ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក
- ព្រះជីវប្រវត្តិរបស់សម្ដេចរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៩ ខែវិច្ឆិកា ឆ្នាំ២០១៩

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២៣៩ ខែវិច្ឆិកា ឆ្នាំ២០១៩

## មាតិកា

### សំបុត្រ

◆ អំពើប្រល័យពូជសាសន៍....................................................១

### ផ្នែកឯកសារ

◆ រឿងរ៉ាវចេញពីគ្រួសារ តឹក សេងអេង................................. ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ដៃ សែម អតីតពេទ្យខ្មែរក្រហម....................................... ១១
◆ បូជាភ្លើង សំណួរដែលបានសួរមកខ្ញុំ ..................................១៣
◆ ព្រះជីវប្រវត្តិរបស់សម្តេចរាជបុត្រី ................................. ២៥
◆ ម៉ៃ សារុំ ជនជាតិព័រ......................................................៣០
◆ រៀនប្រវត្តិសាស្ត្រដើម្បីបញ្ចៀសការស្អប់ខ្ពើម....................... ៣៦

### ផ្នែកច្បាប់

◆ សាលក្រមសំណុំរឿង០០២/០២.......................................៣៩

### វេទិកាពិភាក្សាសាធារណៈ

◆ សៀវភៅអំពើប្រល័យពូជសាសន៍..................................... ៥១

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ សេចក្តីប្រកាសស្វែងរកសាច់ញាតិ....................................៥៤
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់ ..........................................៥៥



សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ព.ម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

***ស្នេរលេខនេះ៖*** *ឆាំង យុ, រី លក្ខិណា, , សួគ្រ វិចិត្រ , ឡុង ដានី , វ៉ាន់ថាន់ ពៅដារ៉ា* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ហូ ផុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយករងទី១៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ផុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *ផាត ចាន់សុនិតា* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រ ពិភពលោក

យើងអាចនិយាយបានថាលទ្ធិប្រជាធិបតេយ្យគឺជាកម្លាំងដែលមិនចេះចុះញ៉មនៅក្នុងប្រវត្តិសាស្ត្រ។ ក្នុងនាមសេរីភាពនិងសមភាពលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់ដល់សម្លេងរបស់មនុស្សប្រុសស្រី និងបំបែកប្រព័ន្ធនយោបាយបែបឋានានុក្រម។ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរការអប់រំនាំមកនូវសក្តានុពលប្រកបដោយ ថាមពលក្នុងការកែប្រែសង្គម។ការអប់រំដែលផ្តោតលើ ការត្រិះរិះពិចារណាការឆ្លុះបញ្ចាំងអំពីខ្លួនឯង និងសេចក្តីអាណិតអាសូរអាចបង្កើតជាផ្នត់គំនិតថ្មីៗជាលក្ខណៈបុគ្គល និងជារួមដើម្បីបង្ហាញពីការយល់ឃើញនិងផ្តល់ដល់មនុស្ស នូវឧបករណ៍ក្នុងការចោទសួរខ្លួនឯងស្ថាប័ន និងពិភពលោក។ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរការអប់រំក៏អាចជាអំណាចដ៏វិសេសវិសាលរបស់មនុស្សជាតិក្នុងការសម្រេច បាននូវសន្តិភាពសេរីភាព និងយុត្តិធម៌។

ការសិក្សាអំពីប្រវត្តិសាស្ត្រគឺជាសមាសធាតុសំខាន់សម្រាប់ចក្ខុវិស័យនៃការអប់រំ។ ប្រវត្តិសាស្ត្រអាចត្រូវបានសិក្សា ដើម្បីបណ្តុះការយល់ដឹងនិងឆ្លុះបញ្ចាំងប្រកបដោយការត្រិះរិះពិចារណា តាមរយៈ គំនិតពីអតីតកាល ពីមនុស្ស និងពីស្ថាប័ន។ប្រវត្តិសាស្ត្រអាចជាមូលដ្ឋានគ្រឹះនៃក្តីសង្ឃឹម ការលើកទឹកចិត្តនិងការសណ្តោសប្រណី។ ទន្ទឹមនឹងនេះដែរប្រវត្តិសាស្ត្រក៏អាចត្រូវបាន ប្រើប្រាស់ជាសម្ភារសម្រាប់ការអប់រំដើម្បីពន្យល់អំពីកំហុសគុណវិបត្តិ និងអំពើខុសឆ្គងនៅក្នុងសង្គម។ប្រវត្តិសាស្ត្រជំរុញឲ្យបុគ្គលហ៊ានប្រឈមមទទួលស្គាល់ទុក្ខវេទនាដែលបង្កដោយសារ សាសនា វប្បធម៌និងប្រទេសជាតិ។ប្រវត្តិសាស្ត្រជំរុញឲ្យបុគ្គលហ៊ានប្រឈមមុខនឹងភាពភ័យខ្លាចដែលកើតមានឡើងនៅក្នុងសង្គម។

ដោយសារតែអំណាចដ៏មហិមានៃប្រវត្តិសាស្ត្រក្នុងការបង្កើតអត្តសញ្ញាណវប្បធម៌ និងចក្ខុវិស័យបែបសហសម័យយើងត្រូវតែធ្វើឲ្យការសិក្សា អំពីប្រវត្តិសាស្ត្រប្រែទៅជាសមាសធាតុដ៏មានសារសំខាន់ សម្រាប់យុត្តិសាស្ត្រជាសកលក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ ទោះជាបញ្ហាជាសកល តម្រូវឲ្យមានយុត្តិសាស្ត្រជាសកលក្នុងការដោះស្រាយយ៉ាងណាក៏ដោយ ក៏យុត្តិសាស្ត្រទាំងនេះត្រូវពឹងផ្អែកលើការចូលរួមពីសំណាក់ ថ្នាក់មូលដ្ឋានដែលមិនអាចខ្វះបានទាល់តែសោះ។

យុត្តិសាស្ត្រជាសកលនានា ដែលត្រូវបានប្រើប្រាស់



សម្រាប់បង្ការ និងទប់ស្កាត់ អំពើប្រល័យពូជសាសន៍ គឺពិតជាចាំបាច់ក្នុងការកំណត់លក្ខខណ្ឌ និងទិកាសទូទៅសម្រាប់កិច្ចសហប្រតិបត្តិការ និងការធ្វើការរួមគ្នា។ ទោះបីជាយ៉ាងណាក៏ដោយសូម្បីតែពិភពលោកនៅក្នុង យុគសម័យសកលភាវូបនីយកម្មក្តីក៏រាល់បញ្ហានិងដំណោះស្រាយទាំងអស់ត្រូវកើតចេញពីការផ្តួចផ្តើមនៅតាមបណ្តាភូមិ ឃុំ។ ប្រសិនបើយើងទទួលស្គាល់ថាមនុស្សគ្រប់រូបមានសក្តានុពលដើម្បីផ្លាស់ប្តូរបុគ្គលនិងសហគមន៍នោះ នឹងដើរតួនាទីជាផ្នែកយ៉ាងសំខាន់មួយនៃយុត្តិសាស្ត្រសកលលោក។ទោះជាមានធនធានប៉ុន្មានក៏ដោយ ជោគជ័យនៃយុត្តិសាស្ត្រជាសកលនឹងអាស្រ័យទៅលើ ការចូលរួមការដឹកនាំ និងភាពជាម្ចាស់ការរបស់សហគមន៍ក្នុងភូមិឃុំ។ ភាពជាម្ចាស់ការ ក្នុងភូមិឃុំលើយុត្តិសាស្ត្រនានាពុំមែនមានន័យថា សហគមន៍ក្នុងភូមិឃុំ អាចឬគួរតែដោះស្រាយបញ្ហារបស់ខ្លួនដោយខ្លួនឯងនោះទេ។ ការណែនាំផ្លូវការគាំពារការអប់រំនិងគោលគំនិតគឺសុទ្ធសឹងតែជាផ្នែកដ៏សំខាន់ដែលសហគមន៍អន្តរជាតិ អាចចូលរួមចំណែកដើម្បីលើកកម្ពស់និងជួយដល់បុគ្គលក៏ដូចជា ស្ថាប័នមូលដ្ឋានឲ្យចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែង ជាសកលដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ប្រវត្តិសាស្ត្រគឺ មិនត្រឹមតែពឹងផ្អែកលើការផ្តល់ពេលវេលាឬជួយមនុស្សតែប៉ុណ្ណោះទេ។យើងត្រូវតែចំណាយធនធានលើប្រតិបត្តិការ និងសម្ភារឧបទេសព្រោះថាគ្រូបង្រៀនល្អគឺ ត្រូវពឹងផ្អែកលើបរិយាកាសសិក្សាដែលមានប្រភពធនធានល្អគ្រប់គ្រាន់។

កម្មវិធីសិក្សាគ្រប់ជ្រុងជ្រោយ ស្តីពីការសម្លាប់រង្គាលផ្សេងៗនៅក្នុងប្រវត្តិសាស្ត្រ គឺជាការចូលរួមចំណែកតូចមួយចំពោះការតស៊ូកម្រិតមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា។ ទោះបីជាប្រទេសកម្ពុជាបាន បោះជំហានយ៉ាងសំខាន់ក្នុងការបង្រៀនប្រវត្តិសាស្ត្ររបស់ខ្លួននៅតាមបណ្តាសាលារៀននិងសហគមន៍អាទិភាពយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវសម្រេចឲ្យបាន ក្នុងការអប់រំមនុស្សជំនាន់ក្រោយពីអំពើប្រល័យពូជសាសន៍ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។កម្មវិធីសិក្សានេះ មានគោលបំណងបំពេញចន្លោះខ្វះខាតទាំងអស់ តាមរយៈការផ្តល់ជារូបភាពនិងឧទាហរណ៍នៃបទពិសោធន៍ នៅក្នុងសង្គមដទៃទៀតទាក់ទងនឹងការសម្លាប់រង្គាលនានា។ កម្មវិធីសិក្សា នេះផ្តល់ដល់អ្នកអប់រំនូវប្រភពធនធានជាច្រើនដើម្បីបង្កើនការយល់ដឹងរបស់សិស្សអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងជំរុញឲ្យមានការពិភាក្សាដេញដោលពីបទពិសោធន៍ របស់ប្រទេសកម្ពុជាជាមួយនឹងការសម្លាប់រង្គាលក្នុងប្រទេសនានាថាតើការសម្លាប់រង្គាលទាំងអស់ មានភាពដូចគ្នានិងខុសគ្នាយ៉ាងដូចម្តេចខ្លះ។ សង្គមទាំងអស់តម្រូវឲ្យ មានកម្មវិធីសិក្សាដែលទាក់ទាញចំណាប់អារម្មណ៍ និងជំរុញឲ្យមានការផ្លាស់ប្តូរព្រោះថាគោលបំណងចម្បងនៃការអប់រំ គឺមិនត្រឹមតែបង្ហាញឲ្យឃើញពីការសិក្សារបស់សិស្សតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជជែកវែកញែកអំពីការគិតទុកជាមុន និងការស្វែងយល់អំពីព័ត៌មាននិងគំនិតថ្មីៗទៀត។ ប្រជាជនកម្ពុជាអាចអះអាងអំពីសារសំខាន់ នៃការគិតដែលជំរុញឲ្យមានការផ្លាស់ប្តូរ។ប៉ុន្តែទម្រង់ជាទូទៅសកម្មភាព និងគំនិតទាំងនេះរបស់ប្រជាជនកម្ពុជាតែងតែត្រូវបានផ្ទុកទៅដោយក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅចង់បានសន្តិសុខ ជាអាទិភាពមានប្រៀបជាងការជំរុញទឹកចិត្តនិងនវានុវត្តភាពទៅវិញ។ ទំនើបភាវូបនីយកម្ម និងភាពច្នៃប្រតិដ្ឋ គឺអាស្រ័យលើអ្នកដឹកនាំ ហើយយើងចាំបាច់ត្រូវតែធ្វើឲ្យប្រសើរឡើងនូវវិធី ដែលអាចលើកកម្ពស់ការពិចារណាដោយអង់អាច និងប៉ិនប្រសព្វ។កម្មវិធីសិក្សានេះនឹងក្លាយជាផ្នែកតូចមួយ ដើម្បីបំពេញបន្ថែមទៅលើសកម្មភាពផ្សេងៗសម្រាប់អភិវឌ្ឍន៍ចំណេះដឹង ផ្នែកប្រវត្តិសាស្ត្រដល់មនុស្សជំនាន់ក្រោយ។ គ្មានអ្វីគួរឲ្យមន្ទិលទៀតទេថា ប្រវត្តិសាស្ត្រដើរតួនាទីសំខាន់ជាវេទិកា ដ៏សំខាន់មួយសម្រាប់ឈានទៅបង្កើតវប្បធម៌មួយ ដែលគោរពនិងការពារលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអភិវឌ្ឍ។

**ឆាំង យុ**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
វិទ្យាលេខ១០, ផ្លូវ២៩៦ ភូមិ៣
សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានី ភ្នំពេញ





វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅវិទ្យាលេខ១០, ផ្លូវ២៩៦, ភ្នំពេញ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំសម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាន ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# រឿងរ៉ាវចេញពីគ្រួសារ តឹក សេងអេង ៖ ប្រធានបច្ចេកទេសផ្លូវរថភ្លើង

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D២១២៨២

ខ្ញុំឈ្មោះ តឹកសេង អេង។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិត្រពាំងវែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ខ្ញុំមានឪពុកឈ្មោះដួន និង ម្តាយឈ្មោះ នាង យិម។ អ្នកទាំងពីរបានស្លាប់បាត់ជីវិតហើយ។ ខ្ញុំ បានរៀបការនៅឆ្នាំ១៩៤៨ ជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះម៉ក់ណយ ស៊ីមក្រោមការផ្សំផ្គុំរបស់ឪពុកម្តាយ។ បន្ទាប់ពីខ្ញុំ រៀបការរួចខ្ញុំ បាននាំ ប្រពន្ធរបស់ខ្ញុំទៅរស់នៅជាមួយខ្ញុំ តាមការដ្ឋាន ផ្លូវដែក ដែលត្រូវសាងសង់និងការដ្ឋានផ្លូវដែកដែលត្រូវជួសជុលតាមការចាត់តាំងរបស់រាជការ។ ខ្ញុំមានកូនទាំងអស់ ១០នាក់។ កូនៗ របស់ខ្ញុំ រួមទាំងចៅពីរនាក់ដែលមានអាយុ៤ឆ្នាំ និងអាយុ៦ឆ្នាំ បានក្លាយជាអ្នកទោសហើយបញ្ជូនមកកាន់ គុកទួលស្លែង ដោយអង្គការចោទប្រកាន់ថាក្បត់បដិវត្តន៍។

ក្រុមគ្រួសារខ្ញុំត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ៖

ប្រពន្ធ ខ្ញុំត្រូវបានអង្គការចាប់ខ្លួន នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ១៩ ៧ ៦ ។ កូនស្រីច្បងរបស់ខ្ញុំឈ្មោះអេងសុកឆេង( មិនឃើញប្រវត្តិរូប)អាយុ២៨ឆ្នាំ(នៅឆ្នាំ១៩៧៦)។ នាងមានប្តីឈ្មោះង៉ូវប៉ោសេង។កូនស្រីទី២ឈ្មោះ អេង ម៉ា ការិន កើតនៅស្រុកបាកានខេត្តពោធិ៍សាត់។ម៉ាការិនត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃ



តឹក សេងអេង



ម៉ក ណយស៊ីម ប្រពន្ធរបស់ តឹក សេងអេង



គឹក គាំសិរីល័យ




អេង វុទ្ធី



អេង រាត្រី




អេង ម៉ាការិន

ទី១៩ ខែធ្នូ ឆ្នាំ១៩៧៦។ មុនឆ្នាំ១៩៧៥ នាងធ្វើការនៅខ្មែរអាកាសចរណ៍។ក្រោយមក កូនខ្ញុំធ្វើការនៅក្រសួងរថភ្លើងដោយមានតួនាទីជាប្រធានពួក។ កូនស្រីទី៣) ឈ្មោះតឹកគាំសិរីល័យ កើតនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ នាងមានតួនាទីជាកម្មកររទេះភ្លើងដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ខែធ្នូ ឆ្នាំ១៩៧៦។កូនប្រុសទី៤ឈ្មោះអេងរាត្រីអាយុ២១ឆ្នាំ(នៅឆ្នាំ ១៩៧៦) កើតនៅពោធិ៍ចិនតុង។ រាត្រីរៀនបានត្រឹមថ្នាក់ទី២ហើយក្រោយមក ធ្វើជាកម្មកររថភ្លើង នៅស្រុកបាណន់។រាត្រីត្រូវបានចាប់ខ្លួន នៅថ្ងៃទី៩ខែមករាឆ្នាំ១៩៧៧។ កូនប្រុសទី៥)ឈ្មោះអេងសួរស្តី អាយុ២០ឆ្នាំ (នៅឆ្នាំ១៩៧៦) ធ្វើជាកម្មករ រទេះភ្លើង។ សួរស្តីរៀនបានត្រឹមថ្នាក់ទី៧ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២០ ខែធ្នូឆ្នាំ១៩៧៦។កូនស្រីទី៦) ឈ្មោះអេងរស្មីមានអាយុ១៨ឆ្នាំ (នៅឆ្នាំ១៩៧៦) រៀនបានត្រឹមថ្នាក់ទី៦ធ្វើជាកម្មកររទេះភ្លើង។ រស្មីត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៩ ខែធ្នូឆ្នាំ១៩៧៦។កូនស្រីទី៧)ឈ្មោះអេង សោវត្ថា អាយុ១៧ឆ្នាំ (នៅឆ្នាំ១៩៧៦) រៀនដល់ថ្នាក់ទី៨។ នាងត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៩ខែធ្នូ ឆ្នាំ១៩៧៦។ កូនស្រីទី៨) ឈ្មោះអេង វុឌ្ឍី អាយុ១៥ឆ្នាំនៅឆ្នាំ១៩៧៦)រៀនដល់ថ្នាក់ទី៩។ នាង ត្រូវបានអង្គការចាប់ខ្លួន នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦។ កូនប្រុសទី៩)ឈ្មោះ អេងសារដ្ឋ រៀនថ្នាក់ទី១២។ សារដ្ឋត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃ



ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

ទីផ្នែក :

១- ឈ្មោះដើម តឹក សេងអេង

- ឈ្មោះប្រែ

២- អាយុ ៥៤ ឆ្នាំ ជនជាតិ ខ្មែរ ភេទ ប្រុស

៣- ទីលំនៅកំណើតកើតនៅភូមិ [illegible]

ឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]

៤- ក្រសួងនិងនាទី មុនថ្ងៃរំដោះភ្នំពេញ ( ក្នុងឆ្នាំ ១៩៧៥ ) កម្មកររទេះភ្លើង [illegible]

៥- ក្រសួងនិងនាទី បច្ចុប្បន្ន កម្មកររទេះភ្លើង [illegible]

៦- ឪពុកឈ្មោះ [illegible] ម្ដាយឈ្មោះ [illegible]

៧- ប្រពន្ធ ឬ ប្ដី ឈ្មោះដើម [illegible] ឈ្មោះប្រែ

៨- ទីលំនៅកំណើតកើតនៅភូមិ [illegible] ឃុំ សង្កាត់លេខ ៣.

ស្រុក ស្អាង ខេត្ត កណ្ដាល ។

៩- បច្ចុប្បន្ន នៅ

១០- មានកូនប្រុសចំនួន ៤ នាក់ កូនស្រី ៦ នាក់

១១- ទីកន្លែងឃាត់ខ្លួន រទេះភ្លើង

១២- ឃាត់ខ្លួន ថ្ងៃទី ១៩ ខែ ១២ ឆ្នាំ ១៩៧៦ ។ ផ្ទះ [illegible] បន្ទប់ធំ ៤ [illegible]

ប្រវត្តិរូប តឹក សេងអេង

ទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ និងកូនពៅម្នាក់ អាយុ៤ឆ្នាំ (មិនឃើញប្រវត្តិរូប)។

## ប្រវត្តិរូបរបស់ខ្ញុំនៅមុនពេលបញ្ជូនមកមន្ទីរស-២១

នៅអាយុ៧ឆ្នាំ ម្តាយរបស់ខ្ញុំបាននាំខ្ញុំទៅនៅវត្តក្តីសែនដើម្បីឲ្យខ្ញុំរៀនសូត្រ។ ខ្ញុំបានរស់នៅវត្តក្តីសែនបាន៣ឆ្នាំ ប៉ុន្តែខ្ញុំរៀនមិនឆ្លាតនិងអានសំបុត្រមិនរួច ដូច្នេះ ឪពុកខ្ញុំបានសម្រេចចិត្តយកខ្ញុំត្រឡប់ទៅផ្ទះវិញ។ ខ្ញុំបានជួយធ្វើការឪពុកម្តាយដូចជា ៖ ប្រូតស្មៅឲ្យគោ-ក្របី, ភ្ជួររាស់ ដកស្ទូង ... ជញ្ជូនស្រូវពូជ ដាំពោតដាំត្រសក់ សណ្តែកជាដើម។ រហូតដល់ខ្ញុំអាយុ១៧ឆ្នាំ មានអាចារ្យម្នាក់ឈ្មោះហេងបានមកលេងស្រុកខ្ញុំ ហើយបានបបួលខ្ញុំមកភ្នំពេញ។អាចារ្យ ហេងបានយកខ្ញុំទៅផ្ញើនៅវត្តរបស់លោកគ្រូម៉ែន។ ខ្ញុំ បានរៀននៅសាលាវត្តបាន ២ឆ្នាំ ក៏ប្រឡងជាប់សញ្ញាបត្រ ហើយខ្ញុំបានសុំចូលរៀននៅសាលាបារាំង (ហ្វ្រង់ស្វាបូឌូវាំង) ។ខ្ញុំរៀនបានពីរទៅបីខែចាងហ្វាងសាលាបារាំងបានឲ្យសិស្សថ្នាក់ទាបឈប់រៀន។ ខ្ញុំ ក៏បានមកសុំនាយកសាលាចូលរៀននៅសាលានៅចាក់អង្រែវិញ។ ខ្ញុំ រៀនបាន៤ឆ្នាំ ក៏ប្រឡងថ្នាក់សឺទីហ្វីកាប៉ុន្តែខ្ញុំប្រឡងធ្លាក់ហើយក៏ឈប់រៀន។ក្រោយមក ខ្ញុំ បានធ្វើការនៅហាងចិនលក់ថ្នាំដែលមានទីតាំងនៅផ្សារចាស់។ ខ្ញុំបានហូបបាយនៅហាងចិលលក់ថ្នាំ និងបានប្រាក់ខ្លះចំណែកពេលយប់ខ្ញុំមកសម្រាកនៅវត្តវិញ។

ខ្ញុំធ្វើការនៅហាងលក់ថ្នាំបានកន្លះឆ្នាំ ក៏បានស្គាល់មិត្តភក្តិម្នាក់ឈ្មោះកុយអ៊ុំ ធ្វើការនៅក្រសួងឃោសនាការបានប្រាប់ខ្ញុំថា នៅក្រសួងរថភ្លើងមានសេចក្តីប្រកាសជ្រើសរើសកាបូរ៉ាល់(កម្មករ)ចំនួន៣០នាក់ដើម្បីរៀនបច្ចេកទេសខាងផ្លូវដែក។ខ្ញុំនិងកុយ អ៊ុំ បានដាក់ពាក្យហើយបានរៀនរយៈពេល១១ខែទើបបានបញ្ចប់វគ្គ។

នៅខែធ្នូ ឆ្នាំ១៩៨៦ សៀមប្រគល់រថភ្លើងពីរខ្សែឲ្យមកខ្មែរគឺមួយខ្សែ សម្រាប់ដឹកស្បៀង និងមួយខ្សែទៀតសម្រាប់ដឹ




អេង សួរស្តី



អេង រស្មី

កកម្មករចេញពីភ្នំពេញ។ នៅថ្ងៃ ទី៩ ខែធ្នូ ឆ្នាំ ១៩៤៦ ខ្ញុំបាន ធ្វើដំណើរមកដល់ស្ថានីយរថភ្លើងប៉ោយប៉ែត ហើយដាក់កម្មក រចុះជួសជុលផ្លូវរថភ្លើងនៅទីនោះ។ នៅឆ្នាំ១៩៤៧រាជការបាន ផ្លាស់ខ្ញុំមកខេត្តពោធិ៍សាត់។ក្រោយមក នៅឆ្នាំ១៩៤៩ ដោយ ស្ថានភាពផ្លូវខូចខាតច្រើនពេករាជការបានផ្លាស់ខ្ញុំមកនៅស្ថានី យព្រៃស្វាយនៅក្នុងស្រុកមោងឫស្សីវិញ។

នៅចុងឆ្នាំ ១៩៥១ យៀក មិញ បានចាប់ខ្ញុំយកទៅក្នុង ព្រៃហើយរយៈពេល៤ ទៅ៥ ថ្ងៃទើបបានដោះលែងខ្ញុំមកវិញ។ ដោយសារខ្ញុំខ្លាចយៀកមិញចាប់ខ្ញុំម្តងទៀត ខ្ញុំក៏បានស្នើសុំរាជ ការផ្លាស់មកភ្នំពេញ។ ប៉ុន្តែ រាជការមិនយល់ព្រមក៏បានផ្លាស់ ខ្ញុំមកស្ថានីយស្តុកអាចម៍រមាសនៅក្នុងខេត្តកំពង់ឆ្នាំង។ ខ្ញុំធ្វើកា របានប្រហែលជា៦ខែក៏សុំលាឈប់ពីក្រសួងរទេះភ្លើង ហើយ បានមករស់នៅជាមួយម្តាយមីងលក់គុយទាវនៅផ្សារថ្មី។ ប្រពន្ធខ្ញុំបានជួយដាំបាយឲ្យម្តាយមីងរបស់ខ្ញុំ ចំណែកខ្ញុំមិនបាន ធ្វើការងារអ្វីទេ។ ពីរខែក្រោយមក ខ្ញុំបានជួបឈ្មោះ ធុន ហេង ធ្វើការនៅរទេះភ្លើងភ្នំពេញ បានណែនាំខ្ញុំពីរបបសេរី។ នៅឆ្នាំ ១៩៥៣ខ្ញុំបានចូលធ្វើការនៅក្រសួងរទេះភ្លើងម្តងទៀត។



អេង សារដ្ឋ

នៅឆ្នាំ១៩៧០ ខ្ញុំ បានទៅនៅ កំពង់សោម ជាមួយឈ្មោះ ឯម ធុល ដែលធ្វើការនៅស្ថានីយរទេះភ្លើងកំពង់សោម។ក្រោ យមក ឯមធុល ត្រូវផ្លាស់មករស់នៅភ្នំពេញ វិញហើយពេល នោះខ្ញុំក៏បានជូនគាត់មកដែរ។ ធុល បានបបួលខ្ញុំទៅលេងផ្ទះ ប្អូនរបស់គាត់ឈ្មោះ ឯម ថុស ធ្វើទាហាន ដែលមានទីតាំងនៅ ខាងក្រោយផ្សារធំថ្មី។ ឯម ថុស បានបបួលខ្ញុំចូលធ្វើជាទាហាន ប៉ុន្តែ ខ្ញុំបានបដិសេធព្រោះខ្ញុំធ្វើការរទេះភ្លើងរវល់ខ្លាំងណាស់។ ថុស បានណែនាំខ្ញុំថា ធ្វើតែថ្ងៃឈប់សម្រាកប៉ុណ្ណោះ ទើបខ្ញុំ យល់ព្រម។ ខ្ញុំ បានប្រាប់ ថុស ថាថ្ងៃស្អែកខ្ញុំត្រឡប់មកកំពង់ សោមវិញ។ ខ្ញុំក៏បានណែនាំបានឈ្មោះ ណី យឿន, ខាន់ ធីធ្វើ ការនៅរទេះភ្លើងឲ្យជួយស៊ើបការណ៍នៅក្នុងក្រុងកំពង់សោម។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារខ្ញុំធ្វើ ជាកុម្មង់ដូយាមស្ថានីយរថភ្លើងនៅកំពង់សោម។ នៅឆ្នាំ១៩៧២ដែលផ្លូវជាតិលេខ៤ត្រូវកាត់ផ្តាច់ ខ្ញុំបានចាត់តាំងកូនខ្ញុំម្នាក់ ឈ្មោះ អេង សុកឆេង ចាំទទួលសំបុត្រតាមយន្តហោះទៅឲ្យ ឈ្មោះ ឯម ថុស នៅភ្នំពេញ។ ក្រោយមកខ្ញុំបានអប់រំកូនប្រ សាខ្ញុំឈ្មោះប៉ោសេង តាមដានកម្មករ និងអ្នកជិះយន្តហោះទៅ មកភ្នំពេញនិងកំពង់សោម។

នៅខែកញ្ញា ឆ្នាំ១៩៧៤ ខ្ញុំបានផ្លាស់ពីកំពង់សោម មករស់នៅភ្នំពេញ។ ខ្ញុំបានទទួលការចាត់ឲ្យជីកស្រះចិញ្ចឹមត្រី ក្នុងបរិវេណស្ថានីយរថភ្លើង ហើយខ្ញុំក៏បានបបួលកម្មករចាស់ ឈ្មោះ សន ឲ្យធ្វើការជាមួយខ្ញុំ។

ក្រោយមក ឈ្មោះ ឯម ថុល បានហៅខ្ញុំ និងសមាជិក ក្រុម ដែលធ្វើការជាមួយគាត់មកជប់លៀងមុនបុណ្យចូលឆ្នាំ ខ្មែរ។ បន្ទាប់ពីជប់លៀងហើយឯមថុលបានថ្លែងថាកម្លាំងទាំង អស់ត្រូវដាក់កម្លាំងការពារ កុំឲ្យខ្មែរក្រហមវាយចូលទីក្រុង បានហើយត្រូវបន្ថែមកងទ័ពឈ្លបមើលឲ្យបានតឹងរ៉ឹង។ប្រសិន បើទ័ពព្រៃវាយចូលភ្នំពេញបាន យើងត្រូវរត់ទៅស្រុកកំណើត

វៀនៗខ្លួនហើយឲ្យបងប្អូនយើងជួយលាក់ប្រវត្តិរូប។

នៅវេលាម៉ោង៩ព្រឹក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍បានចូលមកដល់ទីក្រុងភ្នំពេញ ហើយម្នាក់ៗបាននាំគ្នាទះដៃស្រែកហោ។ បន្តិចក្រោយមក នៅវេលាម៉ោង ១១កងទ័ពខ្មែរក្រហម បានដេញប្រជាជនចេញពីផ្ទះទាំងអស់គ្នា។ ខ្ញុំ បានរៀបចំអីវ៉ាន់បន្តិចបន្តួច ចេញពីផ្ទះនៅផ្សារធំថ្មីជាមួយប្អូនថ្លៃខ្ញុំមួយគ្រួសារទៀត។ យើងបាន ទៅសម្រាកនៅផ្ទះបងថ្លៃនៅទឹកល្អក់មួយយប់។ ពេលនោះ យើងនៅនិយាយគ្នាលេងនិងមានសេចក្តីសប្បាយរីករាយនៅឡើយ។ នៅថ្ងៃបន្ទាប់យើងបានធ្វើដំណើរទៅផ្ទះប្អូន នៅពោធិ៍ចិនតុងមួយគ្រួសារទៀត។នៅតាមផ្លូវយោធាបានដកហូតយកឡានយើង។គ្រួសារខ្ញុំ មានគោលបំណងទៅស្រុកបាទី ព្រោះមានម្តាយធំខ្ញុំរស់នៅភូមិចំបក់ជិតសាលាស្រុកបាទី។ បងប្អូនក្រុមគ្រួសារខ្ញុំទាំងអស់មានគ្នា៤០នាក់។ យើងធ្វើដំណើរតាមផ្លូវអស់កម្លាំងក៏បាននាំគ្នាឈប់បោះជំរំសម្រាកនៅភូមិព្រៃព្រីង១យប់។

ពេលព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥គ្រួសារខ្ញុំបានរៀបចំបន្តដំណើរទៅមុខទៀត ដើម្បីឲ្យដល់គោលដៅ។ នៅរសៀលម៉ោង២យើងបានទៅដល់ស្ទឹងកន្ទួត ក៏បានបោះជំរំនៅទីនោះម្តងទៀត។នៅព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ខ្ញុំឮខ្មែរក្រហមជិះឡានដើរប្រកាសថា «កម្មករគ្រប់រោងចក្ររថភ្លើង អគ្គិសនី តម្បាញ និងរដ្ឋករទឹកត្រូវចូលធ្វើការវិញ»។ ខ្ញុំក៏បានទៅប្រាប់អ្នកប្រកាសនៅលើឡានហើយខ្មែរក្រហមនៅលើឡាននោះបានឲ្យខ្ញុំទៅកត់ឈ្មោះ នៅវត្តទឹកថ្លា។ ខ្ញុំបានរត់ទៅកត់ឈ្មោះនៅវត្តទឹកថ្លា បន្ទាប់មកយោធាខ្មែរក្រហមបានប្រាប់ថាឲ្យយកគ្រួសារទាំងអស់ត្រឡប់មកវិញ។ ខ្ញុំ ក៏បាននាំគ្រួសារមកក្រោយវិញហើយនៅរង់ចាំនៅវត្តទឹកថ្លា។ ខ្ញុំ បានរង់ចាំខ្មែរក្រហមរហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ ទើបបានអង្គការយកឡានមកដឹកខ្ញុំនិងគ្រួសារទៅត្រពាំងក្រសាំង ខេត្តតាកែវហើយនៅវេលាម៉ោង៥ល្ងាចអង្គការ បានដឹកគ្រួសារ និងកូនៗខ្ញុំបន្តមកភ្នំពេញ។ កូនរបស់ខ្ញុំធំៗខ្មែរក្រហមបានចាត់ឲ្យធ្វើការនៅរោងចក្រចំណែកកូនតូចៗនៅមន្ទីរកុមារ។ ខ្ញុំត្រូវទៅជួសជុលផ្លូវដែកនៅខេត្តតាកែវ។ អង្គការបានចាត់តាំងខ្ញុំឲ្យធ្វើផ្លូវដែកចាប់ពីត្រពាំងក្រសាំងរហូតដល់ខេត្តតាកែវដែលដំបូងមានកម្មករចំនួន៣០នាក់ ក្នុងចំណោមនោះខ្ញុំស្គាល់ជិតស្និទ្ធឈ្មោះ គ្រី និង សាក់។ នៅពេលយប់យើងបានលួចប្រជុំគ្នាពីការចង់វិលទៅរករបបចាស់វិញ។ ពេលធ្វើការរួចខ្ញុំតែងតែទៅផ្ទុតទឹកនៅស្ទឹងចាស់ហើយក៏បានជួបឈ្មោះសីហាដែលជាអ្នកធ្វើស្ពាននៅជិតនោះ។ សីហា បានណែនាំខ្ញុំឲ្យរកមនុស្សដែលទុកចិត្តឲ្យបាន៤ ទៅ ៥នាក់ ដើម្បីធ្វើសម្ពាធប្រឆាំងខ្មែរក្រហម ក្នុងនោះមាន ម៉ុន, សំណាង, អ៊ុក បូ និង ហូ។ នៅពេលយប់យើងបានប្រជុំណែនាំហើយចាត់តាំង ម៉ុន ទៅប្រទះឡាងដើរបំផុសប្រជាជនចំណែកសាក់ និងគ្រីឲ្យទៅសង្កាត់ព្រៃទទឹង ។ដល់ខែសីហាឆ្នាំ១៩៧៥ ការតភ្ជាប់ផ្លូវដែកបានទៅដល់ខេត្តតាកែវ ហើយអង្គការបានចាត់តាំង បូ ឲ្យទៅធ្វើប្រធានសង្កាត់ចំណែកខ្ញុំ, សំណាង និង ហួយ ទៅមុខទៀតដល់តានី។

ខែកញ្ញាឆ្នាំ១៩៧៦អង្គការឲ្យខ្ញុំបង្រៀននៅតាមស្ថានីយតាមធម្មតាវិញ។ ឯការបង្រៀនរបៀបស្ទង់ផ្លូវលើកផ្លូវតម្រង់ផ្លូវថ្មីងផ្លូវរបៀបដាក់ព្រីបវាយថ្មបញ្ចូលធ្វើប្រឡាយ និងច្បាប់ចរាចររទេះភ្លើងបើកបរពេលយប់និងពេលថ្ងៃ ការប្រើប្រាស់សម្ភារគ្រប់មុខប្រកបដោយការប្រុងប្រយ័ត្ន។

នៅខែធ្នូ ឆ្នាំ១៩៧៦ ខ្ញុំបានមកជួសជុលផ្លូវដែកខូចខាតដោយសារចម្បាំងនៅឈានមុខ។ បន្ទាប់ពីជួសជុលនៅទីនោះរយៈពេល៤ខែហើយអង្គការបានបញ្ជូនខ្ញុំឲ្យទៅបង្រៀនបច្ចេកទេសនៅខេត្តតាកែវវិញ។ នៅទីនោះខ្ញុំបានទាក់ទងខ្សែរបស់ខ្ញុំជាច្រើននាក់ដែលបានបង្កប់ខ្លួនជាយូរមកហើយ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំឲ្យមកបង្រៀនបច្ចេកទេសនៅទឹកអំបិល របៀបប្រើសម្ភារគ្រប់មុខសម្រាប់ជួសជុលផ្លូវ រយៈពេលមួយអាទិត្យ។ ចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៧៦ អង្គការបានប្រាប់ខ្ញុំថាឲ្យផ្លាស់ទៅធ្វើផ្លូវថ្មី។ ខ្ញុំបានរៀបអីវ៉ាន់ជិះរថភ្លើងឡើងមកភ្នំពេញ។ ពេលមកដល់ភ្នំពេញ អង្គការបានដឹកខ្ញុំមកទីនេះតែម្តងដោយមានគ្រួសារខ្ញុំ និង កូនប្រុស ព្រមទាំងចៅពីនាក់ម្នាក់អាយុ៦ឆ្នាំ និងម្នាក់ទៀតស្រីអាយុ៤ឆ្នាំ។

**ដារ៉ារដ្ឋ មេត្តា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthchenda.s@dccam.org។





















# ង៉ៃ សែម ៖ អតីតពេទ្យខ្មែរក្រហមនៅថ្មបាំង

កាលពីកុមារ ខ្ញុំមិនបានរៀនសូត្រទេ ដោយសារនៅក្នុងភូមិរបស់ខ្ញុំមិនមានសាលារៀន។ ក្រោយមក ខ្ញុំបានចូលធ្វើជាកងសេនាជនការពារភូមិ ត្រពាំងព្រៃស្ថិតនៅក្នុង ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង ព្រោះនៅពេលនោះមានចលនាបដិវត្តន៍ បានកើតឡើង និងតែងជ្រៀតចូលមកក្នុងភូមិ។ នៅឆ្នាំ១៩៧០ ក្រុមខ្មែរក្រហម ចូលទៅដល់ភូមិរបស់ខ្ញុំ និងបានឃោសនាប្រាប់ប្រជាជនពីបដិវត្តន៍របស់ខ្លួន។ ការមកឃោសនានៅតំបន់ដាច់ស្រយាល ដូច្នេះបានធ្វើឲ្យខ្ញុំមានចិត្តចង់ចូលរួមជាមួយខ្មែរក្រហមយ៉ាងខ្លាំង។ពាក្យដែលក្រុមខ្មែរក្រហមប្រើសម្រាប់ឃោសនានៅពេលនោះគឺ «បងប្អូនកសិករត្រូវតែខិតខំប្រឹងប្រែងក្រោកឡើង ដើម្បីរួបរួមកម្លាំងគ្នាតស៊ូប្រឆាំងជាមួយនឹងវណ្ណៈជិះជាន់»។ ក្រុមខ្មែរក្រហមនិយាយរួចហើយ ក៏សំណូមពរឲ្យបងប្អូន នៅក្នុងភូមិឡើងមានមតិ។ដោយសារសង្គមនៅសម័យនោះ មានការជិះជាន់កេងប្រវ័ញ្ច គៀបសង្កត់ពីមេភូមិមេឃុំ ហើយទិន្នផលដែលកសិករដាំបានលក់បានតម្លៃថោក ទើបខ្ញុំ បានជឿជាក់លើក្រុមខ្មែរក្រហមកាន់តែខ្លាំង។ ខ្ញុំបានសម្រេចចិត្ត ចូលរួមជាមួយខ្មែរក្រហមចាប់តាំងពីពេលនោះមក។

បន្ទាប់ពីចូលចលនារបស់ខ្មែរក្រហមរួចមកខ្ញុំក៏បានបន្តឃោសនាអូសទាញ ឲ្យយុវជននៅក្នុងភូមិឲ្យចូលរួមជាមួយខ្ញុំដែរ។ ការឃោសនាអូសទាញ និងបញ្ចុះបញ្ចូលឲ្យយុវជនចូលរួមជាមួយ ខ្ញុំមិនពិបាកទេ ព្រោះយុវជនភាគច្រើន



ង៉ៃ សែម កំពុងវែងឬស្សីធ្វើឈ្នាង

បានជឿជាក់ទៅលើមាគ៌ារបស់ខ្មែរក្រហម។ក្រោយពីប្រមូលបានសមាជិកច្រើនហើយ ខ្ញុំនិងយុវជនទាំងនោះក៏បាននាំគ្នាហ្វឹកហាត់ក្បួនយោធានៅក្នុងព្រៃក្នុងមួយថ្ងៃកន្លះម៉ោង។ នៅពេលនោះក្រុមរបស់ខ្ញុំមានកាំភ្លើងតែ២-៣ដើមតែប៉ុណ្ណោះ។ ដូច្នេះយើងបានបែកកម្លាំង ដើម្បីចាំងឈើធ្វើជាកាំភ្លើងរួចហើយលាបធ្យូង និងថ្នាំពណ៌ខ្មៅៗ ដើម្បីបន្លំភ្នែកកងទ័ពលន់នល់។យើងចេញដើរល្បាតម្តងៗមានសមាជិកប្រមាណចាប់ពី៥នាក់ទៅ១៥នាក់។ កងរបស់ខ្ញុំបានបន្លំដោយបានពាក់ស្បែកជើងរួច ហើយដើរទៅមុខៗរយៈពេលប្រហែល២ម៉ោងក្រោយមក កងរបស់ខ្ញុំបានដោះស្បែកជើងចេញរួចហើយដើរកាត់កន្លែងដដែល ដើម្បីឲ្យកងទ័ពខាង លន់នល់ គិតថាខ្ញុំមានគ្នាច្រើន។ កងរបស់ខ្ញុំបានរស់នៅក្នុងព្រៃដោយមានតែដំឡូង និងក្តួច លាយជាមួយបាយហូប។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានទទួលជ័យជម្នះលើរបប លន់ នល់។ ពេលនោះយោធាខ្មែរក្រហមក៏បានជម្លៀសប្រជាជនថ្មីពីភ្នំពេញមកដល់ស្រុកថ្មបាំង។ ខ្ញុំត្រូវបានខ្មែរក្រហមតែងតាំងធ្វើជាយោធាស្រុកថ្មបាំង ដែលមានប្រធាន ឈ្មោះ នុន និងឈ្មោះ ម៉េង។

ក្រោយមក នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ពីយោធាទៅនៅអង្គភាពពេទ្យ ស្រុកថ្មបាំងវិញ ដោយមានឈ្មោះ យ៉ន គឺជាប្រធានពេទ្យ។ នៅពេលនោះខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការផ្នែរខាងផ្គត់ផ្គង់ស្បៀង និងដំឡូងដល់អ្នកជំងឺ។ ខ្ញុំនិងសមាជិក៥ទៅ៦នាក់ បានរែកដំឡូងពីថ្មបាំង ទៅផ្តល់ឲ្យអ្នកជំងឺនៅមន្ទីរពេទ្យជំនាប់ ព្រោះអ្នកជំងឺមិនមានអាហារហូបគ្រប់គ្រាន់។ ចុងភៅបានបបរមួយខ្ទះ ដោយដាក់លាយដំឡូងត្រយល្ពុងគល់ចេកនិងត្រយូងចេករួចហើយដួសដាក់ចានឲ្យអ្នកជំងឺរួចហើយ ដួសដាក់ចានឲ្យអ្នកជំងឺ ដែលមើលទៅឃើញតែទឹកបបររាវៗ មិនឃើញគ្រាប់អង្ករឬបន្លែឡើយ។ នៅអំឡុងពេលនោះ ខ្ញុំក៏មានជំងឺហើមដែរ ព្រោះតែហូបមិនគ្រប់គ្រាន់។

នៅក្នុងឆ្នាំ១៩៧៦ដដែលខ្ញុំរៀបការជាមួយនារីម្នាក់ដែលធ្វើការនៅក្នុងអង្គភាពពេទ្យឃុំ។ កាលខ្ញុំរៀបការនៅពេលនោះមានទាំងអស់៩គូ ដោយយើងត្រូវឡើងប្តេជ្ញានៅចំពោះមុខអង្គការ។ ក្រោយរៀបការរួច ខ្ញុំនិងប្រពន្ធបានរស់នៅជុំគ្នា ប៉ុន្តែយើងចេញទៅធ្វើការនៅអង្គភាពផ្សេងគ្នា ដោយប្រពន្ធរបស់ខ្ញុំធ្វើការនៅអង្គភាពពេទ្យឃុំចំណែកខ្ញុំនៅអង្គភាពពេទ្យស្រុក។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ ស៊ីវ ដែលជាលេខាស្រុកថ្មបាំងចាស់ចេញ រួចដាក់ឈ្មោះ ផល មកគ្រប់គ្រងជំនួសវិញ។ តាំងពីឈ្មោះ ផល ចូលមកគ្រប់គ្រងសមាជិកនៅក្នុងអង្គភាពបានបាត់ខ្លួនបន្តបន្ទាប់ ធ្វើឲ្យខ្ញុំមានការបារម្ភយ៉ាងខ្លាំង។

រហូតដល់ពេលដែលកងទ័ពវៀតណាម វាយចូលមកប្រទេសកម្ពុជា ខ្ញុំបាន រត់គេចខ្លួនចូលក្នុងព្រៃជាមួយខ្មែរក្រហមម្តងទៀត ដោយសារខ្ញុំបានជឿការឃោសនារបស់ខ្មែរក្រហមថា វៀតណាមនឹងសម្លាប់ខ្មែរក្រហម និងចាប់វះពោះញាត់ស្មៅ។ ខ្ញុំបានទៅរស់នៅថ្មដា ជាប់ព្រំដែនថៃ។ ថ្ងៃមួយកងទ័ពរដ្ឋាភិបាលនៅភ្នំពេញ និងកងទ័ពវៀតណាម បានស៊ើបដឹងកន្លែងលាក់ខ្លួនរបស់ខ្ញុំក៏បាញ់ផ្លោងគ្រាប់មកទីតាំងរបស់ខ្ញុំចាប់តាំងពីម៉ោង៥ព្រឹកបណ្តាលឲ្យយោធាខ្មែរក្រហមមួយចំនួនបានស្លាប់ ហើយអ្នកដែលនៅរស់ជីវិត និងខ្ញុំក៏បានរត់គេចខ្លួន។

នៅឆ្នាំ១៩៩០ ខ្ញុំបាន ចូលមករស់នៅឃុំអូរសោម ស្រុកវាលវែង ដែលពេលនោះមានសុទ្ធតែព្រៃឈើដុះជុំជិត។ ខ្ញុំបានកាប់ឆ្ការព្រៃដើម្បីយកដីធ្វើស្រែចម្ការ និងធ្វើខ្ទមតូចៗរស់នៅបណ្តោះអាសន្ន។ ចំណែកការធ្វើដំណើរលំបាកខ្លាំងណាស់ ហើយប្រសិនបើខ្ញុំចង់ទិញសម្ភារ និងអំបិលសម្រាប់ហូបខ្ញុំត្រូវធ្វើដំណើរទៅទិញពីផ្សារនៅប្រមោយ។ ចំណែកផលដំណាំដែលប្រមូលពីចម្ការ សត្វដែលដាក់អន្ទាក់បាន ខ្ញុំទុកចែកគ្នាជាមួយប្រជាជនក្នុងភូមិហូប។ ខ្ញុំលក់តែខ្លឹមឈើ និងជ័រវល្លិដែលរកបានប៉ុណ្ណោះ។

**វី លក្ខិណា**

# បូជាភ្លើង
## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

ពេលវេលាបានកន្លងផុតទៅ អស់ជាច្រើនឆ្នាំហើយ បន្ទាប់ពីខ្ញុំបានសរសេរអំពីជីវប្រវត្តិរបស់ខ្ញុំ នៅក្នុងសៀវភៅដំណើរទៅអូសឈ្វិចៈបំណែកជីវិត និងសៀវភៅបន្ទាប់ៗមកទៀតរបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមកខ្ញុំបានបង្រៀនសិស្សនៅតាមវិទ្យាល័យ និងមហាវិទ្យាល័យជាច្រើនជាមួយនឹងជំនឿយ៉ាងមុតមាំថាក្មេងៗជំនាន់ក្រោយ ត្រូវតែមានការចងចាំអំពីហូឡូខសន៍(មានន័យជាភាសាខ្មែរថាបូជាដោយភ្លើងឬបូជាភ្លើង) ប្រសិនបើយើងមិនចង់ឲ្យវាកើតឡើងសារជាថ្មីម្តងទៀត។ អ្វីដែលបានកើតឡើងរួចម្តងមកហើយអាចនឹងកើតឡើងបានម្តងទៀតទោះបីជាវាមិនដូចគ្នាទាំងស្រុងយ៉ាងណាក៏ដោយ។ ដើម្បីទប់ស្កាត់ហេតុការណ៍នេះ យើងចាំបាច់ត្រូវមានការចងចាំពីព្រោះអតីតកាល បានបន្សល់ទុកស្លាកស្នាមរហូតដល់បច្ចុប្បន្នកាលនិងបន្តចោលស្រមោលអន្ធការរបស់ខ្លួនទៅអនាគតកាល។

នៅដើមខែកញ្ញា ក្នុងឆ្នាំ១៩៤០ ត្រង់ស៊ីលវ៉ានីខាងជើងត្រូវបានប្រគល់ឲ្យប្រទេសហុងគ្រីវិញ។ នៅពេលនោះខ្ញុំពិតជាអស់សង្ឃឹមខ្លាំងណាស់។ ការធ្វើបាបយាយីទៅលើជនជាតិជ្វីហ្វបានចាប់ផ្តើម ទោះបីជាមិនទាន់ប្រែប្រួលទៅជាការគំរាមកំហែងផ្ទាល់ចំពោះជីវិតរបស់យើងក៏ដោយ។ ប៉ុន្តែមិនយូរប៉ុន្មានផងក៏មានលេចឮដំណឹងពីប្រទេសរូម៉ានីអំពីការសម្លាប់និងការធ្វើបាបជនជាតិជ្វីហ្វ។ នៅប្រទេសម៉ុលដាវីជនជាតិជ្វីហ្វត្រូវបានគេចាប់បញ្ជូន ទៅប្រទេសអ៊ុយក្រែនតាមរថភ្លើងដែលនៅទីនោះពួកគេត្រូវបាន បង្ខំឲ្យជីកផ្នូររបស់ខ្លួនមុនពេលដែលត្រូវបានបាញ់សម្លាប់ចោល។ នៅពេលនោះខ្ញុំពិតជាសប្បាយចិត្តណាស់ដែលយើងរស់នៅក្រោមការគ្រប់គ្រងរបស់ប្រទេសហុងគ្រី។

បន្ទាប់មកនៅក្នុងរដូវរងារ ក៏មានពាក្យនិយាយតៗគ្នាថាជនជាតិជ្វីហ្វនៅតំបន់ខាងកើតជាច្រើននាក់ ត្រូវបានបញ្ជូនតាមរថភ្លើងទៅប្រទេសត្រង់នីស្ទ្រៀ និងអ៊ុយក្រែន។ មកដល់ពេលនេះខ្ញុំបានទម្លាប់ខ្លួនទៅហើយ ជាមួយនឹងការផ្លាស់ប្តូរពីភាពធូរធាទៅភាពមិនសូវមានបាន របស់យើងនៅហុងគ្រីហើយក៏រីករាយដែរដែលយើងមិនបាន នៅក្រោម



ការគ្រប់គ្រងរបស់រូម៉ានីទៀតៗ ខ្ញុំនៅតែអាចស្រមៃឃើញទិដ្ឋភាពរបស់ខ្លួនឯងនៅពេលនោះ ដែលខ្ញុំកំពុងតែអង្គុយចាក់ស្រោមជើងរោមសត្វ សម្រាប់អ្នកដ៏គួរឲ្យអាណិតទាំងនោះដែលមិនត្រូវបាន គេអនុញ្ញាតឲ្យយកសម្លៀកបំពាក់កក់ក្ដៅជាប់ទៅជាមួយៗ បន្ទាប់មក នៅក្នុងខែមីនា ឆ្នាំ១៩៤៤ អាល្លឺម៉ង់បានចូលឈ្លានពានប្រទេសហុងគ្រី ហើយពេលនោះដែរគឺជាពេលវេលាមួយដែលខ្ញុំត្រូវសោកស្ដាយ ដោយយើងមិនបាននៅក្រោមការគ្រប់គ្រងរបស់រូម៉ានី តទៅទៀតៗប្រទេសរូម៉ានីមិនបានប្រគល់ជនជាតិជ្វីហ្វទៅឲ្យ ប្រទេសអាល្លឺម៉ង់ទេផ្ទុយទៅវិញពួកគេ ធ្វើជំនួញជាមួយសហរដ្ឋអាមេរិកដោយបង់ប្រាក់ចំនួន១០០ដុល្លារក្នុងមួយនាក់ សម្រាប់ឱ្យជនជាតិជ្វីហ្វទៅអ៊ីស្រាអែលៗ

នៅទីបំផុតខ្ញុំគ្រាន់តែជា មនុស្សម្នាក់ក្នុងចំណោមមនុស្សមានសំណាងល្អដ៏ទៃទៀតតែប៉ុណ្ណោះៗ ខ្ញុំមានសំណាងល្អជាច្រើនលើកៗសំណាងល្អរបស់ខ្ញុំចាប់ផ្ដើមនៅពេលដែលយើងបានទៅដល់អូសឈ្វិច ដែលនៅទីនោះប្អូនស្រីខ្ញុំ និងខ្ញុំបានរួចផុតពីការជ្រើសរើសដែលមានន័យថា យើងបានគេចផុតពីការបញ្ជូនទៅបន្ទប់ផ្សែងពុលៗ ហេតុការណ៍ចៃដន្យល្អៗបានកើតឡើងជារឿយៗនៅក្នុងអំឡុងពេលដែលខ្ញុំត្រូវបានគេឃុំឃាំងខ្លួនៗ អ្វីដែលសំខាន់នោះគឺខ្ញុំមិនត្រូវបានគេបញ្ជូនទៅជំរំដែលមានស្ថានភាពអាក្រក់ខ្លាំងនោះទេៗ ពីអូសឈ្វិចខ្ញុំត្រូវបានគេបញ្ជូនទៅជំរំបីផ្សេងៗពីគ្នា ដែលនៅទីកន្លែងនោះកិច្ចការរបស់យើងជាទូទៅ គឺត្រូវសម្អាតសំណង់បាក់បែកៗមនុស្សជាច្រើនទៀតត្រូវបាន ដាក់នៅក្នុងជំរំដែលពួកគេត្រូវធ្វើការផ្លាស់វេនគ្នា នៅក្នុងរោងចក្រក្រោមដីអណ្ដូងរ៉ែប្អូកកន្លែងជីករ៉ែៗ ជាច្រើនដងមកហើយដែលខ្ញុំបានស្ថិតនៅ




**ផែនទីប្រទេស និងទីកន្លែងដែលអ្នកនិពន្ធបានលើកឡើង**




***ផែនទីជំរំប្រមូលផ្តុំរបស់ណាហ្ស៊ី***

ក្នុងស្ថានការណ៍មួយ ដែលខ្ញុំប្រាកដក្នុងចិត្តថាគឺជាពេលវេលាចុងក្រោយនៃជីវិតរបស់ខ្ញុំប៉ុន្តែរឿងអ្វីមួយផ្សេងទៀតបានកើតឡើង ហើយខ្ញុំក៏បានរួចជីវិត។

នៅក្នុងជំរំយើងមិនអាចដឹងបានទេ ថាការផ្លាស់ប្តូរនឹងមានន័យថាសេចក្តីស្លាប់ឬរស់។ សូម្បីតែពេលខ្លះនៅក្នុងជីវិតប្រចាំថ្ងៃ ក៏យើងមិនអាចដឹងមុនបានទេថាតើជីវិតនឹងមានអ្វីកើតឡើងទេ។ យើងរស់នៅក្នុងជីវិតមួយស្ងប់ស្ងាត់ហើយពេលវេលាចេះតែកន្លងផុតទៅ ដោយយើងមិនបានចាប់អារម្មណ៍អំពីអ្វីទាំងអស់។ការផ្លាស់ប្តូរកើតឡើងបន្តិចម្តងៗរហូតទាល់តែវិពេចនោះវាបាន បង្ហាញចេញជារូបភាពយ៉ាងច្បាស់ក្រឡែត ទើបយើងចាប់ផ្តើមឆ្ងល់ថាតើរឿងនេះអាចកើតឡើងបានដោយរបៀបណា? ជីវិតបានបង្រៀនយើងថាអ្វីៗទាំងអស់អាចផ្លាស់ប្តូរបានក្នុងមួយប៉ប្រិចភ្នែក ហើយយើងក៏មិនអាចដឹងមុនបានដែរថាការផ្លាស់ប្តូរនោះនឹងនាំយើងឆ្ពោះទៅរកអ្វីមួយ ដែលកាន់តែល្អប្រសើរឬក៏កាន់តែអាក្រក់នោះទេ។

ការបង្រៀនរបស់ខ្ញុំ នៅក្នុងសាលារៀនជាធម្មតាមានពីរផ្នែកដែលផ្តោតសំខាន់ទៅលើផ្នែកទីពីរ។ខ្ញុំចាប់ផ្តើមពីការព្យាយាម បង្ហាញអំពីមនុស្សនាពេលអតីតកាលនិងស្ថានភាពរស់នៅរបស់ពួកគេ ដែលជាចំណែកមួយធ្វើឱ្យមានហូឡូខសន៍។ ក្រោយមកទៀត ខ្ញុំបន្តធ្វើបាឋកថានៅតាមសាលារៀនជាមួយនឹងរឿងរ៉ាវនៃបទពិសោធន៍ផ្ទាល់ខ្លួន របស់ខ្ញុំដែលតែងតែបញ្ចប់ជាមួយពេលវេលា គ្រប់គ្រាន់សម្រាប់ឆ្លើយសំណួរសិស្ស។ ខ្ញុំបានបញ្ជាក់ថាគ្មានសំណួរណាជាសំណួរល្ងីល្ងើឬក៏ត្រូវហាមឃាត់សួរនោះទេ ប៉ុន្តែសម្រាប់សំណួរខ្លះគឺគ្មានចម្លើយតែម្តង។ សំណួរថា«ហេតុអ្វីបានជាហូឡូខសន៍ កើតឡើង?»អ៊ីចឹងវាធ្វើឲ្យសំណួរដែលពាក់ព័ន្ធ ជាច្រើនទៀតកាន់តែមានសារៈសំខាន់ឡើង។

ខ្ញុំបានប្រមូលសំណួរទូទៅ ដែលត្រូវបានសិស្សសួរជាញឹកញាប់មកដាក់ក្នុងសៀវភៅនេះ ដើម្បីជួយដល់អ្នកដែលចង់ដឹងបន្ថែមអំពីការសម្លាប់រង្គាលនៅអឺរ៉ុប។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថាសៀវភៅនេះនឹងត្រូវបាន អានព្រមទាំងផ្តល់ជាប្រយោជន៍ដល់យុវវ័យ សម័យបច្ចុប្បន្ន និងជំនាន់ក្រោយៗតទៀត។ គោលបំណងនៃសៀវភៅនេះ គឺដើម្បីបង្រៀនយើងឲ្យជៀសវាងពីកំហុសប្រវត្តិសាស្ត្រ។ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងធ្វើឲ្យអ្នកអានទាំងអស់គ្នា ដែលបានអានយល់ឃើញថាយើងទាំងអស់គ្នាមិន ត្រូវបានដោតវាសនា កំណត់ឲ្យជាស្រេចថានឹងដើរតួជាឧក្រិដ្ឋជនឬជាអ្នក ដែលឈរមើលបំណាំនោះទេ។ ក្នុងនាមជាបុគ្គលម្នាក់ៗ យើងត្រូវមានឆន្ទៈនិងការទទួលខុសត្រូវ ហើយការចាប់យកការទទួលខុសត្រូវនេះហើយដែលធ្វើឲ្យយើង ទាំងអស់គ្នាអាចជៀសផុតពីប្រវត្តិសាស្ត្រចំដែលបាន។



ហេឌី ប្រ៊ាយ អ្នកនិពន្ធសៀវភៅបុជាភ្លើង

### តើហេតុការណ៍អាក្រក់ខ្លាំងមួយណាដែលបានកើតឡើងចំពោះអ្នក?

ប្រសិនបើអ្នកសួរខ្ញុំ ថាហេតុការណ៍អាក្រក់មួយណាដែលបានកើតឡើងចំពោះខ្ញុំនោះ ខ្ញុំអាចឆ្លើយដោយប្រើតែប្រយោគមួយវាគឺជាពេលដែល ខ្ញុំត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំចង់ផ្តល់ចម្លើយដែលវែងជាងនេះ។ ខ្ញុំនឹងរៀបរាប់ប្រាប់អ្នកអំពីរឿងរ៉ាវ ដែលបានកើតឡើង។ គម្រោងការរបស់អាល្លឺម៉ង់ ដើម្បីសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វគឺជាដំណើរការមួយដែលយឺត ហើយត្រូវបានគិតគូរយ៉ាងល្អិតល្អន់ៗអ្វីៗប្រៀបបានទៅនឹងភ្នែកទទេដែលមិនអាចសង្កេតឃើញអំពីដំណើរការផ្លាស់ប្តូររូបរាងរបស់ផ្កាដែលប្រែប្រួលចេញពីពន្លកហូតបានក្លាយទៅជាផ្កាកុលាបក្រពុំមួយ។ យើងមិនបានកត់សម្គាល់អំពីជំហានតូចៗ ដែលនាំឆ្ពោះទៅរកភាពជោគជ័យដែលអ្នកមិនអាច ស្រមៃឃើញសូម្បីតែនៅក្នុងក្តីសុបិនក៏ដោយ។ គ្រាន់តែក្នុងមួយរំពេចប៉ុណ្ណោះការផ្លាស់ប្តូរដ៏អាក្រក់បានកើតឡើង ប៉ុន្តែយើងអាចរស់នៅជាមួយនឹងការផ្លាស់ប្តូរនេះបាន។ យើងបានគិតថាការផ្លាស់ប្តូរនេះនឹងរំលងផុតទៅ។ ប៉ុន្តែវាមិនបានរំលងផុតនោះទេហើយផ្ទុយទៅវិញការផ្លាស់ប្តូរនេះ បែរជាមានការផ្លាស់ប្តូរថ្មីថែមមួយទៀត។ជាថ្មីម្តងទៀតយើងបានសង្ឃឹមថាការផ្លាស់ប្តូរនេះនឹងរំលងហួសទៅដោយរហ័ស។ យើងក៏មិនអាចនឹកស្មានទាល់តែសោះថាជំហានបន្ទាប់ទៀតគឺជាអ្វីនោះឡើយ។

ទោះបីជា ខ្ញុំបានឆ្លងកាត់រឿងរ៉ាវទាំងអស់នេះក៏ដោយខ្ញុំមានសំណាងល្អ។ រឿងដ៏អាក្រក់បំផុត ដែលអាចកើតឡើងចំពោះមនុស្សម្នាក់មិនបានកើតឡើង ចំពោះខ្ញុំនោះទេ។ដំបូងឡើយខ្ញុំមិនត្រូវបានជាប់នៅក្នុង សំណាញ់របស់អាល្លឺម៉ង់ទេ គឺរហូតទាល់តែជិតចុងបញ្ចប់ នៃសង្គ្រាមនារដូវផ្ការីកក្នុងឆ្នាំ១៩៤៤ ដែលនៅពេលនោះជនជាតិជ្វីហ្វនៅអឺរ៉ុបជាច្រើននាក់ត្រូវបានចាប់ខ្លួនធ្វើជា អ្នកទោសបាត់អស់ទៅហើយ។

ខ្ញុំកើតនៅស៊ីហ្គេត គឺជាទីក្រុងតូចមួយ នៅក្នុងប្រទេសរូម៉ានី នៅភាគខាងជើងនៃប្រទេសត្រង់ស៊ីលវ៉ានី និងគឺជាតំបន់មួយដែលប្រទេសហុងគ្រីនិង រូម៉ានីបានវាយដណ្តើមគ្នាអស់រយៈពេលជាច្រើនសតវត្សរ៍។ រហូតមកទល់បច្ចុប្បន្នប្រទេសទាំងពីរក៏នៅតែចាត់ទុកថា ខ្លួនមានសិទ្ធិទៅលើតំបន់នោះឡើយ។ មុនសង្គ្រាមលោកលើកទី១ស៊ីហ្គេត គឺជាកម្មសិទ្ធិរបស់ប្រទេសហុងគ្រីនិងជាកម្មសិទ្ធរបស់រាជាធិបតេយ្យអូស្ត្រូ- ហុងគ្រី។ប៉ុន្តែបន្ទាប់ពីសន្ធិសញ្ញាទ្រីអាណុណក្នុងឆ្នាំ១៩២០ វាត្រូវបានប្រគល់ឲ្យប្រទេសរូម៉ានី ហើយនៅពេលដែលសង្គ្រាមលោកលើកទីផ្ទុះឡើង អាល្លឺម៉ង់បានដាក់សម្ពាធឲ្យប្រគល់តំបន់នេះទៅឲ្យហុងគ្រីវិញ។ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៤០ហុងគ្រីបានសម្រុកចូលទៅត្រង់ស៊ីលវ៉ានីខាងជើងហើយ ជោគវាសនារបស់យើងក៏ត្រូវបានកំណត់នៅពេលនោះ។

ច្បាប់ណូរែមបឺកមួយចំនួន ត្រូវបានអនុវត្តភ្លាមៗដែលមានន័យថាស្ថានភាពហិរញ្ញវត្ថុ របស់ជនជាតិជ្វីហ្វក៏កាន់តែធ្លាក់ដុនដាបជាងមុន។ មន្ត្រីរាជការដែលជាជនជាតិជ្វីហ្វត្រូវបានបញ្ឈប់ពីការងារ។ វេជ្ជបណ្ឌិតនិងមេធាវីដែលជាជនជាតិជ្វីហ្វត្រូវបានអនុញ្ញាតឲ្យព្យាបាល និងធ្វើជាតំណាងរបស់ជនជាតិជ្វីហ្វគ្នាឯងតែប៉ុណ្ណោះ។ ឯអ្នកដែលមិនមែនជាជនជាតិជ្វីហ្វមិនត្រូវបានអនុញ្ញាត ឲ្យទៅទិញអីវ៉ាន់នៅតាមហាងរបស់ជនជាតិជ្វីហ្វទេ។ ហើយក្មេងៗជនជាតិជ្វីហ្វក៏មិនត្រូវបានអនុញ្ញាតឲ្យទៅសាលារៀនដែរ។ ស្ថានភាពគឺពិតជាអាក្រក់ខ្លាំងណាស់ ប៉ុន្តែជីវិតរបស់យើងមិនត្រូវបានគំរាមកំហែងឡើយ។យើងអាចទម្លាប់ខ្លួនទៅនឹងអ្វីៗគ្រប់យ៉ាងបាន។

មេរៀនមួយដែលយើងអាចរៀនបាន គឺមិនត្រូវទម្លាប់ជាមួយនឹងភាពអយុត្តិធម៌ទេ។ ភាពអយុត្តិធម៌គឺប្រៀបបានដូចជាគ្រាប់ខ្សាច់នៅក្នុងដៃយើង មិនអាចដឹងអំពីទម្ងន់របស់វាបានទេ។ប៉ុន្តែភាពអយុត្តិធម៌មានទំនោរ ក្នុងការកើនឡើងនិង



សូវិចិត្រ មេត្តា អ្នកបកប្រែសៀវភៅបូជាភ្លើង

មានកាន់តែច្រើនឡើងៗ ហើយមិនយូរមិនឆាប់អ្នកមិនអាចទ្រាំទ្របានទៀតទេ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះដែលភាពអយុត្តិធម៌មួយទៀតនឹងកើតមានឡើងៗ យើងត្រូវតែសម្របខ្លួនទៅតាមកាលៈទេសៈរបស់យើង ហើយប្រសិនបើគិតទៅលើអ្វីៗដែលកំពុងតែកើតឡើង នៅក្នុងប្រទេសអាល្លឺម៉ង់និងពិភពលោកទាំងមូលយើងរីករាយ ដែលយើងនៅតែរស់នៅដោយមិនមានគ្រោះថ្នាក់គំរាមកំហែង ដល់ជីវិតរបស់យើងៗ

ប៉ុន្តែហ៊ីត្លែរមិនអាចទទួលយកបានទេ ដែលហុងគ្រី-ជ្វីហ្វ ចំនួន៨០ម៉ឺននាក់រស់នៅដោយសុខស្រួលហើយក៏បានទាមទារឲ្យ មានការផ្លាស់ប្តូរឈ្លើយសឹកចំពោះអ្នកទាំងនោះៗមុនដំបូងប្រមុខរដ្ឋមន្ត្រីមីខលូសហរហ្ស៊ី បានបដិសេធប៉ុន្តែគាត់ត្រូវបានគេចាប់ខ្លួន ហើយអាល្លឺម៉ង់ ក៏បានតែងតាំងមេដឹកនាំចលនារបស់ណាហ្ស៊ីឲ្យធ្វើជានាយករដ្ឋមន្ត្រីជំនួសវិញៗ ហ៊ីវែន សាឡាស៊ីក៏ជាអ្នកដែលមានបំណងចង់កម្ចាត់ជនជាតិជ្វីហ្វម្នាក់ដែរ ដូច្នេះហើយទើបនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៤៤ ព្រំប្រទល់ត្រូវបានបើកឲ្យកងទ័ពអាល្លឺម៉ង់ចូលៗចាប់តាំងពីថ្ងៃនោះមកអ្វីៗបានកើតឡើងយ៉ាងឆាប់រហ័សៗ ក្នុងមួយរំពេចជនជាតិជ្វីហ្វនៅក្នុងប្រទេសហុងគ្រី ត្រូវបានបញ្ជាឲ្យធ្វើផ្កាយពណ៌លឿងហើយ ត្រូវពាក់ជាប់អាវរាល់ពេលដែលចេញទៅក្រៅៗ ជនជាតិជ្វីហ្វមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅទេលុះត្រាតែត្រូវធ្វើភារកិច្ចបន្ទាន់ៗ ជនជាតិជ្វីហ្វមិនអាចឈប់ហើយនិយាយរកគ្នាតាមផ្លូវ មិនអាចទៅរោងភាពយន្តមិនអាចបរិភោគនៅតាមភោជនីយដ្ឋាន ហើយក៏មិនអាចដើរលេងតាមឧទ្យានបានដែរៗ ច្បាប់ទាំងអស់នេះត្រូវតែគោរពតាមការមិនស្តាប់បង្គាប់នឹងត្រូវមានទោសសម្លាប់ចោលៗ

ជាថ្មីម្តងទៀត នេះគឺគ្រាន់តែជាជំហានមួយទៀតរបស់អាល្លឺម៉ង់ ហើយមនុស្សគ្រប់ៗគ្នាក៏បានត្រឹមតែសង្ឃឹមថាអ្វីៗនឹងមិនមានកើតឡើងបន្ថែមទៀតទេៗ ក៏ប៉ុន្តែអ្វីៗបានបន្តកើតមានឡើងតទៅទៀតៗ

សឹងតែមិនបានបួនសប្តាហ៍ផង យើងត្រូវបានគេប្រាប់ថានៅថ្ងៃបន្ទាប់ការរើទីលំនៅ របស់ជនជាតិជ្វីហ្វចេញ ពីទីក្រុងទៅនៅកន្លែងផ្សេងនឹងចាប់ផ្តើមៗ ជនជាតិជ្វីហ្វដែលរស់នៅក្នុងទីក្រុងទាំងអស់ត្រូវរើចេញពីមួយផ្លូវទៅមួយផ្លូវដើម្បីទៅហ្គេតូដែលនៅភាគខាងជើងនៃទីក្រុងៗផ្លូវរបស់យើងត្រូវបានរើចេញមុនគេៗ យើងត្រូវបានអនុញ្ញាតឲ្យយកតែសម្ភារណាដែលអាចយកទៅតាមខ្លួនបាន និងរទេះរុញតែប៉ុណ្ណោះៗ

អំឡុងពេលដែលយើងចាប់ផ្តើមរៀបចំសម្ភារខ្ញុំបានដើរជុំវិញផ្ទះ ហើយនិយាយពាក្យលាវត្ថុទាំងឡាយណាដែលខ្ញុំមិនអាចយកទៅតាមខ្លួនបានៗ បន្ទាប់មកខ្ញុំលេងព្យាណូជាលើកចុងក្រោយហើយក៏អង្អែលគម្របពេលដែលខ្ញុំបិទៗ ខ្ញុំបានសម្លឹងមើលទៅកាន់ទូរសៀវភៅរបស់ខ្ញុំអង្អែលសៀវភៅដែលខ្ញុំស្រឡាញ់ ហើយក៏រត់ទៅក្រោយផ្ទះ ដើម្បីខិបឆ្កែយាមផ្ទះដ៏ស្មោះត្រង់របស់យើង ដែលមានឈ្មោះថាបតរីៗ ខ្ញុំព្យាយាមរម្ងាប់អារម្មណ៍របស់ខ្ញុំ និងវាដោយគិតថាអ្នកជិតខាងរបស់យើងប្រាកដជា មិនភ្លេចមើលថែវាឡើយៗត្រឡប់ចូលទៅក្នុងផ្ទះវិញ ខ្ញុំបានឈប់នៅពីខាងមុខរូបថតយាយតារបស់ខ្ញុំហើយសុំឱ្យពួកគាត់ ជួយមើលថែរក្សាផ្ទះរបស់យើងពេលដែលយើងមិននៅៗ ខ្ញុំបានជឿជាក់ថាយើងនឹងត្រឡប់មកវិញៗ ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់មិនបានដំណើរការល្អដូចពីមុនទៀតទេពីព្រោះរុស្ស៊ី នៅទីបំផុតមានកម្លាំងរឹងប៉ឹងមិនងាយបំបាក់បានខុសពីការគិតទុកពីមុនមករបស់ពួកអាល្លឺម៉ង់ៗ ដោយមិនបានគិតដិតដល់ ខ្ញុំគិតថាអាល្លឺម៉ង់នឹងចាញ់សង្គ្រាមឆាប់ៗនេះ ហើយរូម៉ានីនឹងទទួលបានកម្មសិទ្ធិទៅលើទឹកដីរបស់ខ្លួនវិញៗ អ្វីៗគ្រប់យ៉ាង នឹងអាចវិលត្រឡប់មកជាធម្មតាវិញ ហើយខ្ញុំនឹងអាចទៅរៀននៅមហាវិទ្យាល័យៗ

នៅព្រឹកថ្ងៃបន្ទាប់ ខ្ញុំ បានដឹងច្បាស់អំពីការពិតៗ ប៉ូលីសបានមកផ្ទះរបស់ យើងឪពុកខ្ញុំបានចាក់សោផ្ទះហើយទុកកូនសោនៅក្នុងហោប៉ៅរបស់គាត់ បន្ទាប់មកយើងក៏ចាកចេញទៅហ្គេតូៗឥឡូវនេះពេលវេលា ដែលកាន់តែពិបាកបានចាប់ផ្តើមហើយៗប៉ុន្តែម្តងទៀតយើងត្រូវតែទម្លាប់ខ្លួនជាមួយនឹងពេលវេលានេះៗ ក្តីសង្ឃឹមថាសង្គ្រាមនឹងឆាប់រលត់ទៅគឺ

នៅតែមានបន្តជានិច្ច។

ជាថ្មីម្តងទៀត មិនទាន់បានបួនសប្តាហ៍ផងនៅពីរខែបន្ទាប់ពីអាល្លីម៉ង់ បានចូលឈ្លានពានយើងបានឮសំឡេងអ្នកគោះស្គរនៅកាច់ជ្រុងផ្លូវស្រែកថា «យកចិត្តទុកដាក់ស្តាប់! យកចិត្តទុកដាក់ស្តាប់! ជនជាតិជ្វីហ្វទាំងអស់ត្រូវតែរើចេញពីទីនេះ។ ពួកអ្នកអាចវេចអីវ៉ាន់យកតាមខ្លួន២០គីឡូក្រាមក្នុងម្នាក់ហើយថ្ងៃស្អែកត្រូវតែឈរនៅមុខរបងហ្គេតូដើម្បីត្រៀមខ្លួនចេញដំណើរ។» ទៅទីណា? គ្មានអ្នកណាដឹងទេ។ម្តាយរបស់ខ្ញុំពិតជាពិបាកចិត្តខ្លាំងណាស់។ «ពួកគេប្រាកដជាសម្លាប់យើងចោលជាក់ជាមិនខាន» ម្តាយរបស់ខ្ញុំនិយាយបណ្តើរយំបណ្តើរ។

ខ្ញុំ មិនអាចទទួលយកការចុះចាញ់របស់គាត់បានទេ ហើយក៏បានឆ្លើយតបនឹងគាត់ថា «ទេហេតុអ្វីបានជាពួកគេត្រូវធ្វើបែបនោះ។ យើងមិនបានធ្វើអ្វីខុសទេ។ យើងនឹងត្រូវបានគេបញ្ជូនទៅធ្វើការនៅតាមចម្ការ។ មនុស្សប្រុសត្រូវបញ្ជូនទៅសមរភូមិពីព្រោះនៅទីនោះគេត្រូវការកម្លាំងដើម្បីសាបព្រោះគ្រាប់ពូជមុនរដូវធ្លាក់ព្រិលមកដល់។» នៅពេលដែលឮបែបនេះម្តាយរបស់ខ្ញុំក៏រម្ងាប់អារម្មណ៍។ តើអ្នកនឹងយកអ្វីទៅតាមខ្លួនប្រសិនបើគេអនុញ្ញាតឲ្យអ្នកយកបានត្រឹមតែ២០គីឡូក្រាម? ម្តាយរបស់ខ្ញុំ ភាគច្រើនវេចខ្ចប់អាហារនិងយករបស់ណាដែលអាចរក្សាទុកបានយូរ។ យើងបានស្លៀកសម្លៀកបំពាក់ជាច្រើនជាន់និងពាក់ស្បែកជើងណាដែលរឹងមាំ។ ចំណែកខ្ញុំ បានរៀបចំកាបូបតូចមួយដែលមានខោស្លីបមួយឈុត សៀវភៅកំណត់ហេតុរបស់ខ្ញុំនិងសៀវភៅកំណាព្យដោយករវិមួយរូបដែលខ្ញុំចូលចិត្តមានឈ្មោះថាចូសែវអាទីលឡា។ យើងមិនបាននឹកស្មានទាល់តែសោះថាសូម្បីតែទ្រព្យសម្បត្តិ ចុងក្រោយរបស់យើងក៏ត្រូវបានគេដកហូតដែរ។ នៅព្រឹកថ្ងៃបន្ទាប់ យើងឈរនៅមុខរបងជាមួយអីវ៉ាន់របស់យើង។យើងត្រូវបានគេបង្គាប់ឲ្យឈរជា៥ជួរ ហើយបន្ទាប់មកធ្វើដំណើរតាមដងផ្លូវនៅក្នុងទីក្រុង ទៅកាន់ស្ថានីយរថភ្លើងដែលមានទូរថភ្លើងកំពុងរង់ចាំ។

នៅលើជញ្ជាំងម្ខាងនៃ ទូរថភ្លើងមានសរសេរពាក្យថា« សម្រាប់សេះ៨ ក្បាល» បន្ទាប់មកពួកយើងត្រូវបានគេរុញប្រជ្រៀតគ្នាចូលទៅក្នុងទូរថភ្លើង ដោយក្នុងមួយទូមានមនុស្សចំនួន១០០នាក់។ នៅខាងក្នុងទូរថភ្លើង មានសភាពណែនណ្ដឹះហើយងងឹតឈឹង។មានតែប្រហោងតូចមួយប៉ុណ្ណោះសម្រាប់ឲ្យពន្លឺ និងខ្យល់ចេញចូល។ យើងខំប្រឹងប្រជ្រៀតគ្នាប៉ុន្តែនៅតែគ្មានកន្លែងគ្រប់គ្រាន់ សម្រាប់ឲ្យអ្នកទាំងអស់គ្នាអង្គុយទេ។ នៅក្នុងទូរថភ្លើងមានធុងចំនួនពីរសម្រាប់ឲ្យយើងបត់ជើង និងមានធុងទឹកចំនួនពីរផ្សេងទៀត។ ទ្វារត្រូវបានរុញបិតជិតហើយចាក់សោពីក្រៅ បន្ទាប់មករថភ្លើងក៏បានចេញដំណើរ។ការធ្វើដំណើរបានចំណាយ អស់រយៈពេល បីថ្ងៃបីយប់នៅក្នុងស្ថានភាពដ៏គួរឲ្យខ្ពើមរអើម។ រថភ្លើងបានឈប់នៅតាមចំណតម្តងម្កាលហើយក្លិនស្អុយ និងការស្រែកទឹកស្ទើរតែមិនអាចធ្វើឱ្យយើងទ្រាំទ្របាន។យើងបានសុំអង្វរឲ្យជួយ ប៉ុន្តែការអង្វររបស់យើងគឺគ្មានប្រយោជន៍ទាល់តែសោះហើយស្ថានភាពបែបនេះបន្តរហូតដល់ថ្ងៃទី១៧ និងទី១៨ខែឧសភា។នៅពេលនោះគឺជាពេលដែលយើងបានទៅដល់អូសឈ្វិច។

## ហេតុអ្វីបានជាហ៊ីត្លែរស្អប់ជនជាតិជ្វីហ្វ?

ខ្ញុំបានចងចាំកំប្លែងដ៏គួរឲ្យស្អប់មួយ ដែលនិយាយតៗគ្នាក្នុងអំឡុងពេលសង្គ្រាម។ ចេកុបបានសួរដាណៀលថា« អ្នកណាជាអ្នកចាប់ផ្តើមសង្គ្រាម? » ហើយដាណៀលបានឆ្លើយតបទៅវិញថា «ជនជាតិជ្វីហ្វនិងអ្នកជិះកង់»។«ហេតុអ្វីបានជាអ្នកជិះកង់? » ចេកុបសួរ« ហេតុអ្វីបានជាជនជាតិជ្វីហ្វ? » ដាណៀលឆ្លើយតប។

ពេលធំដឹងក្តី ខ្ញុំបានចាប់ផ្តើមដឹងអំពីពិភពលោកដ៏ធំធេងដែលនៅក្រៅបន្ទប់តូចរបស់ខ្ញុំ។ ខ្ញុំដឹងថាក្មេងៗដទៃទៀតរស់នៅក្នុងជីវភាពផ្សេងពីខ្ញុំ។ មនុស្សទាំងអស់មិននិយាយភាសាដូចគ្នានោះទេ ហើយមនុស្សទាំងអស់នោះក៏មិនទៅវិហារជ្វីហ្វដូចខ្ញុំដែរ។ ខ្ញុំយល់អំពីការសន្ទនារបស់ឪពុកម្តាយខ្ញុំបានច្រើនហើយខ្ញុំ ក៏ចាប់ផ្តើមមានអារម្មណ៍ថាភ័យ

ខ្លាចៗ តើមានរឿងអ្វីបានកើតឡើង? ឪពុកម្តាយរបស់ខ្ញុំបានពិភាក្សាអំពីរឿងនយោបាយអំពីការ បោះឆ្នោតខាងមុខនេះ ថែមទាំងគ្រោះថ្នាក់ ដែលអាចនឹងកើតមានឡើងចំពោះយើង ដែលជាជនជាតិជ្វីហ្វប្រសិនបើ គណបក្សប្រឆាំងនឹងជនជាតិជ្វីហ្វឈ្នះឆ្នោតៗ នៅពេលនោះពួកសេរីកំពុងតែកាន់កាប់អំណាចនៅឡើយ ហើយខ្ញុំក៏មានមោទនភាពខ្លាំងដែលអ៊ំរបស់ខ្ញុំគឺជាសមាជិកម្នាក់របស់រដ្ឋសភាៗ ខ្ញុំ ក៏បានស្តាប់ពីការពិភាក្សាអំពីប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសមួយដែលនៅឆ្ងាយហើយបក្សដែលធ្វើបាប យាយីទៅលើជនជាតិជ្វីហ្វកំពុងតែកាន់អំណាចៗ «ហេតុអ្វី?» ខ្ញុំសួរៗ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំអំពីប្រវត្តិរបស់ក្រុមប្រឆាំងនឹងជនជាតិជ្វីហ្វៗ អំពីជំនឿរបស់មនុស្សនៅទីក្រុងអឺរទៅលើព្រះផ្សេងៗពីគ្នាកាលពីជំនាន់មុនៗ នៅម៉េស៊ូប៉ូតាមៀ មានក្រុមកុលសម្ព័ន្ធតូចមួយដែលដឹកនាំដោយបុរសម្នាក់ មានឈ្មោះថាថេរាដែលជាជាងសូនរូបព្រះៗប៉ុន្តែកូនប្រុសរបស់គាត់ ឈ្មោះអាប្រាហាមមិនជឿថារូបព្រះដែលសង់ពីដី ហើយគ្មានជីវិតនោះអាចនឹងគ្រប់គ្រងពិភពលោកបានទេៗ គាត់បានជឿជាក់ថាប្រាកដជាមានថាមពលខ្លាំងក្លាជាងនេះដែលមិនអាចមើលឃើញបានៗសាសនាថ្មីក៏បានករកើតឡើងដែលជឿទៅលើព្រះតែមួយគត់ហើយអាប្រាហាម គឺជាស្ថាបនិកៗសាសនានេះត្រូវបានគេដាក់ឈ្មោះថាសាសនាយូដា ហើយត្រូវបានផ្សព្វផ្សាយពាសពេញពិភពលោកៗ ប៉ុន្តែ មនុស្សមួយចំនួននៅក្នុងពិភពលោកមិនអាចទទួលស្គាល់សាសនានេះបាននោះទេៗ

បន្ទាប់ពី ការប្រសូតរបស់ ព្រះយេស៊ូ ជំនឿទៅលើព្រះថ្មីមួយទៀត បានចាប់ផ្តើមរីករាលដាលហើយត្រូវបានគេស្គាល់ថាជាសាសនាគ្រិស្តៗ ព្រះយេស៊ូផ្ទាល់ក៏ជាជនជាតិជ្វីហ្វដែលទ្រង់ គឺជាគ្រូបុព្វជិតម្នាក់ក្នុងចំណោមក្រុមជនជាតិជ្វីហ្វដ៏ទៃទៀតដែលបង្រៀន និងផ្សព្វផ្សាយពីច្បាប់របស់ជ្វីហ្វៗ មិនយូរមិនឆាប់មនុស្សជាច្រើនបានចាប់ផ្តើមជឿទៅលើព្រះយេស៊ូ ហើយកូនសិស្សរបស់គាត់ក៏បានចេញទៅពិភពលោកខាងក្រៅដើម្បីផ្លាស់ប្តូរអ្នកដែលមិនកាន់សាសនាឱ្យជឿទៅលើព្រះៗ អ្នកបង្រៀនសាសនាគ្រិស្តក៏បានព្យាយាមបញ្ចុះបញ្ចូលជនជាតិជ្វីហ្វឲ្យជឿទៅលើព្រះយេស៊ូ ប៉ុន្តែនៅពេលដែលជនជាតិជ្វីហ្វបដិសេធយ៉ាងម៉ឺងម៉ាត់ ពួកគេបែរជាត្រូវបានចោទប្រកាន់ថាបាន សម្លាប់ព្រះយេស៊ូទៅវិញៗ ការបៀតបៀនទៅលើជនជាតិជ្វីហ្វក៏បានកើតឡើងយ៉ាងខ្លាំងនៅក្នុងទម្រង់មួយដែលមានតែភាពស្អប់ខ្ពើមៗ

ការចោទប្រកាន់ដែលគ្មានភស្តុតាង ជាច្រើនបានរីករាលដាលហើយការតាមចាប់រកធ្មប់ ដែលជាជនជាតិជ្វីហ្វនៅតាមកន្លែងជាច្រើនបានក្លាយទៅជា រឿងសាមញ្ញមួយដែលកើតឡើងតៗគ្នាជាច្រើនសតវត្សរ៍ៗ ការចោទប្រកាន់ពីរនៅតែកើតមានឡើងរហូតមកទល់សព្វថ្ងៃ ទោះបីជាការពិតត្រូវបានបញ្ជាក់ជាច្រើនដងថាការចោទប្រកាន់នោះគ្មានភស្តុតាងពិតប្រាកដណាមួយក៏ដោយៗ

ការចោទប្រកាន់មួយបាននិយាយថា ជនជាតិជ្វីហ្វបានសម្លាប់ក្មេងតូចៗ ដើម្បីយកឈាមរបស់ពួកក្មេងៗទាំងនោះមកដុតនំបុ័ងសម្រាប់បុណ្យអ៊ីសស្ទ័ៗ ពាក្យចចាមអារ៉ាមនេះបានរីករាលដាលដំបូងនៅក្នុងមជ្ឈិមសម័យ នៅក្នុងភូមិមួយនៅប៉ែកខាងជើងនៃអឺរ៉ុបៗ នាថ្ងៃមួយ នៅដើមរដូវផ្ការីកក្មេងប្រុសសាសនាគ្រិស្តម្នាក់បានបាត់ខ្លួន ហើយអ្នកដុតនំបុ័ងជនជាតិជ្វីហ្វម្នាក់ ត្រូវបានទទួលរងការចោទប្រកាន់ថាបានសម្លាប់ក្មេងប្រុសម្នាក់នោះ ដើម្បីយកឈាមមកដុតនំបុ័ងអ៊ីសស្ទ័ៗសាក្សីក្លែងក្លាយជាច្រើន បានចេញមុខហើយអះអាងថាខ្លួនបានឃើញហេតុការណ៍នោះផ្ទាល់ៗ ការអះអាងនេះគឺគ្រប់គ្រាន់ក្នុងការធ្វើឱ្យអ្នកភូមិទាំងអស់ដាក់ដំបងតាមខ្លួននិងបង្កើតចលនាមួយដើម្បីសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វៗ

បន្ទាប់មកនៅពេល ដែលផ្ទាំងទឹកកកនៅលើទន្លេមួយនៅក្បែរភូមិបានរលាយ សាកសពរបស់ក្មេងប្រុសម្នាក់នោះបានអណ្តែតចេញមកប៉ុន្តែវាមិនអាចជួយអ្វីបានទេៗភូមិដទៃទៀតនៅតែមានការចោទប្រកាន់បែបនេះ នៅពេលណាដែលមានក្មេងស្លាប់ក្នុងភូមិៗ ការកាត់ក្តីលើកចុងក្រោយទៅលើហេតុការណ៍បែបនេះត្រូវបានធ្វើឡើងនៅប្រទេសហុងគ្រី

អំឡុងឆ្នាំ១៨៨៣។ ការចោទប្រកាន់គ្មានមូលដ្ឋានច្បាស់លាស់មួយទៀត គឺពិធីសាររបស់ក្រុមព្រឹទ្ធាចារ្យហ្សាយអ៊ុនដែលជារឿងប្រឌិតមានប្រភពចេញមកពីរាជវង្សត្សារនៃប្រទេសរុស្ស៊ី។ ការចោទប្រកាន់នេះគឺជារឿងប្រឌិតឡើងថាជនជាតិជ្វីហ្វបានកាន់អំណាច ជាអ្នកដឹកនាំពាសពេញពិភពលោក។ នៅក្នុងកិច្ចប្រជុំមួយ នៅចុងសតវត្សរ៍ទី១៩២ពួកគេត្រូវបានអះអាងថាបានរៀបចំផែនការលម្អិតមួយ ដើម្បីសម្រេចបាននូវផែនការគ្រួតត្រាពិភពលោក។ ហ៊ី ត្លែរបានចាត់ទុករឿងព្រេងនិទាននេះថាជាការពិត ដែលធ្វើឲ្យគាត់មានអារម្មណ៍ភ័យខ្លាចចំពោះ ជនជាតិជ្វីហ្វហើយក៏សម្តែងចេញនូវការស្អប់ខ្ពើម និងប្តេជ្ញាចិត្តក្នុងការសម្លាប់ផ្តាច់ពូជជនជាតិជ្វីហ្វ។

ភាពស្អប់ខ្ពើមរបស់ហ៊ីត្លែរចំពោះជនជាតិជ្វីហ្វគឺខ្លាំងក្លាណាស់រហូតដល់អ្នកអាចនិយាយបានថា ហ៊ី ត្លែរ មិនមែនធ្វើសង្គ្រាមប្រឆាំងនឹងពួកសម្ព័ន្ធមិត្តទេ ប៉ុន្តែគឺជាមួយនឹងជនជាតិជ្វីហ្វឯណោះទៅវិញ។ ទោះបីជាអាល្លឺម៉ង់ គ្មានរថភ្លើងគ្រប់គ្រាន់សម្រាប់ដឹកជញ្ជូនទាហានទៅកាន់ សមរភូមិយ៉ាងណាក៏ដោយក៏ហ៊ីត្លែរនៅតែខំប្រឹងប្រមែប្រមូលរទេះ ដើម្បីដឹកជនជាតិជ្វីហ្វទៅអូសឈ្វិចដែរ។

ប្រជាជនអាល្លឺម៉ង់ភាគច្រើន មិនមែនជាអ្នកប្រឆាំងនឹងជនជាតិជ្វីហ្វទេ។ ដូច្នេះហើយទើបបានជាមានតម្រូវការខ្លាំងក្លាមួយក្នុងការជំរុញឱ្យមានការប្រឆាំងនឹងជនជាតិជ្វីហ្វនៅក្នុងចំណោមប្រជាជនអាល្លឺម៉ង់ ចំណែកឯរដ្ឋមន្ត្រីឃោសនារបស់ណាហ្ស៊ី ដែលមានឈ្មោះថាហ្គូបេល ក៏មានភាពប៉ិនប្រសប់នឹងភារកិច្ចនេះដែរ។ខ្សែភាពយន្តសិល្បៈអក្សរសិល្ប៍ និងការអប់រំនិងអ្វីៗផ្សេងទៀត សុទ្ធសឹងតែបានបង្ហាញតាមរយៈគោលលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ។ ការប្រកាន់ពូជសាសន៍ត្រូវបានផ្លិតជាប់យ៉ាងមាំ នៅក្នុងគំនិតរបស់ជនជាតិអាល្លឺម៉ង់។ ក្មេងៗជនជាតិអាល្លឺម៉ង់ត្រូវបានគេបង្រៀនថាជនជាតិជ្វីហ្វមិនមែនជាមនុស្សទេ យើងត្រូវតែកំចាត់ចោលពួកគេទាំងអស់នោះ។ ជនជាតិជ្វីហ្វគឺជាសត្វល្អិតចង្រៃដែលត្រូវតែកំចាត់ចោលហើយជនជាតិជ្វីហ្វក៏ជាមេរោគមហារីកដែលកំពុងតែករកើតឡើង នៅលើរាងកាយស្អាតរបស់ចក្រភពអាល្លឺម៉ង់ ហើយមហារីកនេះត្រូវតែកម្ចាត់ចោល។ ចម្លើយយ៉ាងសាមញ្ញបំផុតសម្រាប់សំណួរខាងលើគឺហ៊ីត្លែរស្អប់ជនជាតិជ្វីហ្វដោយសារតែពួកគេគឺជាជ្វីហ្វ។

ជីវិតនៅក្នុងទីក្រុងតូចដ៏ស្ងប់ស្ងាត់មួយ នៅស៊ីហ្កេតមិនសូវមានព្រឹត្តិការណ៍សំខាន់ៗកើតឡើងទេ។ប្រជាជនចំនួន៣ម៉ឺននាក់ ដែលរស់នៅទីក្រុងនេះគឺសម្បូរទៅដោយជនជាតិភាគតិចផ្សេងៗគ្នា ហើយភាគច្រើនគឺជាជនជាតិជ្វីហ្វ។ នៅពេលដែលខ្ញុំគិតអំពីវាខ្ញុំបាននឹកឃើញអនុស្សាវរីយ៍ មួយចំនួនដែលអាចបង្ហាញឲ្យឃើញថាជីវិតពេលនោះមានលក្ខណៈបែបណា។

នៅពេលនោះខ្ញុំមានអាយុ៣ឆ្នាំ ហើយទើបតែចាប់ផ្តើមចូលរៀនថ្នាក់មត្តេយ្យសិក្សា។ពេលនោះខ្ញុំមានអារម្មណ៍ថាខ្លួនឯងធំហើយ។ ប៉ុន្មានថ្ងៃបន្ទាប់មកខ្ញុំបានទាមទារមិនឲ្យមាននរណាទៅទទួលខ្ញុំពីសាលារៀនទេ ពីព្រោះខ្ញុំចង់ដើរមកផ្ទះដោយខ្លួនឯង។ ម្តាយរបស់ខ្ញុំមិនចង់យល់ព្រមទេប៉ុន្តែចុងក្រោយភាពចចេសរឹងរូសរបស់ខ្ញុំក៏បានឈ្នះ។ នៅពេលនោះគឺម៉ោង១២ថ្ងៃត្រង់ហើយក្មេងតូចៗ មួយក្រុមចេញទៅខាងក្រៅរបងសាលាដើម្បីចេញទៅផ្ទះហើយ មានខ្ញុំនៅកណ្តាលគេៗអ្នកខ្លះទៅស្តាំ ឯអ្នកខ្លះទៀតទៅឆ្វេង។ខ្ញុំរវល់តែយកចិត្តទុកដាក់ស្តាប់ការសន្ទនារបស់ពួកម៉ាក ដែលមានអាយុច្រើនជាងក៏មិនបាននឹកគិតថានឹងទៅផ្ទះតាមផ្លូវណា។ដោយមិនបានសម្លឹងមើលជុំវិញខ្លួនខ្ញុំក៏បានដើរ តាមពួកម៉ាករបស់ខ្ញុំទៅខាងឆ្វេងដែរ។

នៅពេលដែលយើងកំពុងតែដើរ ខ្ញុំចាប់អារម្មណ៍ថាមិត្តរួមថ្នាក់របស់ ខ្ញុំចាប់ផ្តើមដើរទៅផ្លូវផ្សេងៗ ពីគ្នារហូតសល់តែខ្ញុំនឹងពួកម៉ាករបស់ខ្ញុំម្នាក់ទៀតដែលកំពុងតែនិយាយគ្នា។ ប៉ុន្តែភ្លាមៗ នោះពាក្យដែលត្រូវនិយាយទាំងប៉ុន្មានត្រូវបានគាំងជាប់នៅពេល ដែលពួកម៉ាក របស់ខ្ញុំបានឈប់នៅមុខរបងផ្ទះមួយ។ខ្ញុំនៅតែម្នាក់ឯងទេ។ ពេលនោះហើយគឺជាពេលដែលខ្ញុំចាប់ផ្តើមមើលជុំវិញខ្លួន ហើយមិនដឹងថាខ្លួនឯង

នៅទីណានោះទេ។ខ្ញុំមានអារម្មណ៍ភ័យខ្លាច យ៉ាងខ្លាំងពេលដែលដឹងថាខ្លួនឯងកំពុងតែវង្វេងផ្លូវ។ ខ្ញុំក៏ចាប់ផ្តើមយំយ៉ាងខ្លាំង។មានមនុស្សស្រីម្នាក់ បានអើតចេញមកក្រៅបង្អួចហើយសួរថាហេតុអ្វីបានជាខ្ញុំយំ។ ឆ្លើយប្រាប់គាត់ថាខ្ញុំមិនស្គាល់ផ្លូវទៅផ្ទះរបស់ខ្ញុំវិញនោះទេ។

«តើឯងឈ្មោះអ្វី?» គាត់សួរ

«ហេឌី»ខ្ញុំឆ្លើយ។

«តើឯងជាកូនរបស់អ្នកណា?»

«ឪពុករបស់ខ្ញុំ»

«តើឯងរស់នៅឯណា?»

«នៅក្នុងផ្ទះដែលមានរបងពណ៌ក្រហម»។

«កុំយំអីហេឌី»គាត់បាននិយាយបន្ត«ខ្ញុំនឹងជូនឯងទៅផ្ទះ»។ ទីក្រុងដែលខ្ញុំរស់នៅមានទំហំតូចល្មមដែលអាចធ្វើឲ្យគាត់ចំណាំខ្ញុំបាន ពីព្រោះខ្ញុំមានមុខមាត់ដូចឪពុករបស់ខ្ញុំ។

មនុស្សជាច្រើននៅស៊ីហ្គេតស្គាល់គ្នា ទោះបីជាពួកគេមិនដែលមានទំនាក់ទំនងជាមួយគ្នាក៏ដោយ។ ជីវិតរស់នៅក៏ទៅតាមរបៀបស្រដៀងគ្នារវាងប្រជាជននៅក្នុងក្រុមផ្សេងៗពីគ្នា ហើយការបែងចែកជាក្រុមគឺសំដៅទៅលើវណ្ណៈជាជាងតាមជាតិសាសន៍។ មានអ្នកដែលក្រខ្លាំងនិងអ្នកដែលមានជាង។ ក្រុមគ្រួសាររបស់យើងគឺនៅក្នុងក្រុមដែលជាអ្នកមានជាង។ អ្នកទាំងអស់គ្នាដែលនៅក្នុងក្រុមនេះមានអ្នកជំនួយតាមផ្ទះឬសព្វថ្ងៃនេះគេហៅថាអ្នកបម្រើ។

អាន់ណាអ្នកបម្រើរបស់យើង ក្រោកពីដំណេកនៅម៉ោង៦ ព្រឹកហើយអុជភ្លើងចង្ក្រានដើម្បីកុំឱ្យយើងភ្ញាក់ពីគេងនៅក្នុងបន្ទប់ដែលត្រជាក់ខ្លាំង។ អាន់ណា ត្រូវលួងលោមយើងឱ្យភ្ញាក់ពីគេងរាល់ព្រឹកពីព្រោះតែយើងរងារហើយមិនចង់ក្រោកចេញពីគ្រែ បន្ទាប់មក គាត់ស្លៀកសម្លៀកបំពាក់ឲ្យពួកយើងបញ្ចុកអាហារពេលព្រឹករួចមក ទើបនាំយើងទៅសាលារៀន។បន្ទាប់ពីនេះទើបឪពុកម្តាយ របស់យើងក្រោកពីដំណេក។បន្ទាប់ពីអាហារពេលព្រឹករួចឪពុករបស់ខ្ញុំទៅធ្វើការរីឯម្តាយរបស់ខ្ញុំទៅផ្សារដើម្បីទិញអីវ៉ាន់។

## តើនៅពេលណាដែលអ្នកដឹងថា គ្រួសាររបស់អ្នកស្ថិតនៅក្នុងគ្រោះថ្នាក់?

ខ្ញុំមិនអាចចាំបានទេថា នៅពេលណាដែល ខ្ញុំដឹងថាគ្រួសាររបស់ខ្ញុំមានគ្រោះថ្នាក់។ ប៉ុន្តែ នៅពេលដែលខ្ញុំដឹងខ្ញុំដឹងថានោះគឺជាគ្រោះថ្នាក់ ដែលជនជាតិជ្វីហ្វទាំងអស់ជួបប្រទះមិនមែនមានតែគ្រួសាររបស់ខ្ញុំទេ។ គំនិតបែបនេះប្រាកដជាមាននៅក្នុងខួរក្បាលរបស់ខ្ញុំ យូរមកហើយមុនពេលដែលវាចាប់ផ្តើមពញ្ញាក់ស្មារតីរបស់ខ្ញុំនៅពេលវ័យជំទង់។

វាចាប់ផ្តើម នៅពេលដែលខ្ញុំមានអាយុ១៨ឆ្នាំហើយបានស្រឡាញ់បុរសម្នាក់ ដែលធ្វើការនៅក្នុងការិយាល័យប្រៃសណីយ៍មួយ។ ពាក្យចចាមអារ៉ាមអំពីសង្គ្រាមបានផ្សព្វផ្សាយហើយសាលារៀន បានបន្ទាត់បង្រៀនមនុស្សវ័យក្មេងឱ្យចេះជួយគ្នានៅពេលណាដែលជម្លោះផ្ទុះឡើង។ យើងត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមុខជំនាញ ដែលយើងចង់រៀន។ អ្នកខ្លះជ្រើសរើសយកមន្ទីរពេទ្យដើម្បីរៀនធ្វើជាគិលានុបដ្ឋាយិកា រីឯខ្លះទៀតជ្រើសរើសនគរបាល ចំណែកឯខ្ញុំជ្រើសយកការិយាល័យប្រៃសណីយ៍។

យើងមានគ្នា៦នាក់ដែលដឹកនាំដោយគ្រូសិល្បៈបានដើរចូលទៅក្នុងការិយាល័យប្រៃសណីយ៍។ ខ្ញុំសប្បាយចិត្តនិងរំភើបយ៉ាងខ្លាំង។ ខ្ញុំនឹងបានជួបបុរសដែលខ្ញុំស្រលាញ់ ហើយព្រមទាំងអាចរៀនអំពីលេខកូដសម្ងាត់ម៉ាសដែលខ្ញុំចូលចិត្ត។ យើងត្រូវបានប្រធានប្រៃសណីយ៍ផ្តល់ការស្វាគមន៍យ៉ាងអធិកអធម បន្ទាប់មក គាត់បានពន្យល់យើងអំពីភាពមិនច្បាស់លាស់របស់ស្ថានភាពនយោបាយ និងសារសំខាន់របស់សេវាប្រៃសណីយ៍នៅក្នុងពេលនេះ។ គាត់ក៏បានរៀបរាប់អំពីកិច្ចការដែលបានធ្វើឡើងនៅការិយាល័យប្រៃសណីយ៍ ........ មកដល់ទីនេះគាត់បានឈប់និយាយ ហើយសម្លឹងជុំវិញបន្ទាប់មកក៏សួរថា «ខ្ញុំចាត់ទុកថាអ្នកនៅទីនេះទាំងអស់គឺជាជនជាតិរូម៉ានី?»គ្រូបានមើលមកខ្ញុំ ហើយឆ្លើយយ៉ាងស្ទាក់ស្ទើរថា «អត់ទេមិនមែនទាំងអស់គ្នាទេ»។

ប្រធានប្រៃសណីយ៍បានដាក់ក្រដាសនៅក្នុងដៃគាត់

ចុះហើយនិយាយថា «ប្រសិនបើបែបនេះយើងមិនអាចបន្តបានទៀតទេ។» យើងទាំងអស់គ្នាត្រូវត្រឡប់ទៅផ្ទះវិញ។ ខ្ញុំត្រឡប់មកផ្ទះវិញហើយយំយ៉ាងខ្លាំង។ម្ដាយរបស់ខ្ញុំគាត់ខ្លាចណាស់គាត់គិតថា រឿងអាក្រក់បានកើតឡើងមកលើរូបខ្ញុំ។ «តើមានរឿងអ្វីកើតឡើង?» គាត់សួរហើយសួរទៀត។ ខ្ញុំបានត្រឹមតែយំ។ ចុងក្រោយខ្ញុំក៏ប្រាប់គាត់។ ខ្ញុំពិតជាខឹងនិងអាម៉ាស់ខ្លាំងណាស់។ ខ្ញុំចង់ឱ្យម្ដាយរបស់ខ្ញុំសន្យាថាយើងនឹងចាកចេញពីប្រទេសមួយនេះ។ ខ្ញុំមិនអាចរស់នៅក្នុងកន្លែងដែលមើលងាយខ្ញុំហើយចាត់ទុកខ្ញុំ ជាអនុប្រជាជននោះទេ។ ទន្ទឹមនឹងនោះដែរឪពុករបស់ខ្ញុំបានមកផ្ទះដើម្បីពិសាអាហារថ្ងៃត្រង់ហើយគាត់ទាំងពីរ ក៏ព្យាយាមលួងលោមឲ្យខ្ញុំផ្លាស់ប្ដូរចិត្ត។ ឪពុកម្ដាយរបស់ខ្ញុំបានព្យាយាមពន្យល់ថាយើងមិនមានកន្លែងដែលត្រូវទៅទេ ហើយការប្រឆាំងនឹងជនជាតិជ្វីហ្វកើតមានឡើងគ្រប់កន្លែងទាំងអស់ នៅក្នុងពិភពលោកដរាបណាយើងគ្មានប្រទេសដែលជារបស់យើង។ គ្មានជម្រើសនោះទេយើងត្រូវតែសម្របខ្លួន។ ខ្ញុំ មិនចង់សម្របខ្លួនទេហើយក៏មិនចង់ទទួលស្គាល់ហេតុការណ៍ទាំងអស់នេះដែរ ប៉ុន្តែចុងក្រោយខ្ញុំបានរម្ងាប់អារម្មណ៍របស់ខ្លួនឯង។ នេះគឺប្រហែលជាការភ្ញាក់ខ្លួនដំបូងរបស់ខ្ញុំ។

ពេលវេលាបានកន្លងផុតទៅ ការគំរាមកំហែងក៏កាន់តែខិតជិតចូលមកដល់។ ខ្ញុំមិនអាចចងចាំអំពីអារម្មណ៍ភ័យខ្លាចបានទេ។ អ្វីៗប្រៀបបានដូចជាអារម្មណ៍មួយដែលពិបាកនឹងពន្យល់ដូចជាសម្ពាធមួយនៅក្នុងដើមទ្រូងរបស់ខ្ញុំពេលខ្លះវាខ្លាំងឯពេលខ្លះទៀត វាខ្សោយប៉ុន្តែវាមិនដែលបាត់ទៅណាទេ។ មនុស្សទូទៅមិនដែលចង់ជឿទេថារឿងមិនល្អអាចនឹងកើតឡើងមកលើខ្លួន។ ឯខ្ញុំចង់ជឿទៅលើពាក្យរបស់កងការពារណាហ្ស៊ី ដែលបានប្រាប់ឪពុករបស់ខ្ញុំថាអ្វីៗដែលបានឮអំពីការធ្វើបាបយាយីទៅលើជនជាតិជ្វីហ្វ គឺគ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុណ្ណោះជនជាតិអាល្លឺម៉ង់គឺជាពលរដ្ឋដែលមានអរិយធម៌ខ្ពង់ខ្ពស់។

ពេលខ្លះខ្ញុំគិតអំពីអ្វីដែល ម្ដាយរបស់ខ្ញុំបាននិយាយអំពីការសម្របខ្លួនហើយ តើវាមានភាពងាយស្រួលយ៉ាងណា។ខ្ញុំគ្មានថ្ងៃអាចសម្របខ្លួនបានទេ ខ្ញុំបាននិយាយបែបនេះ ប៉ុន្តែនៅពេលដែលខ្ញុំ ត្រឡប់មកមើលអ្វីដែលបានកើតឡើងម្ដងទៀត ការសម្របខ្លួនគឺជាអ្វីដែលខ្ញុំបានធ្វើ។ ឆន្ទៈរបស់មនុស្ស ដើម្បីរស់មានភាពខ្លាំងក្លាណាស់ដែលមិនងាយនឹងចុះចាញ់ លុះត្រាណាតែមានអារម្មណ៍ថាមានចុងកំបិតនៅនឹងបំពង់ក។ មកដល់ពេលនេះ គេប្រហែលជាលែងអើពើហើយក៏គិតថា នេះគឺជាអ្វីដែលខ្ញុំបានគិតនៅពេលដែលខ្ញុំទៅដល់អូសឈ្វិចហើយមានអ្នកជាប់ទោសបុរសម្នាក់បានប្រាប់ខ្ញុំថាយើងបានចូលមកដល់ជំរំសម្លាប់។ ដូចនេះមានន័យថា «មានតែសេចក្ដីស្លាប់ហើយមែនទេ ដែលកំពុងតែរង់ចាំ? បើដូច្នេះឲ្យវាឆាប់ចប់ទៅ»។ នៅពេលដែលខ្ញុំត្រូវបានគេបំបែកចេញពីម្ដាយរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាធូរចិត្ត។ ខ្ញុំដឹងថាក្មេងៗនឹងមិនត្រូវបានគេសម្លាប់ទេ។ ប៉ុន្តែនៅពេលនោះដែរខ្ញុំក៏មានទុក្ខព្រួយយ៉ាងខ្លាំង «តើនឹងមានរឿងអ្វីកើតឡើងចំពោះម្ដាយរបស់ខ្ញុំ?» មកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែមិនហ៊ានសន្និដ្ឋានការគិតមួយនោះទេ។ ភាពអយុត្តិធម៌ ត្រូវតែលុបបំបាត់។នៅអាល្លឺម៉ង់ប្រតិកម្មតបទៅនឹង អំពើអយុត្តិធម៌គួរតែចាប់ផ្ដើមមានតាំងពីដើមឆ្នាំ១៩៣០មកម្ល៉េះ។ ទើបតែចាប់ផ្ដើមមានបន្ទាប់ពីអ្វីៗគ្រប់យ៉ាងបានកើតឡើងគឺហួសពេលទៅហើយ។

## «តើប្រជាជនអាល្លឺម៉ង់ទាំងអស់គាំទ្រហ៊ីត្លែរបានដោយរបៀបណា?»

ការប្រកាន់ជាតិសាសន៍ ដែលបណ្ដាលឲ្យមានការសម្លាប់រង្គាលនេះមានប្រភពយូរណាស់មកហើយ។ វាគឺអំពីការបណ្ដុំរបស់មនុស្សដែលមាន ជាតិសាសន៍ដូចគ្នាភាពលោភលន់និងភាពភ័យខ្លាច។ ទាំងអស់នេះគឺជាអ្វីដែលហ៊ីត្លែរបានយកមកប្រើជាយុទ្ធសាស្ត្រ ដើម្បីជ្រើសរើសសមាជិកថ្មីសម្រាប់បក្សរបស់ខ្លួន។ សុន្ទរកថាដ៏រំជើបរំជួលរបស់ហ៊ីត្លែរបានអំពាវនាវឲ្យមានសាមគ្គីភាពគ្នា រវាងសាសន៍អាល្លឺម៉ង់ដ៏អស្ចារ្យការស្ដារឡើងវិញ នូវទឹកដីដែលបានបាត់បង់ហើយ

និងភាពភ័យខ្លាចចំពោះផែនការ របស់ជនជាតិជ្វីហ្វ ក្នុងការ
គ្រប់គ្រងពិភពលោក ដែលរាប់បញ្ចូលទាំងមូលធននិយម
និងកុម្មុយនីស្ត។ នៅពេលនោះប្រជាជនអាល្លឺម៉ង់មិនសប្បា
យចិត្តជាមួយនឹងស្ថានភាពប្រទេសរបស់ខ្លួន ដែលមានអ្នក
នយោបាយទន់ខ្សោយនិងអត្រា អ្នកអត់ការងារធ្វើខ្ពស់នោះ
ទេ។ហ៊ីត្លែរបានប្រើប្រាស់អារម្មណ៍ ដែលត្រូវបានគេក្បត់រប
ស់ជនជាតិអាល្លឺម៉ង់នៅចុងបញ្ចប់សង្គ្រាមលោកលើកទី១ភា
ពអាម៉ាស់របស់បូរណភាពទឹកដី ហើយនិងការរងទុក្ខរបស់
ប្រជាជនមកទាមទារឱ្យមានសំណង។ ហ៊ី ត្លែរ អំពាវនាវឲ្យ
មានភាពរួបរួមជាតិព្រមទាំងសន្យានំប៉័ង និងការងារធ្វើ។

នៅដើមឆ្នាំ១៩៣០ណាហ្ស៊ី មិនសូវមានអ្នកគាំទ្រ
ច្រើនទេ។ ប៉ុន្តែដោយសារតែភាពអង់អាចនិងរបៀបនៃការនិ
យាយស្ដីដ៏ល្អរបស់ហ៊ីត្លែរ មនុស្សជាច្រើនចាប់ផ្តើមចូលរួម
គាំទ្របក្សរបស់គាត់ និងមានគ្រប់ស្រទាប់វណ្ណៈទាំងអស់ដូច
ជាអ្នកធ្វើជំនួញនិងអាជីវកម្មធំៗ ដែលគិតថាខ្លួននឹងអាចទទួ
លបានផលចំណេញពី គោលនយោបាយរបស់ហ៊ីត្លែរនាយ
ទាហានដែលចូលចិត្តគំនិតប្រកាន់ ជាតិសាសន៍និយមរបស់
ហ៊ីត្លែរមនុស្សសាមញ្ញ ដែលធុញទ្រាន់នឹងភាពក្រីក្រ ហើយ
និងមនុស្សស្រីដែលលង់នឹងភាពទាក់ទាញរបស់ហ៊ីត្លែរ។ ហ៊ី
ត្លែរមានកម្លាំងមួយដែលអាចសណ្តំមនុស្សស្រី ឲ្យក្លាយទៅ
ជាអ្នកដែលគាំទ្រគាត់យ៉ាងស្មោះស្ម័គ្រ។ ត្រង់ចំណុចនេះគឺ
ហាក់បីដូចជាចម្លែកខ្លាំងណាស់ពីព្រោះ ចំពោះហ៊ីត្លែរតួនាទី
របស់ស្ត្រីគឺអាចសង្ខេបបានដោយ ត្រឹមតែអក្សរខេ(K)ខេ(k)
ខេ(K)ឬភាសាអាល្លឺម៉ង់ ឃីនដឺ(Kinder),ឃូហ្សេ(Kuche),
ឃីហ្សេ(Kircheដែលមានន័យថាកុមារចង្ក្រានបាយវិហារ។

ហ៊ី ត្លែរ មានអ្នកជំនាញជាច្រើនចាំជួយគាត់។ មុខ
សញ្ញារបស់ពួកគេគឺមនុស្សវ័យក្មេង និងការបង្កើតគម្រោង
ឃោសនានោគមន៍វិជ្ជា ដ៏មានឥទ្ធិពលតាមរយៈខ្សែភាពយ
ន្តអក្សរសិល្ប៍និងសិល្បៈ។ ជនជាតិជ្វីហ្វ ត្រូវបានចាត់ទុកថា
គឺជាសត្វល្អិតចង្រៃ។ ការឃោសនាប្រឆាំងនឹងជនជាតិជ្វីហ្វ
គឺសំដៅទៅលើគ្រប់ស្រទាប់អាយុ ទាំងអស់របស់ប្រជាជន
អាល្លឺម៉ង់។ការចាប់ផ្តើមដំបូង គឺសំដៅលើកុមារតូចៗបន្ទាប់
មកតាមរយៈសៀវភៅនៅសាលារៀន និងតាមអក្សរសិល្ប៍
និងភាពយន្តរបស់មនុស្សពេញវ័យ។ រហូតមកទល់សព្វថ្ងៃ
នេះភាពយន្តរបស់លេនីរៀហ្វេនស្តាល់“Triumphofthewill
” នៅតែជាគំរូដែលមានប្រសិទ្ធភាពសម្រាប់ការឃោសនាម
នោគមន៍វិជ្ជា។

នៅក្នុងសៀវភៅសិក្សា មានការផ្សព្វផ្សាយឃោស
នាមនោគមន៍វិជ្ជា នៅតាមគ្រប់មុខវិជ្ជាទាំងអស់។ ឧទាហរណ៍
លំហាត់គណិតវិទ្យា នៅក្នុងសៀវភៅសិស្សវិទ្យាល័យដែល
បានបោះពុម្ពក្នុងឆ្នាំ១៩៣៥ មួយមានសំណួរថា«តើមានប្រា
ក់កម្ចីរបស់រដ្ឋប៉ុន្មាន ដែលអាចផ្តល់ឱ្យអ្នកដែលទើបតែរៀប
ការបើប្រៀបធៀបទៅនឹងប្រាក់ដែលរដ្ឋាភិបាលចំណាយទៅ
លើជនពិការខក្រិដ្ឋជន និងមនុស្សវិកលចរិត?» ណាហ្ស៊ីបាន
ផ្តោតសំខាន់ខ្លាំងទៅលើការអប់រំកាយ របស់មនុស្សវ័យក្មេង
ដែលត្រូវបានពង្រឹងទាំងផ្លូវកាយ និងសតិអារម្មណ៍។ ពួកគេ
ត្រូវបានជ្រើសរើសឲ្យចូលក្នុងហ៊ីត្លែរ ជូយេន់ឬយុវជនរបស់
នារីក៏មានក្រុមសម្រាប់ខ្លួនដែរ គឺមានឈ្មោះថាសម្ព័ន្ធនៃក្មេង
ស្រីអាល្លឺម៉ង់ ដែលនៅក្នុងក្រុមនេះនារីត្រូវបានបង្ហាត់បង្រៀ
នឲ្យក្លាយទៅជា ប្រជាពលរដ្ឋគំរូនិងក្លាយទៅជាមាតារបស់
កុមារ ជាច្រើននាក់នាពេលអនាគត។ ហ៊ីត្លែរដែលជីវិតនៅក្នុ
ងជំរំនិងសាមគ្គីភាព ប្រែក្លាយឲ្យអ្នកទាំងនោះក្លាយទៅជាអ្ន
កបម្រើដ៏ស្មោះត្រង់។

នារីក៏មានក្រុមសម្រាប់ខ្លួនដែរ គឺមានឈ្មោះថាសម្ព័
ន្ធនៃក្មេងស្រីអាល្លឺម៉ង់ ដែលនៅក្នុងក្រុមនេះនារីត្រូវបានបង្ហា
ត់បង្រៀនឲ្យក្លាយទៅជាប្រជាពលរដ្ឋគំរូ និងក្លាយទៅជាមា
តារបស់កុមារជាច្រើននាក់នាពេលអនាគត។

ទោះបីជាមានការកើនឡើងនៃអ្នកគាំទ្រក៏ដោយក៏ប្រ
ជាជនមួយចំនួនធំ មិនមែនជាអ្នកដែលប្រឆាំងនឹងជនជាតិជ្វី
ហ្វទេ និងមួយចំនួនតូចគឺដោយសារតែជឿលើការឃោសនា
មនោគមន៍វិជ្ជា។ (**នៅមានត**)

***ហេខី ហ្សាយ***

# ព្រះជីវប្រវត្តិរបស់សម្តេចរាជបុត្រី ព្រះរាម នរោត្តម បុប្ផាទេវី ក្នុងសៀវភៅ «រាជវង្សានុវង្សនៃប្រទេសកម្ពុជា»

យោងតាមសៀវភៅ ដែលមានចំណងជើងថា «រាជវង្សានុវង្សនៃ ប្រទេសកម្ពុជា»ដែលសរសេរឡើងដោយឯកអគ្គរាជទូត បណ្ឌិត ហូលីយ៉ូ ដែលជ្រេស (Julio A. Jedres) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់សម្តេច ព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋដែលមានកម្រាស់ប្រមាណជាង៣០០ទំព័រ ជាភាសាអង់គ្លេស និងត្រូវបានបកប្រែមកជាភាសាខ្មែរ បានសរសេររៀបរាប់ពីព្រះជីវប្រវត្តិរបស់សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី ថា ៖

«សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវីប្រសូតិនៅថ្ងៃទី៨ខែមករា ឆ្នាំ១៩៤៣ ក្នុងរាជធានីភ្នំពេញ។ សម្តេចព្រះរាមគឺជាព្រះរាជបុត្រីព្រះបាទនរោត្តម សីហនុ និងអ្នក



ការសម្តែងរបាំព្រះរាជទ្រព្យនៃប្រទេសកម្ពុជាសម្រាប់ប្រធានប្រមុខរដ្ឋបរទេសនៅព្រះទីនាំងច័ន្ទឆាយានៃព្រះបរមរាជវាំងឆ្នាំ១៩៦០

ម្នាងផាត់កាញ៉ុល។ទ្រង់បានបញ្ចប់ការសិក្សា នៅវិទ្យាល័យព្រះនរោត្តម ស្ថិតក្នុងរាជធានីភ្នំពេញ។ ក្នុងនាមជាបុត្រីវ័យក្មេងទ្រង់ត្រូវបានជ្រើសរើស ដោយព្រះឯយ្យកោ របស់ទ្រង់ព្រះមហាក្សត្រិយានីស៊ីសុវត្ថិកុសមៈ ហើយព្រះរាមនរោត្តម បុប្ផាទេវីគឺជាអ្នកសម្តែងរបាំដំបូង នៃជីវិតរបស់ទ្រង់នៅព្រះជន្ម១៥ព្រះវស្សា។ ទ្រង់មានភាពល្បីល្បាញដោយសាររបាំព្រះរាជទ្រព្យ។ ទ្រង់បានសម្តែងរបាំជាច្រើន និងទទួលបានជោគជ័យដ៏អស្ចារ្យនាពេលបន្តបន្ទាប់មកទៀត ទ្រង់ទទួលបានងារជាតួឯកខាងរបាំនៅព្រះជន្ម ១៨ព្រះវស្សា។ ព្រះអង្គម្ចាស់វ័យក្មេងស្ថិតនៅក្នុងសម្លៀកបំពាក់សូត្រ និងរតនភណ្ឌដ៏អស្ចារ្យដោយបានសម្តែងនៅលើព្រះពន្លាបើកចំហរជាប់ជញ្ជាំងព្រះបរមរាជវាំងអមដំណើរដោយ ក្រុមរបាំព្រះរាជវាំង«ពិណពាទ្យ»វង់ភ្លេងគងស្គរ ស៊ីឡូហ្វូនស្នែង និងឧបករណ៍ខ្សែតន្ត្រី»។



ព្រះរាម នរោត្តម បុប្ផាទេវី

### របាំអប្សរា

សម្តេចព្រះរាម នរោត្តម បុប្ផាទេវី គឺជាតួរបាំឯកនៃផ្នែករបាំអប្សរាដែលរបាំនេះមានវត្តមានចាប់តាំងពីសតវត្សរ៍



ព្រះរាម នរោត្តម បុប្ផាទេវី ក្នុងសំលៀកបំពាក់របាំអប្សរា

ទីមកម្ល៉េះ។ ក្បាច់រាំដ៏សែនសមរម្យ របស់តួរបាំអប្សរាដែលត្រូវបានតែងលម្អរដោយម្កុដធ្វើពីមាស និងសម្លៀកបំពាក់ធ្វើពីសរសៃសូត្រត្រូវបាន ឆ្លាក់ជាច្រើនកន្លែងតាមជញ្ជាំងប្រាសាទអង្គរវត្ត។ ការសន្និដ្ឋានបានបង្ហាញថាតួរបាំអប្សរាមាន

រហូតដល់៣០០០រូប ក្នុងសតវត្សរ៍ទី១២នៃរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧។ ក្រោយមកសម្តេចព្រះរាម នរោត្តមបុប្ផាទេវីបានធ្វើដំណើរទៅកាន់ពិភពលោកក្នុងនាមជា «អប្សរាពណ៌ស»ឬជាតួរបាំរបស់កម្ពុជាដ៏ឆ្នើមប្រកបដោយកាយវិការដ៏ក្មៀវក្លាល្អឆើត គួរឲ្យចង់គយគន់នៃរបាំដែលមានអាយុកាល ២០០០ឆ្នាំ ជាមួយនឹងការបង្កប់នូវអត្ថន័យដ៏ជ្រាលជ្រៅ។ ដោយមានការទទួលបន្ទុក សម្រាប់ការរស់ឡើងវិញសាជាថ្មីនៃរបាំអប្សរា សម្តេចព្រះរាមនរោត្តម បុប្ផាទេវីគឺជានិមិត្តរូបនៃរបាំតន្ត្រីខ្មែរ ដែលបាត់បង់ចាប់តាំងពីសតវត្សរ៍ទី១៥ ក្នុងពេល ដែលភាពរុងរឿងនៃសម័យអង្គរត្រូវបានធ្លាក់ចុះ ជាមួយនឹងឥទ្ធិពល នៃប្រទេសអាស៊ីអាគ្នេយ៍មកលើវប្បធម៌ខ្មែរ។ របាំអប្សរាត្រូវបានស្តារឡើងវិញនៅឆ្នាំ១៩៦២ដោយម្ចាស់ក្សត្រិយានីស៊ីសុវត្ថិកុសុមៈ ដែលជាព្រះឯយ្យកោរបស់សម្តេចរាជបុត្រី ព្រះរាមនរោត្តម បុប្ផាទេវីបានរៀបចំសម្តែងក្នុងព្រឹត្តិការណ៍មួយក្នុងឆ្នាំ១ ៩៦ ៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឧត្តមសេនីយ៍ ហ្សរាល ដឺហ្គោលនៅឯរោងមហោស្រប អូប៉េរ៉ាដឺប៉ារីស នៅក្នុងប្រទេសបារាំងហើយតួសម្តែងអប្សរាពណ៌សសម្តែង ដោយព្រះរាមបុប្ផាទេវីដែលមានព្រះជន្ម២១ ព្រះវស្សា។ ស្ថិតក្នុងសម្លៀកបំពាក់ដែលទើបតែកែច្នៃថ្មីរបស់ម្ចាស់ក្សត្រិ យានី កុសុមៈ ដែលចម្លងចេញពីចម្លាក់នៅតាមប្រាសាទអង្គរវត្ត។ ដោយសារតែចង្វាក់រាំដ៏សែនល្អរបស់នារីអប្សរាធ្វើឲ្យទស្សនិកជន ដែលបានចូលទស្សនា



សម្តេចព្រះរាម បុប្ផា ទេវី បង្ហាត់របាំព្រះរាជទ្រព្យមុនការសម្តែង២០១៧

ស្ទើចសរសើរយ៉ាងខ្លាំង។ ការបង្កើតឡើង ដំបូងនៃក្បាច់រាំ បានផ្តល់ដល់ទស្សនិកជន នូវអត្ថន័យនៃនិរន្តរភាពនាទសវត្សរ៍ឆ្នាំ១៩៦០ជាមួយនឹងការរាំនៃការធ្វើបច្ចុប្បន្នភាពរួមផ្សំជាមួយកេរដំណែលរាប់ពាន់ឆ្នាំកន្លងមក។ចាប់ពីពេលនោះមក របាំអប្សរាបានក្លាយជានិមិត្តរូបនៃវប្បធម៌ខ្មែរ និងត្រូវបានសម្តែងក្នុងប្រទេសកម្ពុជាហើយបានជួយផ្សព្វផ្សាយ ឲ្យប្រជាជនកម្ពុជាទៅកាន់ពិភពលោកខាងក្រៅ។ តាមរយៈការស្តារឡើងវិញនៃរបាំមួយនេះម្ចាស់ ក្សត្រិយានីកុសុមៈ និងព្រះរាមបុប្ផាទេវីបាននាំរបាំមួយនេះ មិនត្រឹមតែទៅកាន់ពិភពលោកតែប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រជាជនខ្មែរទូទាំងប្រទេស។នៅក្នុងអតីតកាល នៃរបាំបុរាណមួយនេះគឺសម្រាប់តែព្រះមហាក្សត្រទតតែប៉ុណ្ណោះ ដោយសម្តែងពីមុខព្រះភក្ត្ររបស់ខ្សែរាជវង្សានុវង្ស ដើម្បីរំឭកដល់បុព្វបុរសនៃខ្សែរាជវង្ស និងសម្រាប់ឧទ្ទិសដល់អាទិទេព ។

នៅក្នុងរបាំបុរាណខ្មែរជាធម្មតា មានតួរាំនាំមុខម្នាក់ ឬយ៉ាងច្រើនបំផុតពីរនាក់។ សម្តេចព្រះរាមបុប្ផាទេវីតែងតែជាតួរាំនាំមុខអប្សរា ដើម្បីតំណាងឲ្យស្ត្រី រាំពីឋានសួគ៌ដែលបានឆ្លាក់តាមជញ្ជាំងប្រាសាទអង្គរវត្ត។ នៅក្នុងគម្ពីរទេវកថាដ៏សំខាន់របស់តណ្ហាស្រីអប្សរាជាស្រី ដែលមានរូបឆោមឆើតឆាយនៅក្នុងទឹកហើយរស់នៅក្នុងស្រះឈូក។ ស្រីអប្សរាមានរូបសម្បត្តិស្រស់សោភា ហើយពេលខ្លះទៀតមានអំណាចទាក់ទាញមនុស្សប្រុសរហូតដល់ស្លាប់ទៀតផង។ របាំអប្សរាត្រូវបានផ្សាភ្ជាប់ជាមួយពិធីបុណ្យសាសនាសំខាន់ៗ។ អប្សរាគឺជាចំណងជើងខ្សែភាពយន្ត ដែលជាស្នាដៃដំបូងរបស់សម្តេចព្រះបាទនរោត្តមសីហនុ ដែលមានសម្តេចព្រះរាមបុប្ផាទេវីគឺជាតួឯកស្រី។ បើយោងទៅតាមសម្តេចព្រះរាមបុប្ផាទេវីរបាំអប្សរា អាចមានតួរាំយ៉ាងតិចបំផុត បីនាក់និងយ៉ាងច្រើនបំផុតប្រាំបួននាក់។ ប៉ុន្តែ នៅក្នុងនោះត្រូវមានតួរាំរបាំឯកម្នាក់។ របាំនេះមានភាពជ្រួតជ្រាបស្រមើស្រមៃស្រស់ស្អាតនិងមិនមានទីបញ្ចប់។ នេះប្រហែលមកពីតន្ត្រីដែលហាក់ដូចជាមានសំនៀងកាយវិការ និងមានចលនាយឺតៗតែរម្យទមដោយបត់បែនផ្ចិតផ្ចង់ និងសម្រស់ដ៏ស្រស់ស្អាត ព្រមទាំងការបញ្ចេញទឹកមុខដ៏ទន់ភ្លន់សោភា និងដ៏អស្ចារ្យរបស់តួសម្តែងនៃរបាំដែលភាគច្រើនជាមនុស្សវ័យក្មេង និងមានសម្រស់ស្រស់ស្អាត។

### រឿងព្រេងនៃរបាំអប្សរាមេរ៉ា

នៅខែមករា ឆ្នាំ២០១០សម្តេចព្រះរាម បានប្រមែប្រមូលក្រុមសិល្បៈខ្មែររួមមានទាំងអ្នកប្រាជ្ញនិងអ្នកច្នៃម៉ូតនៅឯផ្ទះរបស់ទ្រង់ក្នុងរាជធានីភ្នំពេញ។ ពេលនោះ ក៏បានចាប់ផ្តើមធ្វើការក្នុងគម្រោងរបាំថ្មីមួយ ដែលត្រូវបានស្គាល់ថា «រឿងព្រេងនៃរបាំអប្សរាមេរ៉ា» ដែលពិពណ៌នាអំពីការបង្កើតព្រះរាជាណាចក្រកម្ពុជា តាមរយៈរឿងទេវពីរអង្គគឺព្រះកម្ពុនិងទេពអប្សរមេរ៉ា។ ផ្នែកដំបូងនៃរបាំបានជាប់ទាក់ទងទៅនឹងកំណើតរបស់ទេពអប្សរដែល ជាតួរបាំមកពីឋានសួគ៌ដ៏ស្រស់ស្អាតទាំងអស់នេះ មានទំនាក់ទំនងជាមួយអច្ឆរិយដែលបានផុសចេញពីរឿងកូរសមុទ្រទឹកដោះដែលកូរដោយ ពពួកយក្សនិងពពួកទេវតា។ផ្នែកទី២ នៃរបាំគឺនិយាយអំពីម្ចាស់ក្សត្រិយ៍នៃទេពអប្សរ ដែលចុះមកកាន់ផែនដីតំណាងឲ្យទេពអប្សរបរិសុទ្ធអប្សរមេរ៉ា ដែលជាបុត្រីរបស់ស្តេចនាគគឺជាស្តេចក្នុងទឹកនិងលើគោក។ ការរួបរួមរវាងព្រះនាង និងព្រះអង្គកម្ពុ ដែលព្រះអង្គមកពីប្រទេសដទៃ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាចាប់កំណើតឡើង ព្រមជាមួយនឹងកុលសម្ព័ន្ធខ្មែរ។យោងទៅតាមរបាំខ្មែរ និងអ្នកប្រាជ្ញខាងសិល្បៈគឺលោកស៊ុប៉ាយាហេលែននុត (SuppyaHeleneNut) ដែលធ្វើការជិតស្និទ្ធជាមួយសម្តេចព្រះរាមបុប្ផាទេវីផ្តោតទៅ លើសិលាចារិករបាំថ្មីមួយនេះត្រូវបានបែងចែកជាពីរ ក្នុងការសម្តែងហើយវាមានឈុតឆាកទស្សនីយភាពជាច្រើន ដែលសម្តែងតាមបែបខ្លីៗ និងតាមបែបប្រពៃណី ដែលត្រូវបានបង្រួមឲ្យខ្លីព្រមទាំងមានការរៀបចំសាជាថ្មី/ និងការកែឡើងវិញឲ្យសាកសមនឹងសាច់រឿង។ឈុតទី១នៃ «រឿងព្រេងនៃរបាំអប្សរាមេរ៉ា»ត្រូវបានចែកជាបួនវគ្គ ដោយចាប់ផ្តើមពីរឿងទេវកថាកូរសមុទ្រទឹកដោះ។នៅក្នុងវគ្គដំបូង គឺពិពណ៌នាពីសង្គ្រាមគ្មានទីបញ្ចប់

រវាងទេវតានិងយក្សត្រូវបាន បញ្ចូលដោយបួនផ្នែកដោយក្រុមសម្តែងហើយតួសម្តែងទាំងនោះ ត្រូវតុបតែងខ្លួនឲ្យដូចទៅនឹងរូបចម្លាក់នៅតាមប្រាសាទអង្គរវត្ត។ វគ្គនេះគឺជាការសម្តែងប្រយុទ្ធរវាងមនុស្សប្រុសពីរនាក់ និងរវាងអសុរា«យក្ស»និងហនុមាន«ស្វា»។ ការបញ្ចូលគ្នាបែបប្រពៃណីគឺអសុរាមកពីល្ខោនខោល (ប្រពៃណីរាំតាមភូមិដែលមាននៅក្នុងរឿងរាមាយាណៈ) ហើយមួយទៀតមកពីការសម្តែងជាសាធារណៈ(ហនុមាន)គឺជាការ កែច្នៃថ្មីស្រឡាងដែលអ្នកសម្តែងមានកាយសម្បទា មាំមួន និងរហ័សរហួន អំឡុងពេលធ្វើសង្គ្រាម។ ឈុតទីពីរគឺត្រូវបែងចែកជាប្រាំវគ្គ ដោយមានកន្លែងដែលអប្សរា( ស្រីស្រស់ស្អាតមកពីឋានសួគ៌) គ្រប់គ្រងក្នុងការបង្កើតបរិយាកាសស្និទ្ធស្នាលនិងទាក់ទាញបន្ថែមទៀត។ នៅទីនេះយើងផាកចេញពីរឿងបង្កើតចក្រវាឡ និងការមិនស្រុះស្រួលគ្នាថាតើប្រទេសខ្មែរចាប់កំណើត ដោយរបៀបណា។

សម្តេចព្រះរាមនរោត្តមបុប្ផាទេវី គឺជាសាស្ត្រាចារ្យផ្នែកវប្បធម៌និងរបាំប្រពៃណី (ចាប់ពីឆ្នាំ១៩៦៥-១៩៧០)។ នៅក្នុងឆ្នាំ១៩៨០ សម្តេចព្រះរាមបានបង្រៀនរបាំបុរាណខ្មែរក្នុងជំរំជនភៀសខ្លួន SiteB ជាប់ព្រំដែនរវាងកម្ពុជា-ថៃ។ ចាប់តាំងពីការវិលត្រឡប់របស់ព្រះអង្គ មកកាន់ប្រទេសកម្ពុជា នៅថ្ងៃទី១៨ខែវិច្ឆិកា ឆ្នាំ១៩៩១ បន្ទាប់ពី កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស សម្តេចព្រះរាមបានចូលបម្រើការជាអនុរដ្ឋមន្ត្រីវប្បធម៌ និងវិចិត្រសិល្បៈ (ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣) គឺជាទីប្រឹក្សារដ្ឋាភិបាលទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ(ពីឆ្នាំ១៩៩៣ដល់ ឆ្នាំ១៩៩៨)គឺជារដ្ឋមន្ត្រីវប្បធម៌និងវិចិត្រសិល្បៈ(ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤)។ ក្រោយមកសម្តេចព្រះរាមក៏ទទួលបាន តួនាទីជាអនុប្រធាននៃកាកបាទក្រហមកម្ពុជាពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧។ ចាប់តាំងពីឆ្នាំ២០០០មកសម្តេចព្រះរាមគឺជា ប្រធានសមាគមន៍ចិន-កម្ពុជា។ តមកទៀត សម្តេចព្រះរាមក៏បញ្ចុះបញ្ចូលអង្គការអន្តរជាតិយូណេស្កូ បានយ៉ាងជោគជ័យក្នុងការដាក់បញ្ចូលរបាំព្រះរាជទ្រព្យ នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកអរូបីសម្រាប់មនុស្សជាតិ ដែលត្រូវបានប្រកាសក្នុងឆ្នាំ២០០៣។ សម្តេចព្រះរាមបាន ដឹកនាំគណៈប្រតិភូរបាំព្រះរាជទ្រព្យកម្ពុជាទៅកាន់សហគមន៍អឺរ៉ុប ជប៉ុន សហរដ្ឋអាមេរិករួមទាំងរដូវកាលវិស្សមកាលនៅឯសាលារបាំ Brooklyn ក្នុងខែឧសភា ឆ្នាំ២០១៣។ ក្រៅពីភាសាខ្មែរសម្តេចព្រះរាមអាចសរសេរ និងនិយាយភាសាបារាំងបានយ៉ាងល្អ។

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ បានប្រទានងារ ជាសម្តេចរាជបុត្រីព្រះរាម។សម្តេចព្រះរាមបានចូលបម្រើការក្នុងព្រឹទ្ធសភា(តំណាងសភាជាតិ) ចាប់ពីឆ្នាំ២០១៣ ដល់ខែមេសា ឆ្នាំ២០១៦។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ទ្រង់ត្រូវបានព្រះមហាក្សត្រតែងតាំង ក្នុងចំណោម រាជវង្សពាព្រះអង្គដទៃទៀតឲ្យងារ ជាក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជា។ សម្តេចព្រះរាមគឺជាមន្ត្រីនៃគ្រឿងឥស្សរិយយស នៃព្រះមហាម្ចាស់ក្សត្រិយានីស៊ីសុវត្ថិកុសុមៈ ហើយទ្រង់ក៏ជាមន្ត្រីគ្រឿងឥស្សរិយយសមុនីសារ៉ាផងដែរ។

សម្តេចរាជបុត្រីព្រះរាមនរោត្តម បុប្ផាទេវីបានយាងសោយព្រះទិវង្គតក្នុង ព្រះជន្ម៧៧ព្រះវស្សា នាវេលាម៉ោង ១២:៣០ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងមន្ទីរពេទ្យព្រះរាជាណាចក្រថៃដោយជរាពាធ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ជាថ្ងៃកាន់ទុក្ខនៅទូទាំងប្រទេសចំពោះការយាង សោយព្រះទិវង្គតរបស់សម្តេចរាជបុត្រីព្រះរាមនរោត្តមបុប្ផាទេវី ដើម្បីជាការរំឭកដល់ព្រះគុណបំណាច់ដ៏ធំធេងរបស់ព្រះអង្គចំពោះជាតិមាតុភូមិកម្ពុជាជាពិសេស លើផ្នែកសិល្បៈ វប្បធម៌ អរិយធម៌។ ព្រះរាជសពរបស់ ព្រះរាមនរោត្តម បុប្ផាទេវីត្រូវបានដឹកមកតម្កល់នៅវត្តបទុមវតី ក្នុងរាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៩ខែវិច្ឆិកាឆ្នាំ២០១៩ ដើម្បីធ្វើបុណ្យតាមព្រះបវេណី និងព្រះពុទ្ធសាសនា។ ព្រះរាជសពរបស់ព្រះរាមនរោត្តមបុប្ផាទេវីនឹងត្រូវថ្វាយព្រះភ្លើង នៅថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ហូ ថុនា**

# ម៉ៃ សារុំ ជនជាតិព័រ ៖ អតីតអ្នកនាំផ្លូវមេដឹកនាំខ្មែរក្រហម ប្រចាំនៅមន្ទីរច១ (បច្ចុប្បន្នច្រកព្រំដែនថ្មដាក្នុងស្រុកវាលវែង)

ជនជាតិព័រមាន ភាសា វប្បធម៌ទំនៀមទម្លាប់របស់ខ្លួនតាំងពីយូរយាណាស់មកហើយ។ ជនជាតិព័រភាគច្រើនរស់នៅប្រមូលផ្តុំគ្នានៅភូមិស្រែពាំង អន្លង់ក្រូច ពាមព្រុស ឃុំស្រែតាំងយ៉ ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ជនជាតិព័របានប្រកបរបរប្រពៃណីរបស់ខ្លួន ដូចជា បរបាញ់សត្វព្រៃ ធ្វើស្រែរកខ្លឹមចន្ទ បេះផ្លែដង្កោវ និងក្រវាញ។ ចំណែកវប្បធម៌ និងសិល្បៈ ជនជាតិព័រមានពិធីលាងអារក្ស និងមានរបាំដាច់ដោយឡែករបស់ខ្លួន ដែលសព្វជនជាតិខ្មែរហៅថា«របាំបេះផ្លែក្រវាញ» ព្រោះកាលពីសម័យមុនអ្នកភូមិជនជាតិព័រតែងតែប្រារព្ធ និងសម្តែងរបាំនេះមុនពេលចេញដំណើរទៅភ្នំក្រវាញ ដើម្បីបួងសួងដល់អារក្សអ្នកតាថែរក្សាព្រៃសុំខ្លឹមឈើល្អៗ។ ជនជាតិព័រ កម្រនឹងឈ្លោះប្រកែកគ្នាណាស់ហើយ នៅពេលរកបានសត្វឈ្លូស ប្រើសតែងតែចែកគ្នាហូបនៅក្នុងភូមិ។ នៅពេលចលនាបដិវត្តន៍ខ្មែរក្រហម ចូលមកដល់ជនជាតិព័ររាប់រយគ្រួសារត្រូវបានឃោសនាឲ្យចូលរួមជាមួយបដិវត្តន៍ ដោយបានបោះបង់ចោលវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។ជនជាតិព័រមួយចំនួនបាន ទទួលតួនាទីផ្សេងពីបដិវត្តន៍ខ្មែរក្រហម និងត្រូវបានបំបែកឲ្យទៅរស់នៅលាយឡំជាមួយជនជាតិខ្មែរ និងឆ្ងាយពីភូមិកំណើតដូចជា ម៉ៃ សារុំ។



ម៉ៃ សារុំ កំពុងផ្តល់បទសម្ភាសន៍ជាមួយ ឡុង ដានី នាយកនៃមជ្ឈមណ្ឌលផ្សះផ្សាវាលវែង

ម៉ៃ សារុំ ដែលនិយាយភាសាខ្មែរបានយ៉ាងច្បាស់បានរៀបរាប់ថា ខ្ញុំមានអាយុ៦៥ឆ្នាំ គឺជនជាតិព័រកើតនៅភូមិស្រែពាំង ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ (បច្ចុប្បន្ន ភូមិស្រែពាំង ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់)។ ក្រោយពេលខ្មែរក្រហមចូលមកគ្រប់គ្រងខ្ញុំត្រូវបានផ្លាស់ទៅរស់នៅឃុំសំរោងក្នុងស្រុកភ្នំក្រវាញវិញ។ខ្ញុំមានម្តាយឈ្មោះ ឡី ចំណែកឪពុកឈ្មោះ ម៉ៃ គឺជា មេភូមិនិងមានមុខរបររកខ្លឹមចន្ទទៅលក់នៅថៃ ដែលភាសាថៃហៅថា «ម៉ៃហម»។ បន្ទាប់ពី លក់ខ្លឹមចន្ទបានប្រាក់ ឪពុករបស់ខ្ញុំតែងតែទិញអំបិលប្រហុកពីថៃវែកត្រឡប់មកផ្ទះវិញ។ ឪពុកខ្ញុំចេញទៅរកស៊ីរយៈពេលកន្លះខែទៅមួយខែទើបត្រឡប់មកផ្ទះម្តង។ ខ្ញុំបានយកឈ្មោះឪពុករបស់ខ្ញុំឈ្មោះ ម៉ៃ ដាក់ជាត្រកូលរបស់ខ្ញុំ ដោយមិនដាក់ត្រកូលតាមជីតាឡើយ។ ឪពុកនិងម្តាយខ្ញុំគឺជាជនជាតិព័រដូច្នេះខ្ញុំអាចនិយាយភាសាជនជាតិព័រដើម្បីទំនាក់ទំនងជាមួយជនជាតិព័រនៅក្នុងភូមិ។ ភាសាជនជាតិព័រខុសពីភាសាខ្មែរប៉ុន្តែមានពាក្យមួយចំនួនស្រដៀងទៅនឹងភាសាថៃទៅវិញ ដូច្នេះហើយទើបជនជាតិព័រមានទំនាក់ទំនងល្អជាមួយជនជាតិថៃនៅតាមបណ្តោយព្រំដែន។ ទោះបីយ៉ាងណាជនជាតិព័ររៀនភាសាខ្មែរឆាប់ចេះ ប៉ុន្តែបើជនជាតិខ្មែររៀនភាសាព័រវិញជួបការលំបាកច្រើន។

កាលពីនៅវ័យក្មេងឪពុកម្តាយរបស់ខ្ញុំតែងតែបបួលខ្ញុំ ចូលក្នុងព្រៃបេះក្រវាញនៅពេលក្រវាញចេញផ្លែនៅខែសីហា នៅតាមជួរភ្នំស្ថិតនៅភូមិអន្លង់ក្រូច ក្នុងស្រុកក្រវាញ។ ខ្ញុំបានជួយស្ពាយឆ្នាំង ចាន និងសម្ភារផ្សេងៗចូលទៅព្រៃជាមួយគាត់។ នៅពេលបេះផ្លែក្រវាញបានច្រើន ឪពុករបស់ខ្ញុំបានរែកផ្លែក្រវាញទាំងនោះត្រឡប់មកផ្ទះវិញបន្ទាប់មកមានឈ្មួញកាត់ចិនបានមកទិញផ្លែក្រវាញ នៅផ្ទះរបស់ខ្ញុំតែម្តង ដែលកាលជំនាន់មុនខ្មែរក្រហម ផ្លែក្រវាញមួយគីឡូលក់បានតម្លៃ៥០រៀល(គិតជាមាសនៅសម័យនោះគឺ៣០០រៀលទើបទិញបានមាសមួយជី)។ ដើមក្រវាញភាគច្រើនដុះនៅក្រោមម្លប់ឈើ និងតាមជ្រលងភ្នំដែលមានអាកាសធាតុត្រជាក់។ ដើមក្រវាញមានសណ្ឋានដូចដើមរំដេង ប៉ុន្តែមានស្លឹកធំៗជាងដើមរំដេងនិងមានរោមតូចឆ្មាពណ៌សៗ នៅលើស្លឹកៗនៅពេលយើងប៉ះរោមនៅលើស្លឹកនោះ នឹងបណ្តាលឲ្យរមាស់ស្បែក។ ផ្លែក្រវាញរាងមូលតូចៗមានរស់ជាតិហឹរនិងមានក្លិនដូចជាប្រេងខ្យល់។

ចំណែកដង្កោក៏មានសណ្ឋានដូចក្រវាញដែរ ប៉ុន្តែមានដើមរលោងៗដង្កោមានពីរប្រភេទគឺ ដង្កោក្រហម និងដង្កោដំរីដែលមានផ្លែធំប៉ុនៗមេជើង ហើយពេលទុំមានរស់ជាតិផ្អែមអាចហូបបាន។ ប៉ុន្តែឈ្មួយកាត់ចិនមិនទិញដង្កោដំរីនេះ គឺទិញតែដង្កោក្រហមដែលមានផ្លែតូចៗជាចង្កោមស្រដៀងនឹងក្រវាញ។ ទោះបីយ៉ាងណា ក្រវាញមានក្លិនឈ្ងុយនិងរស់ជាតិហឹរជាងដង្កោហើយផ្លែក្រវាញពេលទុំមានសម្បកក្រាស និងរឹងជាងផ្លែដង្កោ។

ប្រជាជននៅក្នុងភូមិភាគច្រើនយកកូនក្រវាញ និងដង្កោដែលដុះលូតពីដីជាប់នឹងដើមធំមកធ្វើជាអន្លក់ ឆា និងស្ល។ ក្រៅពីយកដើមក្រវាញធ្វើជាអាហារ នៅពេលដែលខ្ញុំរកកលគ្រុនក្តៅខ្ញុំបានយកផ្លែក្រវាញ៤ ទៅ៥ គ្រាប់មកស្ងោរជាមួយទឹកសម្រាប់ផឹក ដែលអាចធ្វើឲ្យខ្ញុំបានឆាប់ធូរស្បើយពីជំងឺបានដែរ។

ក្រោយមក ខ្ញុំបានចូលរៀនភាសាខ្មែរនៅសាលាបឋមសិក្សាលាចនៅក្នុងស្រុកភ្នំក្រវាញ ដោយខ្ញុំបានមកស្នាក់នៅជាមួយអ៊ំប្រុស និងអ៊ំស្រីធ្វើជាប៉ូលីស។ ខ្ញុំស្នាក់នៅផ្ទះជាមួយអ៊ំប្រុសនិងអ៊ំ ព្រោះផ្លូវធ្វើដំណើរពីស្រុកកំណើតរបស់ខ្ញុំមកសាលានៅសម័យនោះពិបាកខ្លាំងណាស់ គឺមានតែផ្លូវរទេះនិងផ្លូវលំប៉ុណ្ណោះ។ ម្យ៉ាងទៀត អ៊ំរបស់ខ្ញុំទាំងពីរមិនមានកូនប្រុស ពេលខ្ញុំនៅជាមួយគាត់ ខ្ញុំបានជួយមើលថែកូនស្រីតូចៗរបស់គាត់ បន្ទាប់ពីខ្ញុំទំនេរពីរៀនសូត្រ។នៅឆ្នាំ១៩៧០ ខ្ញុំបានរៀនដល់ថ្នាក់ទី៧(ជំនាន់សង្គមចាស់) ក៏កើតមានរដ្ឋប្រហារ។ពេលនោះអ៊ំរបស់ខ្ញុំ ក៏ឲ្យខ្ញុំត្រឡប់ទៅផ្ទះនៅឯស្រុកកំណើតវិញ។

នៅក្នុងឆ្នាំ១៩៧០ ម្តាយរបស់ខ្ញុំក៏បានស្លាប់ចោលខ្ញុំទៅ។ ពេលនោះឪពុករបស់ខ្ញុំបានណែនាំខ្ញុំថា «កូនទៅបួសទៅព្រោះឯងធំដែរហើយម្តាយឯងក៏ស្លាប់ទៀត វរ!គេមកចាប់កូនចូលធ្វើទាហានហើយម្យ៉ាងទៀតបួសសងគុណម្តាយឯងផង»។ ខ្ញុំបានស្តាប់ការទូន្មានពីឪពុករបស់ខ្ញុំៗខ្ញុំបានចូលបួសនៅវត្តទួលគ្រួសក្នុងឃុំស្រែតាំងយ៉ៗ

នៅអំឡុងពេលខ្ញុំនៅជាព្រះសង្ឃ ចលនាខ្មែរក្រហមក៏បានរីករាលដាលចូលមក ដល់ភូមិទួលគ្រួស ភូមិស្រែពាំងនិងភូមិផ្សេងៗទៀត ហើយភូមិទាំងនោះ បានក្លាយទៅជាតំបន់រំដោះរបស់ខ្មែរក្រហម។ បន្ទាប់មកខ្មែរក្រហម បានបង្កើតស្រុកថ្មីមួយមានឈ្មោះថា «ស្រុកពាមព្រុស» ស្ថិតនៅក្នុងតំបន់៦ភូមិភាគយ័ព្យ។មន្ទីរស្រុកពាមព្រុស មានទីតាំងស្ថិតនៅភូមិស្រែពាំងហើយតាទូច ត្រូវបានចាត់ឲ្យធ្វើជាគណៈស្រុកដឹកនាំការងារដែលក្រោយមកត្រូវបានខ្មែរក្រហមចាប់ខ្លួន។ចំណែកស្រុកក្រវាញ មានមន្ទីរស្រុកនៅលាច។

បន្ទាប់ពីខ្ញុំបួសបាន២ព្រះវស្សា ខ្មែរក្រហមបានប្រកាសរំសាយព្រះសង្ឃពីវត្តអារាម ដូច្នេះខ្ញុំក៏សឹកមកធ្វើស្រែវិញ។រយៈពេលបីខែក្រោយមក គឺនៅខែធ្នូ ឆ្នាំ១៩៧២ខ្ញុំបានចូលបម្រើយោធាខ្មែរក្រហម និងបានទៅហ្វឹកហាត់ក្បួនយោធានៅឃ្លាំង ស្ថិតនៅក្នុងស្រុកភ្នំក្រវាញ រយៈពេលកន្លះខែ។ ក្បួនយោធាដែលខ្ញុំហាត់រួមមានៈលូន,ដើរតឿក្នុងទឹក, បាញ់

និងចាក់ដោយកាំបិត នៅពេលអស់គ្រាប់, ហាត់គុណដំបង, វិធីលាក់ការណ៍, វិន័យកងទ័ពដែលសុភាពរាបសារប៉ុន្តែត្រូវម៉ឺងម៉ាត់, មិនត្រូវក្បត់កូនប្រពន្ធ, ពេលចាប់ឈ្លើយសឹកបានមិនត្រូវជេរនិងវាយដំ និងហាត់ពីវិធីហិតក្លិនផ្សែងនិងក្លិនបារីរបស់ខ្មាំងនៅពេលចេញដើរល្បាត។ បន្ទាប់ពីហ្វឹកហាត់រួចខ្ញុំបានចូលទៅនៅអង្គភាពវរសេនាតូច ក្នុងតំបន់៦ក្រោមការគ្រប់គ្រងរបស់តាវង់។ ដំបូងប្រធានរបស់ខ្ញុំបានឲ្យខ្ញុំទៅដាំបាយ និងបានសួរខ្ញុំថា ឯងហ៊ានទៅវាយទេ? ខ្ញុំបានឆ្លើយថា «មិនខ្លាចទេបង មួយគ្រាប់ងាប់ដូចគ្នា»។មួយអាទិត្យក្រោយមក ខ្ញុំក៏ត្រូវបានបញ្ជូនឲ្យឡើងទៅវាយបន្ទាយទាហានរបស់លន់ នល់ នៅម្តុំកុកកូន ជិតទីរួមខេត្តពោធិ៍សាត់។

នៅចុងឆ្នាំ១៩៧៣ ខ្ញុំ ត្រូវបានផ្លាស់ទៅនៅបន្ទាយស្ថិតនៅម្តុំទួលម្កាក់ ក្នុងភូមិវាលវែង ឃុំត្រពាំងពង្ស ស្រុកភ្នំក្រវាញ (បច្ចុប្បន្នភូមិគៀនជម្រុក ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់) ដែលគ្រប់គ្រងដោយ តាវង់ ដដែល។ នៅក្នុងបន្ទាយទួលម្កាក់ មានយោធាខ្មែរក្រហមចំនួនបួនកងអនុសេនាតូចបញ្ចូលគ្នា គឺមួយកងអនុសេនាតូចមានសមាជិកចាប់ពី២០ ទៅ៣០នាក់។ កងអនុសេនាតូចនីមួយៗត្រូវទៅប្រចាំការនៅតាមភូមិ ដូចជា ភូមិសំព័រ ភូមិអូរថ្កូវ ភូមិដំរី និង ភូមិជម្រុក ដែលស្ថិតនៅដាច់ឆ្ងាយពីគ្នា។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ ខ្ញុំ ត្រូវបានបញ្ជូនពីបន្ទាយទួលម្កាក់ ទៅប្រចាំការម្តុំមាត់ព្រះវិញ ព្រោះមានការចោទប្រកាន់ថាយោធាខ្មែរក្រហម នៅខេត្តកោះកុងក្បត់។ ពេលនោះ មេរបស់ខ្ញុំឈ្មោះតាវង់ក៏ឡើងទៅចរចាជាមួយយោធានៅកោះកុងដែរ ប៉ុន្តែមិនត្រូវគ្នាទើបបញ្ជូនកងរបស់ខ្ញុំទៅចាំស្ទាក់នៅម្តុំស្ទឹងតាចាន់កុំឲ្យយោធានៅកោះកុងជ្រៀតចូលមកភូមិវាលវែងទៀត ទើបបណ្តាលឲ្យមានការវាយប្រយុទ្ធគ្នានិងបណ្តាលឲ្យស្លាប់សមាជិកយោធានៅក្នុងអង្គភាពរបស់ខ្ញុំម្នាក់។ ក្រោយមក ខ្ញុំបានសួរមេរបស់ខ្ញុំ តាវង់ បន្ទាប់ពីគាត់បានចូលរួមប្រជុំបក្សថា យោធានៅខាងកោះកុងទៅណា?តាវង់បានប្រាប់ខ្ញុំថា អ្នកក្បត់ទាំងនោះបានរត់ទៅរស់នៅក្នុងទឹកដីថៃអស់ហើយ។

កងរបស់ខ្ញុំបោះទីតាំងនៅមាត់ព្រះ បានមួយរយៈ អង្គភាពយោធាក៏បានផ្លាស់ កងរបស់ខ្ញុំមកប្រចាំការនៅប្រម៉ោយវិញ។ ប៉ុន្តែកងរបស់ខ្ញុំក៏មានកាតព្វកិច្ចទៅចាំឃ្លាំមើលសកម្មភាពមនុស្សចេញចូល និងដើរល្បាតនៅស្ទឹងមេទឹក (ថៃហៅស្ទឹងមេណាម) នៅម្តុំថ្មដា ព្រំដែនខ្មែរ-ថៃ ព្រោះខ្លាចថៃចូលមក។កងរបស់ខ្ញុំដែលមានសមាជិកពី១៥ទៅ២០នាក់ត្រូវបានបែងចែកកម្លាំងគ្នាស្ពាយកាំភ្លើង អង្ករ ចាន់ឆ្នាំង និងឲ្យសមាជិក៣ នាក់ដើរទៅមុខចម្ងាយកន្លះគីឡូដើម្បីស៊ើបការណ៍ ទើបកងធំដើរតាមពីក្រោយដើម្បីបង្ការខ្លាចមានខ្មាំងស្ទាក់វាយប្រហារ។ កងរបស់ខ្ញុំ ធ្វើដំណើរដោយថ្មើជើងរយៈពេល៥ថ្ងៃទើបទៅដល់ស្ទឹងមេទឹក។ នៅទីនោះ មានព្រៃដុះជុំជិតនិងមិនមានជនជាតិថៃ និងខ្មែរ ចេញចូលឡើយគឺមានតែក្រុមគ្រួសារតាវីក និងក្រុមជនជាតិជងផ្សេងទៀតសរុបទាំងអស់៧គ្រួសារ ដែលមិនព្រមចូល បម្រើខ្មែរក្រហមបានរត់មករស់នៅថ្មដាតាមបណ្តោយព្រំដែនខ្មែរ-ថៃនេះ។ កងរបស់ខ្ញុំប្រចាំការនៅស្ទឹងមេទឹករយៈពេល១០ថ្ងៃ ទើបត្រឡប់មកបន្ទាយនៅប្រម៉ោយវិញ។

រយៈពេល៥ខែក្រោយមក យោធាខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញទាំងស្រុង។ ពេលនោះខ្មែរក្រហមបានបញ្ជូនយោធាបន្ថែមមកកាន់ព្រំដែនខ្មែរ-ថៃ ចំណែកកងរបស់ខ្ញុំនៅខាងទ័ពតំបន់នៅឈរជើងនៅប្រម៉ោយដដែល។

នៅអំឡុងពេលនោះ មានប្រជាជនខ្លះបាននាំគ្នារត់ភៀសខ្លួនទៅប្រទេសថៃដែរ។ខ្ញុំបានជួបជនភៀសខ្លួនទាំងនោះ នៅពេលដែលខ្ញុំចេញដើរល្បាតនៅម្តុំតំបន់អណ្តូងដី (បច្ចុប្បន្នឃុំអន្លង់រាបស្រុកវាលវែង)។ ជនភៀសខ្លួនជាច្រើនបានស្លាប់នៅក្នុងព្រៃដោយ សារអត់អាហារ និងមួយចំនួនមានសភាពវង្វេងវង្វាន់ស្មារតី។ ខ្ញុំ ចាប់បានជនភៀសខ្លួនចំនួន៦នាក់ ស្រីក្រមុំ២នាក់ និងមនុស្សប្រុស៤នាក់។ ខ្ញុំបានយកជនភៀសខ្លួនទាំង៦នាក់ទៅសួរចម្លើយ ទើបដឹងថាមកពីខេត្តកំពង់ចាម និងស្វាយរៀង។ ជនភៀសខ្លួនទាំងនោះបានសារភាពថាមូល

ហេតុដែលគាត់រត់ភៀសខ្លួន ដោយសារមិនចង់រស់នៅក្នុងសហករណ៍បន្តទៀត ព្រោះខ្វះខាតអាហារហូបចុកៗបន្ទាប់ពីសួរចម្លើយរួចខ្ញុំបានឲ្យបាយជនភៀសខ្លួនទាំងនោះហូប និងឲ្យស្នាក់នៅជាមួយទ័ពមួយរយៈខ្លី ទើបបញ្ជូនអ្នកទាំងនោះមកសហករណ៍ខាងក្រោយវិញ ប៉ុន្តែខ្ញុំមិនដឹងប្រធានសហករណ៍យកជនភៀសខ្លួនទាំងនោះទៅណាទៀតទេៗ

ក្រោយពីបញ្ជូនជនភៀសខ្លួននោះមកសហករណ៍រួចនៅរដូវប្រាំងឆ្នាំ១៩៧៦ខ្ញុំក៏សុំអង្គភាពមកលេងឪពុកៗពេលមកផ្ទះខ្ញុំឃើញឪពុករបស់ខ្ញុំឈឺហើម ខ្ញុំក៏បានសួរគាត់ថាហេតុដូចម្តេចបានជាពុកហើម? ឪពុកខ្ញុំបាប្រប់ថាហូបមិនគ្រប់ព្រោះអង្គការឲ្យសន្សំសំចៃៗ ខ្ញុំ បាននិយាយថាស្រូវធ្វើបានច្រើនណាស់ហេតុដូចម្តេចទៅជាដូច្នេះហើយខ្ញុំក៏មិននិយាយស្តីទៀតដែរៗ ក្រោយមកខាងសហករណ៍មកសួរខ្ញុំដោយសង្ស័យថាខ្ញុំរត់ចេញពីអង្គភាពយោធាៗ ពេលនោះខ្ញុំក៏បានបង្ហាញសំបុត្រអនុញ្ញាតច្បាប់១ ៥ ថ្ងៃពីអង្គភាពដែលមានបោះត្រាពីលើ ទើបសហករណ៍ជឿជាក់ៗ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦អង្គភាពយោធាបានបញ្ជូនខ្ញុំ ទៅនៅហិនត្រឡោកជាប់នឹងស្ទឹងមេទឹកព្រំដែនខ្មែរ-ថៃៗ ខ្ញុំឈរជើងនៅទីនោះបានមួយរយៈទើបអង្គការប្រកាសប្រាប់យោធា នៅតាមកងតូច និងកងធំថានៅរយៈពេលបីខែទៅមុខទៀត អង្គភាពត្រូវការជ្រើសរើសកងទ័ពបញ្ចូលទៅក្នុងអង្គភាពកងពលនៃភូមិភាគពាយ័ព្យៗ ហើយខ្ញុំក៏មិននិយាយស្តីទៀតដែរៗក្រោយមកខាង សហករណ៍មកសួរខ្ញុំដោយសង្ស័យថាខ្ញុំរត់ចេញពីអង្គភាពយោធាៗពេលនោះខ្ញុំក៏បានបង្ហាញសំបុត្រអនុញ្ញាតច្បាប់១៥ថ្ងៃពីអង្គភាពដែលមានបោះត្រាពីលើទើបសហករណ៍ជឿជាក់ៗ

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ អង្គភាពយោធាបានបញ្ជូនខ្ញុំទៅនៅហិនត្រឡោកជាប់នឹងស្ទឹងមេទឹក ព្រំដែនខ្មែរ-ថៃៗ ខ្ញុំឈរជើងនៅទីនោះបានមួយរយៈ ទើបអង្គការប្រកាសប្រាប់យោធានៅតាមកងតូច និងកងធំថានៅរយៈពេលបីខែទៅមុខទៀតអង្គភាពត្រូវការ ជ្រើសរើសកងទ័ពបញ្ចូលទៅក្នុងអង្គភាពកងពលនៃភូមិភាគពាយ័ព្យ ៗ

នៅអំឡុងពេលនោះ ខ្ញុំ បាននិយាយលេងជាមួយតាផាត និងបានប្រាប់ តាផាតថាខាងអង្គភាពតម្លើងតួនាទីខ្ញុំធ្វើមេក្រុម ប៉ុន្តែខ្ញុំមិនសូវចេះទេៗ តាផាតបានតបមកវិញថា «ធ្វើទៅអញក៏អត់ចេះដែរ!»ៗ តាផាត បានណែនាំខ្ញុំថា «ភារកិច្ចដែលបក្សប្រគល់ឲ្យយើងយើងត្រូវតែធ្វើៗ បក្សមើលឃើញយើងមានសមត្ថភាពទើបឲ្យយើងធ្វើ បើយើងគ្មានសមត្ថភាពក៏បក្សមិនឲ្យយើងធ្វើដែរ»ៗ បន្ទាប់ពីស្តាប់ការណែនាំរបស់តាផាតរួចទើបធ្វើឲ្យខ្ញុំកាន់តែស្និទ្ធស្នាល និងស្គាល់គាត់កាន់តែច្បាស់ហើយក្រោយៗមក ខ្ញុំតែងតែយកសំបុត្រពីរវសេនាធំទៅជូនគាត់ៗ

នៅក្នុងឆ្នាំ១៩៧៧ អង្គភាពយោធាបានកោះប្រជុំនិងបានប្រកាសប្រាប់សមាជិកថាប្រធាន អនុប្រធាននិងកងទ័ពនៅភូមិភាគបូព៌ាភូមិភាគពាយ័ព្យ និងភូមិខត្តរដែលជាប់ពាក់ព័ន្ធជាមួយវៀតណាមមានគំនិតក្បត់ៗ បន្ទាប់មក អង្គភាពយោធាក៏ចាប់ផ្តើមជ្រើសរើសទ័ពទៅវាយតទល់ជាមួយវៀតណាម ប៉ុន្តែមិនបានជ្រើស យកកងរបស់ខ្ញុំទៅទេព្រោះខ្លាចទៅពាក់ព័ន្ធជាមួយវៀតណាមទៀត ដូច្នេះ រក្សាទុកកងរបស់ខ្ញុំឲ្យយាមការពារព្រំដែនខាងលិចជាមួយថៃដដែលៗ

ពេលនៅព្រំដែន ខ្ញុំតែងទទួលការអប់រំពីអង្គភាពដែលទទួលបញ្ជាមកពី ប៉ុល ពត លេខាបក្សថា ដីនៅលើភ្នំខ្នងភ្នំជារបស់កម្ពុជាចំណែកខាងក្រោមជារបស់ថៃៗ ដូច្នេះបើខាងថៃឡើងមកកងរបស់ខ្ញុំត្រូវតែការពារៗ ថ្ងៃមួយនៅពេលយាមនៅប្រកផ្លូវជា(បច្ចុប្បន្ននៅក្នុងដីថៃ និងមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីប៉ុស្តិ៍យាមកម្ពុជា) ខ្ញុំនិងសមាជិកក្រុមបាននាំគ្នាលេងអុករ៉េកដោយសារ តែអផ្សុកខ្លាំងពេកស្រាប់តែឮស្នូរផ្ទុះមីនៗ ខ្ញុំ បានស្រែកសួរសមាជិកកងបញ្ជាក់ថា «ឈ្លួសជើរជាន់មីនឬ?» ពេលនោះសមាជិកកងបានតបថា ចាំស្តាប់សំឡេងបន្តិចសិនបង ហើយក៏នាំគ្នាលេងអុករ៉េកបន្តទៀតៗមួយសន្ទុះក្រោយមកក៏ឮសំឡេងផ្ទុះម្តងទៀត ហើយនៅពេលខ្ញុំក៏ក្រឡេកទៅឃើញខ្មាំងថៃបើកឡើង មកលើខ្នងភ្នំៗឃើញដូច្នេះខ្ញុំ បានបែងចែកកម្លាំងរបស់ខ្ញុំ៦នាក់ព័ទ្ធវាយ

កងទ័ពថៃពីចំហៀង និងពីក្រោយ។ កងកម្លាំងរបស់ខ្ញុំវាយជាមួយកងទ័ពថៃរយៈពេល២០នាទី បណ្ដាលឲ្យកងទ័ពថៃស្លាប់អស់បួននាក់ ហើយអ្នកដែលនៅរស់បានរត់ចុះទៅក្រោមវិញ។ កងរបស់ខ្ញុំបានរឹបអូសយកកាំភ្លើងអឹមសិបានមួយចំនួន។ ស្រាប់តែព្រឹកថ្ងៃបន្ទាប់ កងទ័ពថៃបានផ្ដោងគ្រាប់ជាច្រើនចេញពីកប៉ាល់ ដែលមានមូលដ្ឋាននៅលើសមុទ្រសំដៅមកប៉ុស្តិ៍យាមរបស់ខ្ញុំ។ ខ្ញុំ និងសមាជិកកង បាននាំគ្នារត់ចូលរូងថ្មដើម្បីលាក់ខ្លួន ប៉ុន្តែកងរបស់ខ្ញុំមិនបានបាញ់តបទៅវិញទេ ព្រោះកងរបស់ខ្ញុំ មានតែគ្រាប់បេ ហើយក៏មិនដឹងថាកងទ័ពថៃឈរជើងនៅម្ដុំណាឲ្យច្បាស់លាស់ដែរ។

ទោះបីយ៉ាងណា កងទ័ពថៃមិនអាចចូលមកយកសាកសពកងទ័ពរបស់ខ្លួនបានដែរ ព្រោះយោធាខ្មែរក្រហមបានដឹកអន្ទងដោតចម្រូង និងពង្រាយគ្រាប់មីនយ៉ាងច្រើននៅតាមបណ្ដោយព្រំដែន។បន្ទាប់ពីហេតុការណ៍វាយប្រយុទ្ធគ្នារួច ខាងអគ្គភាពទ័ពរបស់ខ្ញុំបានទូរលេខ និងរាយការណ៍ទៅខាងកងពលហើយចាប់តាំងពីពេលនោះ មកកងទ័ពថៃក៏លែងចូលមកដីកម្ពុជាដែរ។ នៅទីនោះ ខ្ញុំសំឡឹងពីប៉ុស្តិ៍យាមរបស់ខ្ញុំទៅឃើញផ្ទះរបស់ប្រជាជនថៃ នៅជង្ហែរតាមជើងភ្នំ។ នៅអំឡុងពេលនោះ បក្សក៏បានណែនាំឲ្យកងទ័ពដឹកអន្ទងដោយតចម្រូងពីថ្មដារហូតទៅដល់ពាមតា ក្នុងស្រុកសំឡូត ដែលជាការងារដ៏លំបាក និងធ្ងន់ធ្ងរ។ ចំណែករបបអាហារពេលខ្លះកងរបស់ខ្ញុំជួបការខ្វះខាតដែរ ដោយសារតែកងដឹកជញ្ជូនស្បៀងពីអន្លង់វាប មកផ្ដល់ឲ្យមិនទាន់ពេលព្រោះផ្លូវលំបាក។

ខ្ញុំយាមការពារព្រំដែននៅថ្មដារហូតដល់ឆ្នាំ១៩៧៩ ទើបអគ្គភាពយោធា បានប្រមូលកម្លាំងយោធាទាំងអស់រួមទាំងសមាជិកកងរបស់ខ្ញុំ ដែលយាមការពារនៅព្រំដែនថ្មដាមករួមកម្លាំងគ្នានៅក្នុងកងពលដែលគ្រប់គ្រងដោយតាផាត ដើម្បីវាយទប់ទល់កងទ័ពវៀតណាម នៅសរមភូមិត្រែង។ ពេលនោះ ប្រធានវរសេនាធំដែលទើបនឹងឡើងថ្មីឈ្មោះ ថន បានឲ្យកូនចៅមកដកកាំភ្លើងរបស់ខ្ញុំ និងឲ្យខ្ញុំផ្ទេរភារកិច្ចទៅអ្នកផ្សេងវិញ។ ខ្ញុំគិតថាប្រហែលបក្សចោទថាខ្ញុំក្បត់ហើយ ហើយខ្ញុំច្បាស់ជាស្លាប់មិនខាន។ បន្ទាប់មកថនបានហៅខ្ញុំទៅជួបនិងប្រាប់ថា អគ្គភាពបានជ្រើសរើសមនុស្សពាក់រួមមាន ខ្ញុំ,ហួននិងផួន(ស្លាប់)ដែលបានស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់រង់ចាំនាំសារ និងនាំទ័ពដែលកំពុងប្រយុទ្ធជាមួយវៀតណាម ទៅបោះមូលដ្ឋាននៅស្ទឹងមេទឹកវិញនៅ ពេលបាក់ទ័ព។ការវាយប្រយុទ្ធគ្នាជាមួយវៀតណាមបានអូសបន្លាយអស់រយៈពេលជាច្រើនខែ ដូច្នេះ ថន ក៏បានបញ្ជូនខ្ញុំឲ្យមកស្ទឹងមេទឹកមុន ដើម្បីពិនិត្យទីតាំងភូមិសាស្ត្រសម្រាប់យោធាឈរជើង។ មានយោធាខ្មែរក្រហមបាន មកតាមខ្ញុំជាបន្តបន្ទាប់ដែលសរុបទាំងអស់ចំនួន១៥នាក់។ នៅទីនោះ ខ្ញុំ ក៏បានជួបក្រុមជនជាតិភាគតិចភូមិភាគឦសានដែលជាកងការពារមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមមាន តាកេង, តាទូ, តាសុទ្ធ និងតាកែន បានដឹកនាំយោធាមជ្ឈិមមកដល់ស្ទឹងមេទឹកដែរ។ តាកេងបានណែនាំខ្ញុំ ឲ្យរៀបចំទីតាំង ភូមិសាស្ត្រសម្រាប់យោធារកកន្លែងដែលមានទឹក និងរក្សាទឹកទុកសម្រាប់កងយោធាដែលនឹងមកដល់ស្ទឹងមេទឹកជាបន្តបន្ទាប់ទៀត។

នៅពេលអគ្គការប្រមូលផ្ដុំយោធាបាន ច្រើនហើយ ខ្ញុំបានរៀបចំទីតាំងសម្រាប់សាងសង់មន្ទីរ៨១(មន្ទីរមជ្ឈិមឬមន្ទីរសម្ងាត់ច១),ទីតាំងសម្រាប់យោធា(ឬមន្ទីរសម្ងាត់ច២), ឃ្លាំងភ័ស្តុភា កន្លែងដឹកជញ្ជូន នៅស្ទឹងមេទឹក (ឬថ្មដា)។ បន្ទាប់មកទើបមេដឹកនាំខ្មែរក្រហមធំៗ រួមមាន នួន ជា, ប៉ុល ពត, ខៀវ សំផន, អៀង សារី និង សុន សេន មកធ្វើការនៅមន្ទីរ៨១ នេះនិងដឹកនាំកងទ័ពទៅវាយវៀតណាមនៅសមរភូមិ។ ចំណែក តាកេង, តាទូ និង តាកែន នៅខាងមន្ទីរការពារដែលមានឋានៈស្មើនឹងប្រធានកងពល។ ចំណែកខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានក្រុមកងការពារ ដែលមានសមាជិក៣០នាក់ព្រោះខ្ញុំស្គាល់ទីតាំងភូមិសាស្ត្រ នៅតំបន់នោះ។ នៅទីនោះក៏មានស្ថានីយ៍វិទ្យុរបស់ខ្មែរក្រហមមួយដែរ ស្ថិតនៅអូរស្មស្ដីជាប់ស្ទឹងមេទឹកចម្ងាយប្រមាណ បីគីឡូម៉ែត្រពីមន្ទីរ៨១ ឬច១។ ក្រោយមកខ្ញុំបាននាំ ប៉ុល ពត និងមេដឹកនាំ

ខ្មែរក្រហមផ្សេងទៀតមករស់នៅជិត ស្ថានីយ៍វិទ្យុ នៅអូរស្មួស្តីជាប់ស្ទឹងមេទឹកវិញ។នៅថ្ងៃ មួយប្រហែលជានៅក្នុងឆ្នាំ ១៩៨៤ ប្រធានកងពលឈ្មោះ តារ៉ែន (កូនប្រសាររបស់តាម៉ុកដែលប្រចាំការនៅស្ទឹងមេទឹកបានរាយការណ៍ប្រាប់ ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមផ្សេងៗថាបានបោសសម្អាតកងទ័ពវៀតណាមអស់ហើយ។ប៉ុន្តែខ្ញុំមិនទុកចិត្តការរាយការណ៍នេះឡើយ ក៏សុំអនុញ្ញាតពី ប៉ុល ពត ដោយប្រាប់ថាចង់ទៅមន្ទីរពេទ្យមជ្ឈិមស្ថិតនៅជិតចម្ការដំឡូង នៅលើខ្នងភ្នំ និងមានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីមន្ទីររបស់ខ្ញុំ ដើម្បីស៊ើបឲ្យដឹងច្បាស់ពីហេតុការណ៍នេះ។

ពេលនោះ ខ្ញុំក៏ស្នើឈ្មោះ សាវ៉ាន់ ដែលជាពេទ្យពិនិត្យមើលជំងឺប៉ុលពតផ្ទាល់ឲ្យជួយជូនខ្ញុំ ទៅជួបឈ្មោះ ពឿន (កូនប្រសាររបស់អៀងសារី) ប្រធានមន្ទីរពេទ្យឲ្យជួយពិនិត្យជំងឺខ្ញុំដែរ។ពេលខ្ញុំធ្វើដំណើរទៅមន្ទីរពេទ្យមជ្ឈិមក៏មានហេតុការណ៍វាយប្រហារគ្នា៤លើកនៅជិតមន្ទីរពេទ្យមជ្ឈិមហើយ នៅពេលខ្ញុំដើរត្រឡប់មកវិញស្រាប់តែ ឃើញវត្តមានកងទ័ពវៀតណាមជាច្រើននៅតាមផ្លូវ។ ប៉ុន្តែ កងទ័ពវៀតណាមទាំងនោះមិនបានបាញ់ខ្ញុំឡើយព្រោះខ្ញុំដើរតែពីរនាក់ប៉ុណ្ណោះ។ពេលខ្ញុំមកដល់មន្ទីរ៨១នៅពេលរសៀលវិញ ខ្ញុំក៏បានសុំអនុញ្ញាតដើម្បីជួបនិង រាយការណ៍ប្រាប់ ប៉ុល ពត ពីហេតុការណ៍ដែលខ្ញុំជួបប្រទះនិងបានប្រាប់គាត់ថាអ៊ំត្រូវចេញពីមន្ទីរមុនម៉ោង៣ជិតភ្លឺនេះបើមិនចេញទេ គេ (កងទ័ពវៀតណាម) នឹងចូលដល់ហើយ។ ប៉ុល ពត បានសួរខ្ញុំបញ្ជាក់ពីសភាពការណ៍ច្បាស់លាស់ហើយទើបគាត់យល់ព្រមចេញទៅមុន។

បន្ទាប់មក ខ្ញុំក៏បានប្រាប់ប្រពន្ធខ្ញុំឲ្យរៀបចំអីវ៉ាន់ និងនាំកូនស្រីច្បងរបស់ខ្ញុំដែលទើបនឹងកើត រួមជាមួយនារីៗនៅក្នុងអង្គភាពចូលទៅថៃ ដោយជិះឡានវិទ្យុផ្សាយសំឡេងរបស់ខ្មែរក្រហម ដែលមានឈ្មោះវ៉ាន់ជនជាតិលាវនៅខាងគណៈទាក់ទងព្រំដែន បានជូនដំណឹងទៅថៃមុនរួចហើយ។ចំណែកខ្ញុំបានចាក់ចេញទៅតាមក្រោយ។ ខ្ញុំទៅនៅវល្លិ៍បួនក្នុងទឹកដីថៃហើយអង្គភាពការពារ របស់ខ្ញុំក៏ត្រូវបានរំសាយនៅទីនោះដែរ។ នៅក្នុងឆ្នាំ១៩៨៤នេះដែរខ្ញុំបានសរសេរសំបុត្រមួយច្បាប់ផ្ញើតាមឈ្មោះ វ៉ែន យកទៅជូន ប៉ុល ពត សុំអនុញ្ញាតទៅរស់នៅជំរំសាយខេវិញ។ចំណែកប៉ុល ពត, នួន ជា, ខៀវ សំផន និង សុន សេន ក៏បានផ្លាស់ចេញទៅរស់នៅកន្លែងផ្សេងៗទៀតដែរ។

នៅឆ្នាំ១៩៩២ ខ្ញុំ បានមករស់នៅស្រុកខាងប្រពន្ធនៅកោះធំ បានរយៈ៨ខែ ខ្ញុំក៏នាំប្រពន្ធខ្ញុំកូនក្នុងគោលបំណងត្រឡប់មករស់នៅស្រុកកំណើតនៅភូមិស្រែពាំងវិញ ព្រោះនៅស្រុកខាងប្រពន្ធមិនមានដីសម្រាប់ធ្វើស្រែ។ ប៉ុន្តែ ខ្ញុំមិនអាចធ្វើដំណើរទៅដល់ស្រុកកំណើត ពីព្រោះនៅមានកងទ័ពខ្មែរក្រហមឈរជើងនៅតំបន់នោះនៅឡើយ។ ដូច្នេះខ្ញុំក៏សម្រេចចិត្តរស់នៅក្នុងឃុំសំរោងស្រុកភ្នំក្រវាញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ កងទ័ពវៀតណាមបានអនុញ្ញាតឲ្យជនជាតិព័រត្រឡប់ ទៅរស់នៅស្រុកកំណើតនៅភូមិស្រែពាំងវិញ ប៉ុន្តែក្រោយមកកងទ័ពវៀតណាមបានបដិសេធ ព្រោះខ្លាចខាង ប៉ុល ពត អូសទាញបាន។ ក្រោយសមាហរណកម្មឆ្នាំ១៩៩៦ប្រជាជនអាច ចាប់យកដីធ្លីសង់ផ្ទះរស់នៅរៀងៗខ្លួន។ នៅពេលនោះជនជាតិព័រក៏ចង់ទៅរស់នៅស្រុកកំណើតវិញ ប៉ុន្តែដីនៅភូមិកំណើតរបស់ខ្លួនត្រូវអតីតយោធាខ្មែរក្រហម និងប្រជាជនផ្សេងៗទៀតចាប់យកអស់ហើយដូច្នេះជនជាតិព័រទាំងនោះ ត្រូវរស់នៅបែកខ្ញែកគ្នានៅតាមកន្លែងផ្សេងៗ។ ជនជាតិព័រ បានបាត់បង់អត្តសញ្ញាណបន្តិចម្តងៗដោយសារ របបខ្មែរក្រហមជម្លៀសចេញពីភូមិស្រុក។ជនជាតិព័រមួយចំនួនបានស្លាប់ដោយសារអត់អាហារ ជំងឺ និងស្លាប់ក្នុងសម័យសង្គ្រាមនៅអំឡុងទសវត្សរ៍ឆ្នាំ៨០។ ចំណែកជនជាតិព័រដែលនៅរស់រានមានជីវិតខ្លះ មិនចង់បង្ហាញពីអត្តសញ្ញាណរបស់ខ្លួនថា ជាជនជាតិព័រឡើយមកដល់សព្វថ្ងៃនេះហើយ ក្មេងៗជំនាន់ក្រោយខ្លះក៏លែងនិយាយភាសាព័រដែរ។ ទោះបីយ៉ាងណាខ្ញុំចង់ឲ្យមានថែរក្សាភាសាវប្បធម៌របស់ជនជាតិព័រ និងចង់ឲ្យជនជាតិព័រមានការអភិវឌ្ឍន៍ទៅថ្ងៃខាងមុខ។ **សោម ប៊ុនថន**

# រៀនប្រវត្តិសាស្ត្រដើម្បីបញ្ជៀសការស្អប់ខ្ពើម និងការគុំគួន

ការបណ្តុះបណ្តាលសិស្សានុសិស្សឲ្យយល់ដឹងពីប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិ សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺជាការចាំបាច់សម្រាប់សិស្សានុសិស្ស និងយុវជនឲ្យស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឯងច្បាស់លាស់ ដើម្បីត្រិះរិះពិចារណានិងអាចដោះស្រាយបញ្ហាដែលបានកើតឡើងពី អតីតកាល បច្ចុប្បន្ន និងពេលអនាគត។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំយុវជន និងកីឡាបង្កើតនូវវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅតាមសាលារៀនចំនួន៧ ក្នុងស្រុកអន្លង់វែង។

នៅព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ត្រូវបានធ្វើឡើងនៅអនុវិទ្យាល័យត្រពាំងប្រិយ៍ក្នុងស្រុកអន្លង់វែងដែលមានសិស្សានុសិស្សចូលរួមសរុបចំនួន៥៦នាក់។



សិស្សានុសិស្សកំពុងបំពេញសំណួរស្ទាបស្ទង់មតិ

វិស័យអប់រំបានធ្វើឲ្យយុវជនលូតលាស់ ហើយវិស័យអប់រំនេះបានជួយជំរុញឲ្យយុវជន និង សិស្សានុសិស្សស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួន និងស្ថានភាពជាក់ស្តែងដែលសង្គមជាតិរបស់ខ្លួនបានជួបប្រទះបើទោះបីជាយុវជន ឬសិស្សានុសិស្សទាំងនោះមិនបានឆ្លងកាត់សង្គ្រាម និងអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ។

ការអប់រំសិស្សានុសិស្ស ឬយុវជនឲ្យយល់ដឹងស៊ីជម្រៅពីប្រវត្តិសាស្ត្ររបស់ខ្លួន គឺត្រូវការរយៈពេលវែង និងយូរអង្វែង ហើយត្រូវបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត។ ទោះជាយ៉ាងនេះក្តី ការអប់រំគឺជាជម្រើសមួយដ៏មានប្រសិទ្ធភាពបំផុត ដើម្បីទប់ស្កាត់ការរីករាលដាលនៃអំពើស្អប់ខ្ពើម ការរើសអើងនៅក្នុងសង្គម៖ និងជាពិសេសដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនៃអំពើឃោរឃៅ។ការរំឭកនូវរឿងរ៉ាវអតីតកាលនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)ពុំមែនបានន័យថាជាការជំរុញឲ្យយុវជន និងសិស្សានុសិស្សមានការស្អប់ខ្ពើមគុំគួន និងសោកសង្រេងចំពោះប្រវត្តិសាស្ត្រ របស់ខ្លួនឡើយប៉ុន្តែបានជំរុញយុវជននជំនាន់ក្រោយនិងសិស្សានុសិស្ស ឲ្យមានការត្រិះរិះពិចារណាឲ្យបានស៊ីជម្រៅ។ ការបន្តរស់នៅដោយមើលរំលងខ្លួនឯង និងប្រវត្តិសាស្ត្រគឺជា បញ្ហាចម្បងដែលយើងមិនអាចអភិវឌ្ឍន៍សង្គមជាតិរបស់យើងនៅថ្ងៃខាងមុខបានឡើយ។

ការពាំនាំនូវខ្លឹមសារប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)គឺជាដំណើរការមួយដ៏មានសារសំខាន់ចំពោះសិស្សានុសិស្ស និងមនុស្សជំនាន់ក្រោយ



*លោកបណ្ឌិត លី សុខឃាង ធ្វើបទបង្ហាញអំពីខ្សែភាពយន្តឯកសារដល់សិស្សានុសិស្សនៅក្នុងថ្នាក់*

ព្រោះប្រទេសកម្ពុជាទើបបានរួចផុតពីសង្គ្រាម និងរបបខ្មែរក្រហមដែលបានបន្សល់ទុកនូវការបែកបាក់ និងរបួសផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរហើយបន្តជះឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន។

យុវជនគឺជាធនធានសង្គមដ៏រឹងមាំហើយសង្គមជាតិមួយអាចរីកលូតលាស់ទៅមុខបាន លុះត្រាណាតែមានការចូលរួមពីយុវជនដែលស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឯងបានច្បាស់លាស់។

តាមរយៈវេទិកាថ្នាក់រៀននេះ សិស្សានុសិស្សក៏បានទទួលនូវចំណេះដឹងជាច្រើន តាមរយៈមេរៀនដកស្រង់ចេញពីសៀវភៅ«ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» និងការចាក់បញ្ចាំងកុនឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ក្រោយពីបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះសិស្សានុសិស្សមានចំណាប់អារម្មណ៍ដូចតទៅ ៖

ឈួង ឆេងឡុងមានទីកន្លែងកំណើតក្នុងស្រុកអន្លង់វែង និងជាសិស្សថ្នាក់ទី៩«ខ»នៃអនុវិទ្យាល័យត្រពាំងប្រិយ៍បានមានចំណាប់អារម្មណ៍ថា៖ ខ្ញុំយល់ឃើញថា អ្វីដែលជាឧបសគ្គឬមូលហេតុដែលធ្វើឲ្យខ្ញុំពុំអាចអត់ឱនឲ្យអ្នកដទៃបាន គឺនៅពេលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើឃោរឃៅយ៉ាងធ្ងន់ធ្ងរ សម្លាប់ ឬបង្កឲ្យមានស្នាមរបួសផ្លូវចិត្តមកលើបងប្អូនរបស់ខ្ញុំ។

ខ្ញុំគិតថាផលវិបាកដែលកើតឡើង ដោយការមិនចេះអត់ឱនឲ្យគ្នាគឺបង្កនូវផលប៉ះពាល់យ៉ាងខ្លាំង ពីព្រោះបើកាលណាយើងពុំចេះអត់ឱនឲ្យអ្នកដ៏ទៃនោះ អ្នកដ៏ទៃក៏ពុំចេះអត់ឱនមកលើយើងវិញដែរ ហើយប្រទេសជាតិក៏មិនទទួលបានការរីកចម្រើននិងសន្តិភាពដែរ។ ក្រោយពីខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» រួចមក ខ្ញុំយល់ឃើញថាក្នុងសង្គមខ្មែរនាសម័យនោះ គឺពុំចេះអត់ឱនអធ្យាស្រ័យឲ្យគ្នាឡើយដែលបង្កើតឲ្យមាននូវអំពើប្រល័យពូជសាសន៍ ក្នុងសង្គមជាតិទាំងមូល។ចំពោះខ្លឹមសារនៃមេរៀន ដែលខ្ញុំបានចាំជាងគេគឺពាក្យថា«កុម្មុយនីស្តឬរបបកម្ពុជាប្រជាធិបតេយ្យ»។ ខ្ញុំក៏មានចម្ងល់ថាតើនរណាឬរដ្ឋណាដែលជំរុញឲ្យ មានរបបខ្មែរក្រហមឬរបបកម្ពុជាប្រជាធិបតេយ្យ។

អាន ស្រីកា អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី៩ «ខ» នៃអនុវិទ្យាល័យត្រពាំងប្រិយ៍បានយល់ឃើញថាភាពមិនអត់ឱនឲ្យគ្នាគឺសំដៅទៅលើការគុំគួន និងការចងគំនុំគ្នាឬមិនចេះអធ្យាស្រ័យគ្នា។ ខ្ញុំគិតថាសង្គមជាតិរបស់យើងពុំអាចមានការរីកចម្រើន និងការអភិវឌ្ឍន៍បានទេដរាបណាមនុស្សជាតិទាំងមូល ពុំមានការអធ្យាស្រ័យនិងយោគយល់ដល់គ្នាទៅវិញទៅមក។

ក្រោយពីខ្ញុំបានសិក្សា ពីប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)រួចមក ខ្ញុំយល់ឃើញថាសង្គមជាតិរបស់យើងពិតជាត្រូវការជាចាំបាច់នូវការចេះអត់ឱនអធ្យាស្រ័យដល់គ្នា មិនថាតិចឬច្រើននោះទេ ប៉ុន្តែវាអាចជួយជំរុញដល់សង្គមឲ្យមានការរីកលូតលាស់លើគ្រប់វិស័យ ហើយសីលធម៌ក៏លូតលាស់ដែរ។ មេរៀនដែលខ្ញុំចាប់បាននិងយល់ដឹងខ្លះ គឺចំពោះអំពើប្រល័យពូជសាសន៍ របស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ ប៉ុន្តែ មានចំណុចមួយដែលខ្ញុំមានការងឿងឆ្ងល់ថាហេតុអ្វីបានជាមានការរើសអើងពូជសាសន៍ ឬប្រកាន់គ្នាទៅវិញទៅមក?

ទោះបីជាការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ធ្វើឲ្យសិស្សានុសិស្ស និងប្រជាជនកម្ពុជាមានផ្នត់គំនិតនិងការយល់ឃើញខុសគ្នា ទៅលើអតីតឬក្រុមគ្រួសាររបស់ខ្មែរក្រហមក៏ដោយ ប៉ុន្តែវាគឺជាវិធីមួយដ៏មានប្រសិទ្ធភាពដើម្បីដោះស្រាយ នូវរឿងរ៉ាវអតីតកាល។ អ្វីដែលជាក្តីប្រាថ្នា និងជាគោលបំណងក្នុងការអប់រំអំពីប្រវត្តិសាស្ត្រនេះ គឺដើម្បីជាការចងចាំ និងការក្រើនរំឭកទៅដល់យុវជនជំនាន់ក្រោយ ដើម្បីដំណើរការផ្សះផ្សា និងកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជា។

**ស្នួត វិចិត្រ**

# សាលក្រមសំណុំរឿង០០២/០២ ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

## ១. សេចក្តីផ្តើម

**១.** អង្គជុំនុំជម្រះសាលាដំបូង«អង្គជំនុំជម្រះ»នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «អ.វ.ត.ក.» ក្រោយពីបានទទួលសំណុំរឿងលេខ០០២/១៩-០៩-២០០៧/អវតក/អជសជ(«សំណុំរឿង០០២»)សម្រេចចេញសាលក្រមប្រឆាំងឈ្មោះនួនជា និង ខៀវ សំផន នៅក្នុងសំណុំរឿង០០២/០២។

### ១.១. ប្រវត្តិសង្ខេបនៃកិច្ចដំណើរការនីតិវិធីនៃរឿងក្តី

### ១.១.១. សំណុំរឿង០០១ និងសំណុំរឿង០០២

**២.** នៅថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០០៧សហព្រះរាជអាជ្ញាបានចេញដីកាឱ្យផ្តើមការស៊ើបសួរ ឲ្យស៊ើបសួរអនុលោមតាមវិធាន៥៣នៃវិធានផ្ទៃក្នុងដោយចោទប្រកាន់ នួន ជា, អៀង សារី,ខៀវសំផន,អៀង ធីរិទ្ធិ និងកាំង ហ្គេក អ៊ាវ ហៅឌុច ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក.។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានសម្រេចចេញដីកា បំបែកការចោទប្រកាន់ដោយបើកកិច្ចស៊ើបសួរជាសំណុំរឿងពីរផ្សេងគ្នាគឺ៖ សំណុំរឿង០០១ដែលវិសាលភាពនៃសំណុំរឿងនេះ គឺត្រូវបានកម្រិតត្រឹមការចោទប្រកាន់ប្រឆាំងនឹងឈ្មោះ កាំង ហ្គេកអ៊ាវ ពាក់ព័ន្ធនឹង មន្ទីរសន្តិសុខស-២១និងសំណុំរឿង០០២ដែលបានដាក់បញ្ចូលការចោទប្រកាន់ទាំងអស់ ដែលនៅសេសសល់។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងលើ កាំងហ្គេកអ៊ាវនៅក្នុងសំណុំរឿង០០២។

**៣.** នៅចន្លោះពីថ្ងៃទី១៩ ខែកញ្ញា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ នួន ជា,អៀង សារី,ខៀវ សំផន និងអៀង ធីរិទ្ធិ ត្រូវបានចាប់ខ្លួនតាមដីការបស់ចៅក្រម ស៊ើបអង្កេតហើយត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងអ.វ.ត.ក. និងត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងបក្សពួកគាត់ៗ ក្រោយកិច្ចស៊ើបសួរតាមផ្លូវតុលាការនៅក្នុងសំណុំរឿង០០២ អស់រយៈពេល៣ឆ្នាំដែលក្នុងអំឡុងពេលនោះបុគ្គលចំនួន៣.៨៦៦នាក់ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់



អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ

ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ការបំពារបំពាន យ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនិងការរំលោភបំពាន ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។នៅថ្ងៃទី១៣ខែមករាឆ្នាំ២០១១នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនអង្គបុរេជំនុំជម្រះបានរក្សាការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែលមានទំហំធំធេងដដែលតែបានធ្វើការកែប្រែលើចំណុចមួយចំនួន និងបានបញ្ជូនជនជាប់ចោទចំនួន៤នាក់ មកជំនុំជម្រះ។

### ១.១.២. សំណុំរឿង ០០២/០១

៤. ដើម្បីធានាដល់លទ្ធភាពនៅក្នុងការចេញសាលក្រមនៃសំណុំរឿង០០២ ឲ្យបានទាន់ពេលវេលាដោយបានពិចារណាទៅលើរយៈពេលនិងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ ព្រមទាំងការចុះខ្សោយផ្នែករាងកាយ និងវ័យចំណាស់របស់ជនជាប់ចោទទាំងអស់នោះ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះ បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោម តាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង។ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ បានកំណត់វិសាលភាពនៃជំនុំជម្រះនៅដំណាក់កាលដំបូង ក្នុងសំណុំរឿង០០២ដោយកម្រិតត្រឹមការចោទប្រកាន់ ផ្នែកអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយពោលគឺ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងផ្លាស់ទីលំនៅ ប្រជាជននោះ។ ក្រោយមកអង្គជំនុំជម្រះបានពង្រីកវិសាលភាព នៃសំណុំរឿង០០២/០១ដោយបញ្ចូលការចោទប្រកាន់ស្តីពីការសម្លាប់ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។



អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ

៥. ក្រោយពេលសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំង នឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី របស់អង្គជំនុំជំម្រះសាលាដំបូងអង្គជំនុំជម្រះតុលាការកំពូល បានប្រកាសមោឃភាពនូវដីកាសម្រេចបំបែកកិច្ច ដំណើរការនីតិវិធី និង បង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង វាយតម្លៃឡើងវិញលើវិសាលភាពនៃសំណុំរឿង០០២/០១ ក្រោយពេលអនុញ្ញាតឲ្យភាគីដាក់សេចក្តីសន្និដ្ឋានបន្ថែម។ បន្ទាប់ពី បានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីរួច ហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ជាថ្មីម្តងទៀត នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ដោយបានកម្រិតវិសាលភាពសំណុំរឿង០០២/០១ ត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងការ ផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១និងដំណាក់កាលទី២ និងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។

៦. នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះបានសម្រេចថាអៀងធីរិទ្ធ មិនមានសម្បទា ក្នុងការចូលរួមក្នុងសវនាការ ដោយសារតែឥទ្ធិពល នៃជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តទៅមុខ (ដែលទំនងជាជំងឺ Alzheimer) និង

បានសម្រេចចេញដីកាបង្គាប់ឲ្យបំបែក ការចោទប្រកាន់ប្រឆាំងនឹងសំណុំរឿង០០២ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ព្រមទាំងបាន បង្គាប់ឲ្យដោះលែងគាត់ៗនៅក្នុងអំឡុងពេលដែលគាត់កំពុងស្ថិតក្រោមការ ត្រួតពិនិត្យរបស់តុលាការអៀងធីរិទ្ធ បានទទួលមរណភាព នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ដែលជាហេតុនាំឲ្យរលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹងរូបគាត់ៗ

៧. សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ បានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ហើយសវនាការពិនិត្យភ័ស្តុតាង បានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០១៣ៗសវនាការរួមទាំង សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល បានធ្វើឡើងអស់រយៈពេលសរុបចំនួន២២២ថ្ងៃៗ បុគ្គលចំនួន៩២នាក់ បានផ្តល់ភ័ស្តុតាងនៅក្នុងអំឡុងពេលសវនាការទាំងនេះៗ បុគ្គលទាំងនោះរួមមានអ្នកជំនាញចំនួន៣នាក់ សាក្សីចំនួន៥៨នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣១នាក់ៗ ភាគីបានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលពី ថ្ងៃទី១៦ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ៗ

៨. នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា នួន ជា និងខៀវ សំផន មានពិរុទ្ធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលបន្តបន្ទាប់ទៅកាន់តំបន់ផ្សេងទៀតនិងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃហើយបានសម្រេចផ្តន្ទាទោសពួកគេឲ្យជាប់ពន្ធនាគារអស់មួយជីវិតៗ

៩. ក្រោយពេល នួន ជា,ខៀវ សំផន និងសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខរៀងៗខ្លួន ទៅអង្គជំនុំជម្រះតុលាការកំពូលអង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីការបស់ខ្លួនក្នុងសំណុំរឿង០០២/០១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ៗ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចតម្កល់ការផ្តន្ទាទោសនួនជា និង ខៀវ សំផន ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតពាក់ព័ន្ធនឹងការជម្លៀស ប្រជាជនទីក្រុងភ្នំពេញភ្លាមៗក្រោយការដួលរលំទីក្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ៗ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចតម្កល់ផងដែរនូវការផ្តន្ទាទោសលើជនជាប់ចោទពីឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ដែលបានកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៧ៗ

១០. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចច្រានចោលការផ្តន្ទាទោស ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញៗទាក់ទិនការផ្លាស់ទីលំនៅ ប្រជាជនដំណាក់កាលទី២អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចច្រានចោលការ



ខៀវ សំផន ប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ

ផ្តន្ទាទោសពីការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ អង្គជំនុំជម្រះតុលាការ កំពូលក៏បានសម្រេចច្រានចោលការផ្តន្ទាទោស នួន ជា និង ខៀវ សំផន ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយនៅទួលពោធិ៍ជ្រៃផងដែរ។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលបានស្នើ ឲ្យទទួលស្គាល់ការអនុវត្តទម្រង់ទូលាយ នៃការទទួលខុសត្រូវលើ សហឧក្រិដ្ឋកម្មរួមត្រូវបានសម្រេចថាមិនអាចទទួលយកបាន។

**១១.** ចុងក្រោយអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចតម្កល់ការផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិតចំពោះជនជាប់ចោទម្នាក់ៗដោយផ្អែកលើទំហំដ៏ធំធេងនៃឧក្រិដ្ឋកម្មការមិនយកចិត្តទុកដាក់ទាល់តែសោះ ទៅលើជោគវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេសក្រុមដែលងាយរងគ្រោះបំផុតៗមួយវិញទៀត ឧក្រិដ្ឋកម្មទាំងនោះពុំមែនជាហេតុការណ៍កើតឡើងដាច់ដោយឡែកឡើយប៉ុន្តែបានកើតឡើងក្នុងរយៈពេលយូររួមផ្សំជាមួយនឹង តួនាទីដ៏សំខាន់



នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជា

របស់ជនជាប់ចោទ។

### ១.១.៣. សំណុំរឿង ០០២/០២

**១២.** នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំង នឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ នៅក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យចាប់ផ្តើម សវនាការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០២ភ្លាមៗ ក្រោយពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សា ដេញដោលនៅក្នុងសំណុំរឿង០០២/០១ហើយបទចោទទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងសំណុំរឿង០០២/០២ត្រូវតែមានភាពជាតំណាង សមហេតុផលនៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ទាំងមូល។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា យ៉ាងហោចណាស់សំណុំរឿង០០២/០២ត្រូវបញ្ចូលការចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ ការដ្ឋានការងារសហករណ៍និងឧក្រិដ្ឋ កម្មប្រល័យពូជសាសន៍។អង្គជំនុំជម្រះសាលាដំបូងបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីអំពីវិសាលភាព សមស្របនៃសំណុំរឿង០០២/០២នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១១ និងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ នៅក្នុងសវនាការសាធារណៈថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០១៤ និងតាមរយៈសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

ក្រោយមក នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថាសំណុំរឿង០០២/០២រួមមាន ផ្នែកផ្សេងៗនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ ការដ្ឋានការងារទំនប់១ មករា សហករណ៍ត្រាំកក់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍( ជនជាតិវៀតណាមនិងជនជាតិចាម)មន្ទីរសន្តិសុខក្រាំងតាចាន់ ការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានសាងសង់ទំនប់ត្រពាំងថ្មមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានការងារទំនប់ ត្រពាំងថ្ម និងការចោទប្រកាន់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

និងការរំលោភបំពានផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ(ទូទាំងប្រទេស) និងការបោសសម្អាតផ្ទៃក្នុង។នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការ លើអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ រួមមានសហករណ៍ (រួមទាំងការប្រព្រឹត្តចំពោះពុទ្ធសាសនិក) ការដ្ឋានការងារការប្រព្រឹត្តចំពោះក្រុមគោលដៅ(ជនជាតិចាម និងជនជាតិវៀតណាមនិងអតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ) មន្ទីរសន្តិសុខនិងការបោសសម្អាតផ្ទៃក្នុងការចេញ បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍លក្ខណៈ នៃជម្លោះប្រដាប់អាវុធនិងតួនាទីរបស់ជនជាប់ចោទ។

**១៣.** នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការលើអង្គសេចក្តី នៅក្នុងសំណុំរឿង០០២/០២។ក្រុមមេធាវីការពារក្តី ខៀវ សំផនពុំមានវត្តមាននៅក្នុងសវនាការឡើយ នៅក្នុងរយៈពេលដែលនៅសេសសល់ក្នុងឆ្នាំ២០១៨នោះ(សូមមើលខបសម្ព័ន១៖ប្រវត្តិនីតិវិធី)ដែលតម្រូវឲ្យមានការពន្យារ កិច្ចដំណើរការនីតិវិធី។ ក្រុមមេធាវីការពារក្តី នួន ជា បានចូលរួមតែក្នុងសវនាការនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨ប៉ុណ្ណោះ។សវនាការពិនិត្យភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករាឆ្នាំ២០១៥ហើយបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ បន្ទាប់ពីបានធ្វើសវនាការចំនួន២៧៤ថ្ងៃ។

បុគ្គលចំនួន១៨៥នាក់បានផ្តល់ភ័ស្តុតាងនៅក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង០០២/០២ដែលរួមមានសាក្សីចំនួន១១៤នាក់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងអ្នកជំនួញចំនួន០៨នាក់។នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះបានកាត់បន្ថយវិសាលភាពនៃសំណុំរឿង០០២ដោយបានដកចេញនូវអង្គហេតុទាំងអស់ដែល មាននៅក្នុងដីការដំណោះស្រាយហើយដែលមិនត្រូវបាន បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ឬសំណុំរឿង០០២/០២និងបានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ។ ភាគីនានាបានដាក់សារណាបញ្ចប់កិច្ចពិភាក្សា ដេញដោលនៅថ្ងៃទី០២ខែឧសភាឆ្នាំ២០១៧និងបានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល ក្នុងរយៈពេលចំនួន០៩ថ្ងៃសវនាការគឺនៅចន្លោះពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ខែមិថុនាឆ្នាំ២០១៧។បន្ទាប់មកភាគីបានដាក់សារណាដែលបានកែប្រែ។

## ១.២ សេចក្តីសង្ខេបអំពីបទចោទប្រឆាំងនឹងជនជាប់ចោទ

**១៤.** ដីកាដំណោះស្រាយចោទប្រកាន់ថានៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩នួនជាហៅ«បងធំទីពីរ»បានបំពេញមុខនាទីជាអនុលេខានៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក.)ហើយក្នុងពេលជាមួយគ្នានេះដែរនួនជាមានតួនាទីផ្សេងៗទៀត នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដូចជាជារដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មានជានាយករដ្ឋមន្ត្រីស្តីទី ជាប្រធានសភាតំណាងប្រជាជននិងជាប្រធានគណៈកម្មាធិការ អចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។

**១៥.** ដីកាដំណោះស្រាយចោទប្រកាន់ថានៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករាឆ្នាំ១៩៧៩ខៀវសំផនហៅ«ហែម»«ខាង»និង«ណន»មានតួនាទីនិងមុខងារជាច្រើននៅក្នុងប.ក.ក.និងកម្ពុជាប្រជាធិបតេយ្យរួមទាំងជាប្រធានគណៈប្រធានរដ្ឋជាប្រធានមន្ទីរ នយោបាយ៨៧០ និងជាសមាជិកគណៈកម្មាធិការរបស់ប.ក.ក.។

**១៦.** លើសពីនេះទៅទៀត ដីកាដំណោះស្រាយចោទប្រកាន់ថានៅក្នុងអំឡុងពេល នៃការបំពេញមុខងារទាំងនេះជនជាប់ចោទបានប្រព្រឹត្ត( តាមរយៈសហឧក្រិដ្ឋកម្មរួម) បានរៀបចំផែនការបានញុះញង់បានបញ្ជាបានជួយនិងជំរុញនិងជាអ្នកទទួលខុសត្រូវ ក្នុងនាមជាថ្នាក់លើចំពោះបទឧក្រិដ្ឋដែលស្ថិតក្នុងសំណុំរឿង០០២/០២៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមនិងវៀតណាម ការបំពារបំពាន៖(១)ការធ្វើមនុស្សឃាតដោយចេតនា(២)ការធ្វើទារុណកម្ម(៣)ការធ្វើបាបដោយអមនុស្សធម៌(៤)ការបង្កដោយចេតនា

ឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយឬសុខភាព(៥) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយអយុត្តិធម៌ និងទៀងទាត់(៦) ការនិរទេសជនស៊ីវិលដោយខុសច្បាប់(៧) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន៖ (១)ការធ្វើមនុស្សឃាត (២)ការសម្លាប់រង្គាល (៣) ការធ្វើឲ្យទៅជាទាសករ (៤) ការនិរទេស (៥) ការដាក់ក្នុងមន្ទីរឃុំឃាំង (៦) ការធ្វើទារុណកម្ម (៧) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ (៨) អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការរំលោភផ្លូវភេទអំពើ អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថា ជាការជម្លៀសដោយបង្ខំ និងអំពើ អមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

## ២.បញ្ហាបឋម

### ២.១.យុត្តាធិការ

**១៧.** បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័ត «ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ»ដែលសំណៅចុងក្រោយនៃច្បាប់នេះត្រូវបានប្រកាសឲ្យ ប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ អនុលោមតាមមាត្រា ២(១) នៃកិច្ចព្រមព្រៀង និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក. មានយុត្តាធិការបុគ្គលលើ «មេដឹកនាំជាន់ខ្ពស់»នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលទាំងឡាយ «ដែលទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តិនៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

**១៨.** សហចៅក្រមស៊ើបអង្កេត បានសម្រេចថាខ្លួនមានយុត្តាធិការលើ នួន ជា និង ខៀវ សំផន ដោយយល់ឃើញថា ពួកគាត់គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុង ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ផ្អែកលើភ័ស្តុតាងដ៏រឹងមាំ និងច្រើនលើសលប់និងយោងតាមការសារភាព របស់ពួកគេអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាជនជាប់ចោទគឺជាកម្មាភិបាលខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ លក្ខណៈនៃមុខនាទីរបស់ពួកគាត់បានបំពេញលក្ខខណ្ឌ ក្នុងការកំណត់ពួកគេថាជាមេដឹកនាំជាន់ខ្ពស់។ ការសម្រេចស្រដៀងគ្នានេះ ពុំត្រូវបានជំទាស់នៅក្នុងបណ្ដឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/០១នោះឡើយ។ គ្មានភ័ស្តុតាងដែលអាចជំទាស់ទៅលើការសម្រេចនេះនោះទេនៅក្នុងសំណុំរឿង០០២/០២។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាខ្លួនមានយុត្តាធិការបុគ្គលលើ នួន ជា និង ខៀវ សំផន។

**១៩.** ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឧក្រិដ្ឋកម្មសង្គ្រាម និងបទចោទនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជនជាប់ចោទត្រូវចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ថាបានប្រព្រឹត្តនៅក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលឧក្រិដ្ឋកម្មទាំងអស់នេះស្ថិតនៅក្នុង យុត្តាធិការនៃរឿងក្ដីនេះនិងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ដូចមានចែងនៅក្នុងមាត្រា១ និងមាត្រា

៩ នៃកិច្ចព្រមព្រៀង និងមាត្រា១ និងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក.។

## ២.២. គោលការណ៍នីត្យានុកូលភាព

**២០.**មាត្រា១១(២)នៃសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សចែងថា៖

គ្មានជនណាម្នាក់ត្រូវសម្រេចឲ្យជាប់ពិរុទ្ធ ពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើសកម្មភាពឬអកម្មណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ផ្អែកតាមច្បាប់ជាតិឬច្បាប់អន្តរជាតិនៅពេលដែលអំពើនោះត្រូវបាន ប្រព្រឹត្តិនោះឡើយ។ ដូចគ្នានេះមិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តិបទល្មើសឡើយ។

**២១**.គោលការណ៍នីត្យានុកោលភាពកម្ពុជា និងគោលការណ៍នីត្យានុកូលភាពអន្តរជាតិដែលជាប់ទាក់ទងនឹងគោលការណ៍ទូទៅគឺ និងគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង និងគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែងតម្រូវឲ្យច្បាប់ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការ ទទួលខុសត្រូវព្រហ្មទណ្ឌមានភាពច្បាស់លាស់ពិតប្រាកដ និងមិនប្រតិសកម្ម។ ហេតុនេះនៅក្នុងបរិបទដាក់លាក់នៃ អ.វ.ត.ក. គោលការណ៍នីត្យានុគោលភាពតម្រូវឲ្យបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ ត្រូវតែមាននៅក្នុងច្បាប់កម្ពុជាឬច្បាប់អន្តរជាតិ (រួមទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិ) ដែលមានអត្ថិភាពនៅចន្លោះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ហើយជនជាប់ចោទអាចប្រមើលឃើញ និងអាចដឹងបានផងដែរ។ គោលការណ៍នេះមិនបានហាមឃាត់អង្គជំនុំជម្រះក្នុងការធ្វើការបកស្រាយ និងបញ្ជាក់បំភ្លឺអំពីច្បាប់ ឬផ្អែកលើសេចក្តីសម្រេចនានានៅក្នុងរឿងក្តីផ្សេងៗទៀតនោះទេ បើទោះបីជារឿងក្តីទាំងនោះកើតឡើងនៅក្រោយ អំឡុងពេលដែលស្ថិតនៅក្រោមការពិនិត្យនេះក៏ដោយ។ យ៉ាងណាមិញ គោលការណ៍នេះពិតជាហាមឃាត់អង្គជំនុំជម្រះមិនឲ្យ «បង្កើតច្បាប់ថ្មី ឬបកស្រាយច្បាប់ ដែលមានស្រាប់ឲ្យហួសពីដែនកំណត់សមហេតុផល នៃការបញ្ជាក់បំភ្លឺដែលអាចទទួលយកបាននោះឡើយ។ នៅក្នុងករណីនេះអង្គជំនុំជម្រះពិចារណាឃើញថា ខ្លួនត្រូវមានកាតព្វកិច្ចគោរពតាមគោលការណ៍នៃការបកស្រាយតឹងរ៉ឹងលើច្បាប់ព្រហ្មទណ្ឌដូចមានចែងនៅក្នុងមាត្រា ៥នៃក្រមព្រហ្មណ៍ទណ្ឌកម្ពុជាដែលចែងថា ច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ហើយហាមឃាត់ការពន្យាតនិយមន័យនៃឧក្រិដ្ឋកម្មតាមទិសភាព។ នៅក្នុងករណីមានភាពស្រពិចស្រពិល និយមន័យនោះត្រូវបកស្រាយជាប្រយោជន៍ដល់ជនត្រូវចោទឬជនជាប់ចោទ (គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ)។

**២២.** អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា យុត្តាធិការរបស់ អ.វ.ត.ក. ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកម្រិតដោយនិយមន័យនៃឧក្រិដ្ឋកម្មនេះ ដោយសារតែវាត្រូវបានកំណត់ដោយច្បាប់អន្តរជាតិនៅពេលដែលមានការប្រព្រឹត្តអំពើឧក្រិដ្ឋ ដូចបានចោទប្រកាន់ទាំងនោះ។ អង្គជំនុំជម្រះ ពិចារណាឃើញថាករណីនេះត្រូវអនុវត្តដូចគ្នាចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ដោយហេតុថាកាលពីមុនមកអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលមិនបានធ្វើការវាយតម្លៃថា កាលពីមុនមកអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលមិនបានធ្វើការវាយតម្លៃថា តើឧក្រិដ្ឋកម្មនិងទម្រង់នៃការទទួលខុសត្រូវដែលចោទជាបញ្ហានៅក្នុង សំណុំរឿង០០២/០២ ត្រូវបាន ឬមិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិឬច្បាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥ ទេនោះ ហេតុនេះហើយអង្គជំនុំជម្រះនឹងធ្វើការ វាយតម្លៃនៅក្នុងសាលក្រមនៃសំណុំរឿងនេះ។

**២៣.** ចំពោះបទឧក្រិដ្ឋនិងទម្រង់នៃការទទួលខុសត្រូវជនជាប់ចោទត្រូវតែ អាចប្រមើលឃើញគ្រប់គ្រាន់ថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែងក្នុងលក្ខណៈជាទូទៅពុំចាំបាច់ក្នុងលក្ខណៈដាក់លាក់ ចំពោះជនជាប់ចោទឡើយ

ដោយសារលក្ខណ្ឌនេះត្រូវកំណត់ដោយ«ការវិភាគជាសត្យានុម័ត»។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថាជាការសមស្របដែលត្រូវពិចារណាទៅលើមុខងារជាន់ខ្ពស់របស់ជនជាប់ចោទនៅក្នុងការកំណត់ថា តើគោលការណ៍នីត្យានុកូលភាពត្រូវបានគោរពសម្រាប់បទឧក្រិដ្ឋនិងទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់នោះដែរឬទេ។ លើសពីនេះទៀត អង្គជំនុំជម្រះអាចពិចារណាទៅលើច្បាប់ជាតិនៅក្នុងពេលវាយតម្លៃថា តើអាចប្រមើលឃើញជាមុនថាអំពើដែលចោទជាបញ្ហានោះអាចនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ទៅតាមលក្ខណៈដែលអំពើនោះត្រូវចោទប្រកាន់ដែរឬទេ។ទោះបីជាយ៉ាងណាការទទួលស្គាល់បទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមច្បាប់ជាតិមិនតម្រូវឲ្យអំពើនោះអាចផ្តន្ទាទោសបានដោយអ. វ. ត. ក. នោះទេប្រសិនបើវាមានមូលដ្ឋាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិ។

២៤. បើតាមមេធាវីការពារក្តី ខៀវ សំផន វិធីសាស្ត្រដែលអនុវត្តដោយអង្គជំនុំជម្រះតុលាការកំពូល បានប្រដូចភាពអាចប្រមើលឃើញជាមុនបានថា ជាបទល្មើសទៅនឹងភាពអាចប្រមើលឃើញជាមុន ពីចរិតលក្ខណៈនៃអំពើដែលអាចនាំឲ្យមានពិរុទ្ធដែលផ្ទុយទៅនឹងគោលការណ៍នីត្យានុកូលភាព។ មេធាវីការពារក្តី ខៀវ សំផន បន្តយោងទៅលើករណីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលកំណត់ថាគោលការណ៍នីត្យានុកូលភាពតម្រូវលក្ខខណ្ឌថា «បទល្មើសត្រូវតែកំណត់ចេញឲ្យបានច្បាស់លាស់ ដែលអាចជាច្បាប់អន្តរជាតិ។លក្ខខណ្ឌនេះត្រូវបំពេញនៅពេលដែល បុគ្គលអាចដឹងតាមពាក្យពេចន៍បទបញ្ញត្តិពាក់ព័ន្ធ ថាអំពើសកម្មភាពនិងអកម្មណាដែលនឹងនាំ ឲ្យខ្លួនមានការទទួលខុសត្រូវព្រហ្មទណ្ឌ»។

មេធាវីការពាក្តីអះអាងថាផ្ទុយពីលក្ខខណ្ឌតម្រូវនេះអង្គជំនុំជម្រះតុលាការកំពូលបានប្រកាន់ជំហរថា ជនជាប់ចោទមានលទ្ធភាពគ្រប់គ្រាន់ដែលអាចឲ្យខ្លួន «យល់ដឹងថាអំពើដែលខ្លួនប្រព្រឹត្តគឺជាបទល្មើសក្នុងន័យ ដែលគេអាចយល់ដឹងជាទូទៅបានដោយពុំចាំបាច់ យោងទៅរកបទបញ្ញត្តិជាក់លាក់ណាមួយនោះទេ» ដូច្នេះហើយលក្ខខណ្ឌនេះមិនតម្រូវ «ឲ្យមានការវិភាគលើពាក្យពេចន៍បច្ចេកទេស ពាក់ព័ន្ធនឹងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ»។

មេធាវីការពារក្តី ខៀវ សំផន អះអាងថាវិធីសាស្ត្រនេះពុំអាចទទួលយកបានទេ ហើយវាផ្ទុយនឹងកម្មវត្ថុ និងគោលបំណងនៃគោលការណ៍ជាសារវន្តដែលមិនអាចធ្វើបដិប្បញ្ញាត្តិបានឡើយ ទោះបីជានៅពេលប្រទេសមានសង្គ្រាមឬអាសន្នក៏ដោយ។ បើតាមមេធាវីការពារក្តីបទល្មើសព្រហ្មទណ្ឌត្រូវមានលក្ខណៈជាក់លាក់ច្បាស់លាស់ មិនស្រពិចស្រពិលនៅគ្រប់កាលៈទេសៈទាំងអស់។ អាស្រ័យហេតុនេះ មេធាវីការពារក្តីអះអាងថាចរិតលក្ខណៈនៃអំពើរបស់ជនជាប់ចោទ និងលក្ខណៈនៃបទល្មើសដែលបានកើតចោទប្រកាន់មិនអាចយកមកជំនួសសន្តិភាពនៃនិយមន័យជាក់លាក់ និងច្បាស់លាស់នៃបទឧក្រិដ្ឋដែលចោទជាបញ្ហានោះឡើយ។មេធាវីការពារក្តីសន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូងត្រូវងាកចេញពីសំអាង ហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល។

២៥. មេធាវីការពារក្តី ខៀវ សំផន អះអាងបន្ថែមទៀតថាការផ្តែកទៅលើភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មអនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូល រួចផុតពីកាតព្វកិច្ចពិនិត្យមើលភាពអាចដឹងបានរបស់ ខៀវ សំផន ថាមានយុត្តិសាស្ត្រនាសម័យក្រោយសង្គ្រាម។ មេធាវីការពារក្តីគូសបញ្ជាក់ថានៅពេលកំណត់ថា តើវិធានជាក់លាក់មានអត្ថិភាព នៅក្រោមទំនៀមទម្លាប់អន្តរជាតិដែរឬទេ នោះសំខាន់បំផុតត្រូវមានភាពម៉ត់ចត់ និងការប្រុងប្រយ័ត្នបំផុត ក្នុងការកំណត់អំពីភាពអាចប្រមើលឃើញជាមុនថា ជាបទល្មើនិងភាពអាចដឹងជាមុនអំពីវិធាននោះ។ ទោះបីជាមេធាវីការពារក្តីខៀវ សំផន លើកទឡ្ហីករណ៍ទាំងនេះនៅក្នុងបរិបទនៃសហឧក្រិដ្ឋកម្មរួម និងការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិក៏ដោយប៉ុន្តែទឡ្ហីករណ៍ទាំងនេះ ក៏អនុវត្តជាទូទៅលើគោលការណ៍នីត្យានុកោលភាពផងដែរ ដូចច្នេះហើយទឡ្ហីករណ៍ទាំង

នេះនឹងត្រូវលើកយកមកដោះស្រាយនៅក្នុងផ្នែកនេះ។ ភាគីផ្សេងទៀតមិនបាន ដាក់សារណាពាក់ព័ន្ធនឹងករណីនេះនោះទេ។ អង្គជំនុំជម្រះនឹងដោះស្រាយចំពោះទឡ្ហីករណ៍ ដែលពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមនិងការធ្វើមនុស្សឃាត នៅក្នុងផ្នែកពាក់ពន្ធនឹងច្បាប់ជាធរមាន។

**២៦.** អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ដែលបានជំទាស់ទៅលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះគោលការណ៍នីត្យានុកូលភាពបញ្ចូលនូវ លក្ខខណ្ឌតម្រូវពីរផ្សេងគ្នានៅក្រោមគោលការណ៍នោះ ពោលគឺបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ ដែលទទួលស្គាល់ក្រោមច្បាប់កម្ពុជាឬច្បាប់អន្តរជាតិនៅពេលដែលការប្រព្រឹត្តបទល្មើសត្រូវបានចោទប្រកាន់ហើយថាបទល្មើសនិងទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវតែអាចប្រមើលឃើញជាមុនបានគ្រប់គ្រាន់ និងអាចដឹងថាមានច្បាប់ចែង។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងនឹងពិនិត្យមើលទិដ្ឋភាពខុសគ្នាទាំងនេះ។

**២៧.** វិធីសាស្ត្រអនុវត្តដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/០១ បង្ហាញយ៉ាង ច្បាស់ថាអង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់ពីភាពចាំបាច់ក្នុងការបញ្ជាក់ថា«រាល់បទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ត្រូវមានអត្ថិភាពស្ថិតក្រោមច្បាប់ជាតិឬអន្តរជាតិ ក្នុងពេលអំពើល្មើសដែលបានចោទប្រកាន់នោះបានកើតឡើង។

លើសពីនេះទៀតអង្គជំនុំជម្រះតុលាការកំពូល ក៏បានទទួលស្គាល់ភាពចាំបាច់ក្នុងការកំណត់និយមន័យ ធាតុផ្សំសត្យានុម័តនិងធាតុផ្សំអត្តនោម័តិ នៃបទល្មើសជាមូលដ្ឋាន។ អង្គជំនុំជម្រះតុលាការកំពូលក៏បាន យោងទៅការវិភាគអង្គច្បាប់និងសំអាងហេតុរបស់ខ្លួន នៅក្នុងសំណុំរឿង០០១ នៅពេលខ្លួនពិចារណាសំណុំរឿង០០២/០១ថាតើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់ឬមិនត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥ ការវិភាគដែលបានយោងខាងលើនេះគឺមានលក្ខណៈទូលាយហើយបានអនុវត្តវិធីសាស្ត្រហ្មត់ចត់ និងប្រុងប្រយ័ត្ននៅពេលធ្វើការកំណត់ថាត្រូវបាន កំណត់និយមន័ដោយរបៀបណាក្នុងអំឡុងយុត្តាធិការ ពេលវេលារបស់អ.វ.ត.ក.។ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវសំផនមិនមានការចង្អុលបញ្ជាក់ឡើយថាអង្គជំនុំជម្រះតុលាការកំពូលខកខានមិនបានតម្រូវឲ្យមាននិយមន័យច្បាស់លាស់ អំពីឧក្រិដ្ឋកម្មនៅពេលវេលាដែលពាក់ព័ន្ធដោយសារតែការពឹងផ្អែកទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះទេ។

**២៨.** អង្គជំនុំជម្រះយល់ឃើញថា ការសំអាងរបស់មេធាវីការពារក្តី ខៀវ សំផន លើសាលក្រមតទល់នឹងប្រទេសលីទុយអានី របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប បង្ហាញនូវការជ្រើសរើសបែបលម្អៀងមួយលើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។

នៅក្នុងអត្ថបទពាក់ព័ន្ធតុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថាៈ យោងតាមគោលការណ៍ទាំងនេះ បទល្មើសត្រូវតែកំណត់ឲ្យបានច្បាស់លាស់ដោយច្បាប់មិនថាច្បាប់ជាតិឬច្បាប់អន្តរជាតិនោះទេ។ លក្ខខណ្ឌនេះត្រូវបានបំពេញនៅពេលដែលបុគ្គលអាចដឹងតាមពាក្យពេចន៍នៃបទប្បញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ត្រូវមានជំនួយពីការបកស្រាយរបស់តុលាការនិងប្រឹក្សាច្បាប់ច្បាស់លាស់ថាតើអំពើសកម្មនិងអំពើអកម្មណាដែលនឹងនាំឲ្យខ្លួនមានការទទួលខុសត្រូវព្រហ្មទណ្ឌ។

ទោះបីជាយ៉ាងណា មាត្រា៧(១) នៃអនុសញ្ញាសិទ្ធិមនុស្សអ៊ឺរ៉ុបតម្រូវឲ្យមានវិធីសាស្ត្រចំនួនពីរ។ លក្ខខណ្ឌទីមួយតម្រូវឲ្យពិនិត្យមើលថា តើមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ដែរឬទេ ដោយពិចារណាទៅលើស្ថានភាពច្បាប់ នៅក្នុងអំឡុងពេលនៃបទល្មើសដែលត្រូវបាន ចោទប្រកាន់ដើម្បីគាំទ្រការសម្រេចថាមានពិរុទ្ធភាព។ លក្ខខណ្ឌទីពីរត្រូវបាន«កំណត់និយមន័យដោយច្បាស់ ដែលអាចប្រមើលឃើញជាមុនថា

បទល្មើសនិងអាចដឹងថាមានច្បាប់ចែងគ្រប់គ្រាន់ ដើម្បីឲ្យអ្នកប្រព្រឹត្តអាចដឹងនៅពេលនោះថា អំពើសកម្មនិងអសកម្មណាមួយដែលនឹងអាចឲ្យ គាត់ទទួលខុសត្រូវព្រហ្មទណ្ឌលក្ខខណ្ឌតម្រូវឲ្យមានមូលដ្ឋានច្បាប់ច្បាស់លាស់ ពុំរារាំង លក្ខខណ្ឌដែលចែងថានៅក្នុងវិស័យច្បាប់ រួមទាំងច្បាប់ព្រហ្មទណ្ឌផងដែរនោះមានធាតុផ្សំមិនអាច ខ្វះបាននៃការបកស្រាយតាមផ្លូវតុលាការជាពិសេសតែងតែទាមទារនូវលក្ខខណ្ឌនៃការបញ្ជាក់បំភ្លឺនូវចំណុចស្រពិចស្រពិល និងលក្ខខណ្ឌនៃការសម្របទៅតាមកាលៈទេសៈដែលប្រែប្រួលឡើយ។

២៩.ក្នុងករណីនេះអង្គជំនុំជម្រះកត់សម្គាល់ឃើញថាតុលាការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់ថាច្បាប់ដែលផ្តល់នូវមូលដ្ឋានគតិយុត្តិចំពោះនិយមន័យនៃឧក្រិដ្ឋកម្ម អាចរួមមានច្បាប់សរសេរជាលាយលក្ខណ៍អក្សរ និងច្បាប់មិនសរសេរជាលាយលក្ខណ៍អក្សរ ហើយបានសម្រេចថា «មាត្រា៧នៃអនុសញ្ញានេះមិនអាចបកស្រាយបានថា ជាការហាមឃាត់ការបញ្ជាក់បំភ្លឺដោយប្រុងប្រយ័ត្ន លើវិធាននៃការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈការបកស្រាយតាមផ្លូវតុលាការទៅតាមករណីនីមួយៗប្រសិនបើការវិវត្តដែលកើតចេញពីករណីនេះស៊ីសង្វាក់គ្នាជាមួយនឹងលក្ខណៈនៃបទល្មើសនិងអាចប្រមើលឃើញជាមុនបានយ៉ាងសមស្រប និងជារឿយៗមានភាពចាំបាច់នៅពេលដោះស្រាយ ចំពោះឧក្រិដ្ឋកម្មនានាក្រោមច្បាប់ទម្លាប់អន្តរជាតិដោយមិនចាំបាច់បញ្ចូលនៅក្នុងយុត្តាធិការតុលាការជាតិ។

៣០. នៅក្នុងការវិភាគទៅលើ លក្ខខណ្ឌនៃភាពអាចប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើគោលបំណងនៃគោលការណ៍នីត្យានុកូលភាព ដែលត្រូវធានាថាជនជាប់ចោទមិនត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះអំពើដែលពុំអាចព្យាករណ៍ទុកជាមុន បានថាជាបទល្មើសនៅពេលដែលអំពើនោះបានកើតឡើង។ ជាពិសេសនៅក្នុងការវិភាគទៅលើភាពអាចប្រមើលមើលឃើញជាមុន ថាជាបទល្មើសអង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទជាបញ្ហាជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់និងដែលថាអំពើរបស់គាត់គឺជា អំពើឧក្រិដ្ឋក្នុងន័យដែលបានយល់ជាទូទៅដែរឬទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់អំពីបញ្ហាធ្ងន់ធ្ងរ ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របទៅនឹងការយល់ឃើញ ដែលថាកាលណាឧក្រិដ្ឋកម្មកាន់តែមានធ្ងន់ធ្ងរ កាន់តែធ្វើឲ្យជនជាប់ចោទបានដឹងជាទូទៅថាអំពើបែបនោះអាចនឹងត្រូវផ្តន្ទាទោស។

៣១. ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ចំពោះភាពអាចដឹងថាមានច្បាប់ចែង អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាអង្គជំនុំជម្រះតុលាការកំពូលមិនបានសំអាងលើភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្ម ដើម្បីជៀសវាងមិនធ្វើការវាយតម្លៃថា តើជនជាប់ចោទអាចដឹងថាមានច្បាប់ចែងអំពីឧក្រិដ្ឋកម្មទាំងនោះដែរ ឬយ៉ាងណានោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញយ៉ាងច្បាស់ថា ទាំងបទល្មើសនិងទម្រង់នៃការទទួលខុសត្រូវ ត្រូវមានអត្ថិភាពនៅក្រោមច្បាប់ជាតិឬច្បាប់អន្តរជាតិ នៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ ហើយថាក្រៅពីសន្ធិសញ្ញានានានៅមានច្បាប់នានា ដែលបានផ្អែកលើទំនៀមទម្លាប់អាចយកមកធ្វើជាសំអាងក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចយល់ដឹងគ្រប់គ្រាន់បានថាមានច្បាប់ចែង។អង្គជំនុំជម្រះតុលាការកំពូលបានសំអាងលើករណីនេះរួមជាមួយនឹងតួនាទីរបស់ជនជាប់ចោទអាចដឹងថាមានច្បាប់ចែងគ្រប់គ្រាន់អំពីឧក្រិដ្ឋកម្មទាំងនោះ។

៣២. អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាពត្រូវបានបដិសេធចោល។

## ២.៣. សំណុំរឿង

៣៣. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងបន្ទាប់ពី រាល់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំ

ណោះស្រាយត្រូវបានសម្រេច នៅថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១១។ នៅពេលទទួលបាន ការជូនដំណឹងអំពីបទចោទ ជនជាប់ចោទ និងបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជនជាប់ចោទទទួលបានការអនុញ្ញាតឲ្យចូលមើលសំណុំរឿង ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីទាំងមូល។ ហេតុដូច្នេះ នួន ជា ទទួលបានការអនុញ្ញាតឲ្យចូលមើលសំណុំរឿងចាប់តាំង ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ហើយ ខៀវ សំផន អាចចូល មើលសំណុំរឿង ចាប់តាំងពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

៣៤. គិតត្រឹមពេលបញ្ចប់នៃការដាក់សេចក្តីសន្និដ្ឋាន បិទបញ្ចប់កិច្ចពិភាក្សាដេញដោលឯកសារ ចំនួន១៤.៤៧៦ និងសម្ភារមួយចំនួនទៀត ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន៨៧ (៣) នៃវិធានផ្ទៃក្នុង នោះគឺនៅតែជាឯកសារ «សម្ងាត់» ដដែល។ភាគច្រើនលើស លប់នៃសម្ភារទាំងនោះនៅតែរក្សាចំណាត់ថ្នាក់ ដដែលជាចំណាត់ថ្នាក់ដែលត្រូវបានចាត់ថ្នាក់ ដោយស្វ័យប្រវត្តិក្នុងអំឡុងកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង០០២ប៉ុន្តែឯកសារជាច្រើនដែលត្រូវបាន ដាក់ដេញដោលក្នុងសវនាការ សាធារណៈត្រូវបាន ចាត់ថ្នាក់ជាឯកសារសាធារណៈនិង បញ្ចូលក្នុងគេហទំព័ររបស់តុលាការ ដែលភាគីអាចបើកមើលបាន។ទោះបីជាយ៉ាងនេះក្តី យុត្តិកម្មដាក់លាក់មួយចំនួននៃ ការមិនបង្ហាញឯកសារជាសាធារណៈ គឺនៅតែមានសុពលភាពដដែលការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារដែលត្រូវ បានប្រមូលនិងបានធ្វើឡើងក្នុងអំឡុង កិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង០០២ លែងបង្កជាហានិភ័យនៃការរំលោភទៅលើសិទ្ធិរបស់ភាគី ឬសុចរិតភាពនៃកិច្ចស៊ើបសួរ ទៀតហើយ។ហេតុដូច្នេះ ដើម្បីឈានដល់ការចេញសាលក្រមនិងការពឹងផ្អែក និង/ឬការយោងទៅលើព័ត៌មានដែលត្រូវ បានចាត់ចំណាត់ថ្នាក់ជាសាធារណៈនោះ អង្គជំនុំជម្រះត្រូវ ពិចារណាថាតើមានយុត្តិកម្មណាមួយ ចំពោះការរក្សាការ សម្ងាត់ដែលបន្ថយហួសពីការរក្សាការសម្ងាត់នៅក្នុងអំឡុង កិច្ចស៊ើបសួរដែរឬទេ។តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថាការសម្ងាត់ លែងមានភាពចាំបាច់ទៀត ហើយសម្រាប់ឯកសារ ដែលបានបង្ហាញជាសាធារណៈនៅ ក្នុងសាលក្រមនេះ។

## ២.៤. គោលការណ៍នៃភស្តុតាងនិងនីតិវិធី

### ២.៤.១.សេចក្តីផ្តើម

៣៥. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងលើកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក. ។ការណែនាំក្នុងបទដ្ឋាននីតិវិធីក៏អាចត្រូវបានស្វែងរកពីច្បាប់អន្តរជាតិនៅក្នុងករណីដែលនីតិវិធីដែលមានស្រាប់មិន អាចដោះស្រាយចំពោះបញ្ហាពិសេសណាមួយ ឬប្រសិនបើ មានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយឬអនុវត្ត នីតិវិធីនោះ ឬប្រសិនបើនីតិវិធីទាំងនោះ មិនស៊ីចង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។ វិធានផ្ទៃក្នុងប្រចាំបញ្ចូលនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់យកមកអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. និងប្រើប្រាស់ នីតិវិធីអន្តរជាតិ ដើម្បីធានានូវយុត្តិធម៌ ភាពត្រឹមត្រូវ និង ដំណើការសមស្របនៃច្បាប់។ នៅក្នុងក្របខណ្ឌនេះ អង្គជំនុំ ជម្រះត្រូវតែធានាថាការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់ រហ័ស ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ ជនជាប់ចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជន រងគ្រោះនិងសាក្សី។

៣៦. អង្គជំនុំជម្រះកត់សម្គាល់ថា សាលដីកាលើប ណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ដែលបានប្រកាសនៅ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ បានលើកឡើងអំពីនីតិវិធីមួយ ចំនួនដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការ ជំនុំជម្រះលើសំណុំរឿង០០២/០១ ដោយបានផ្តល់ជាគោល ការណ៍ណែនាំសម្រាប់ការដឹកនាំកិច្ចដំណើរការនីតិវិធីនាពេលអនាគត។ ដោយសារតែសាលដីកាលើបណ្តឹងសាទុក្ខនៃ សំណុំរឿង០០២/០១ត្រូវបានប្រកាសប្រហែលជារយៈពេល ប្រាំពីរសប្តាហ៍(សវនាការរយៈពេល១៧ថ្ងៃ)មុនពេលបញ្ចប់ សវនាការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ហេតុ

នេះហើយអង្គជំនុំជម្រះសាលាដំបូង ពុំទទួលបានផលប្រយោជន៍អ្វីស្មើរតែទាំងអស់ ពីគោលការណ៍ណែនាំនេះសម្រាប់ការដឹកនាំសវនាការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២នេះទេ។ នៅក្នុងចំណុចជាច្រើន សេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឆ្លុះបញ្ចាំងនូវ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២។ មិនមានការចម្លងនូវការទទួលខុសត្រូវ ព្រហ្មទណ្ឌពីសំណុំរឿង០០២/០១ មកបញ្ចូលក្នុងសំណុំរឿង០០២/០២នោះដែរ។

ក្នុងបរិបទនេះ ទោះបីជាមានចំណុចរួមគ្នា ដោយផ្នែកៗរវាងភ័ស្តុតាងផ្ទាល់មាត់ និងភ័ស្តុតាងជាឯកសារនៅក្នុងសំណុំរឿងនីមួយៗក៏ដោយតែនៅពេលនេះអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើសម្ភារទាំងអស់ ដែលមាននៅចំពោះមុខខ្លួននោះ៖ អាចមានការធ្វើសេចក្តីសន្និដ្ឋានផ្សេងគ្នារួមទាំងទៅលើភ័ស្តុតាងនិងអង្គសេចក្តីនានាដែលពាក់ព័ន្ធរួមគ្នា។

នៅពេលវាយតម្លៃទៅលើ សម្ភារពីក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធនឹងបញ្ហានានា នៅក្នុងសំណុំរឿង០០២/០២ អង្គជំនុំជម្រះជឿជាក់ថាសិទ្ធិតទល់ពេញលេញក្នុងរឿងក្តីត្រូវបានការពារ។ក្នុងចំណុចនេះ ពាក់ព័ន្ធនឹងការវាយតម្លៃទៅលើភ័ស្តុតាងផ្ទាល់មាត់ដែលបាន ស្តាប់នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះនឹងពិចារណាថាតើភាគីត្រូវបាន រារាំងមិនឲ្យពិនិត្យទៅលើការបំភ្លឺលើបញ្ហានានានៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ នៅក្នុងតុលាការដែរឬទេ។អង្គជំនុំជម្រះបដិសេធ អំណះអំណាងដែលគ្មានមូលដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាភ័ស្តុតាងផ្ទាល់មាត់ពីក្នុងសំណុំរឿង ០០២/០១(តាមរយៈប្រតិចារឹកក្លាយជាភ័ស្តុតាងឯកសារ នៅក្នុងសំណុំរឿង០០២/០២។

**៣៧.** អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្តីពីផលប៉ះពាល់ដោយសាលដីកានៃសំណុំរឿង០០២/០១ មកលើការបញ្ចប់កិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០២។ គ្មានភាគីណាមួយបានដាក់សេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរអំពីបញ្ហានេះឡើយ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ ដែលមួយផ្នែក ត្រូវបានគ្រោងពិភាក្សាលើ«ផលប៉ះពាល់ដោយ សាលដីការ របស់អង្គជំនុំជម្រះតុលាការកំពូលនេះភាគីពុំបានលើកឡើងបញ្ហាណាមួយ ដែលពួកគេយល់ឃើញថា អាចពន្យាពេលការបញ្ចប់ការពិភាក្សាដេញដោល ភ័ស្តុតាងនៅក្នុងរឿងក្តីនេះទេ។ទោះបីជាយ៉ាងនេះក្តី ភាគីបានធ្វើសេចក្តីសន្និដ្ឋាន ដោយផ្អែកលើសាលដីកានៃសំណុំរឿង០០២/០១ ពាក់ព័ន្ធនឹងគោលការណ៍គតិយុត្តិដែល គ្រប់គ្រងទៅលើការពិចារណាលើភ័ស្តុតាង។ ក្នុងករណីមានភាពពាក់ព័ន្ធសេចក្តីសន្និដ្ឋាននិងយុត្តិសាស្ត្រ ដែលអង្គជំនុំជម្រះតុលាការកំពូល បានលើកឡើងនឹងត្រូវដោះស្រាយនៅក្នុងសាលក្រមនេះ។

### ២.៤.២. បន្ទុកនិងបទដ្ឋាននៃភ័ស្តុតាង

**៣៨.** ជនជាប់ចោទត្រូវបានសន្មតថា គ្មានទោសដរាបណា ពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ។ ពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ។ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង។ដើម្បីអាចផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែមានជំនឿ អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីដោះស្រាយភាពមិនស៊ីចង្វាក់គ្នារវាងការបែងចែកខុសគ្នា នៅក្នុងសំណៅភាសាផ្សេងៗនៃវិធាន៨៧ (១) នៃវិធានផ្ទៃក្នុងដែលបង្ហាញពីបទដ្ឋាន«ឲ្យហួសពីវិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ។

**៣៩.** ជំនឿដោយឥស្សរចិត្តគឺជាទស្សនទានមួយដែលបានបង្កើតឡើងដើម្បីធានាថា ចៅក្រមមានសេរីភាពនៅក្នុងការវាយតម្លៃដោយខ្លួនឯងទៅលើភ័ស្តុតាងដែលត្រូវបានសួរដេញដោលនៅក្នុងអំឡុងពេលការជំនុំជម្រះ។

**(នៅមានត)**

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# សៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក

សៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោកគឺជាសៀវភៅដំបូងដែលសរសេររួមគ្នារវាងអ្នកសិក្សាជាន់ខ្ពស់បរទេស និងជនជាតិខ្មែរ រួមមាន ៖ បណ្ឌិត លី សុខឃាង, បណ្ឌិត សូ ហ្វារីណា និងបណ្ឌិត ជា ផល្លា។ សៀវភៅនេះលើកឡើងអំពីអំពើប្រល័យពូជសាសន៍ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពី (ឆ្នាំ១៩៧៥-១៩៧៩) និងដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជារួមបញ្ចូលជាមួយប្រទេស៨ទៀតដែលធ្លាប់បានកើតឡើងនូវអំពើប្រល័យពូជសាសន៍ដូចជា នៅប្រទេស អាឡឺម៉ង់ អាម៉េនី បូស្នី និងរ៉្វាន់ដា។នៅក្នុងសៀវភៅនេះអ្នកនិពន្ធលើកឡើងពីចំណុចសំខាន់ៗដែលឈានទៅរក៖១) មូលហេតុនៃការសម្លាប់រង្គាលនិងការព្រឹត្តអំពើប្រល័យពូជសាសន៍ ២)ដំណើរការស្វែងរកយុត្តិធម៌ទៅតាមបរិបទ របស់ប្រទេសនីមួយៗ និង៣) ដំណើរការផ្សះផ្សាជាតិ បន្ទាប់ពីការសម្លាប់យ៉ាងរង្គាលនិងការទប់ស្កាត់ៗ ការសរសេរសៀវភៅនេះឡើងមិនមែនកើតឡើងដោយគំនិតរបស់មនុស្សតែ ម្នាក់ប៉ុណ្ណោះនោះទេគឺកើត




*លោក គ្រីស្តូហ្វ័រ ឌៀរីង ធ្វើបទបង្ហាញអំពីសៀវភៅអំពើប្រល័យពូជសាសន៍នៅកម្ពុជា*

ឡើងដោយទស្សនវិស័យ និង គំនិតរួមគ្នា ដើម្បីបង្ហាញថា រាល់ខ្លឹមសារទិន្នន័យ និងព័ត៌មាននៅក្នុងសៀវភៅនេះមានភាពសុក្រិត្យត្រឹមត្រូវនៅក្នុងបរិបទប្រទេសនីមួយៗ និងនៅលើសាកលលោកៗសៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោកនេះ បានឆ្លងកាត់គណៈកម្មាធិការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដែលមានការ

ម្លាប់រង្គាលដែលស្រដៀងនឹងប្រទេសកម្ពុជាដែរដូចជាប្រទេសអាម៉េនីប្រទេសអាឡឺម៉ង់ប្រទេសបូស្នី និងប្រទេសរ៉្វាន់ដា» ៗប្រទេសអាម៉េនី គឺជាប្រទេសដំបូងដែលត្រូវបានយល់ឃើញដោយអ្នកស្រាវជ្រាវជាន់ខ្ពស់ថា កើតមានអំពើប្រល័យពូជសាសន៍នៅក្នុងសតវត្សរ៍ទី២០គឺនៅឆ្នាំ១៩១៥ប្រសិនបើគិតមកដល់បច្ចុប្បន្ន គឺមានរយៈពេល ១០៤ឆ្នាំហើយៗ



សាស្ត្រាចារ្យមកពីហាសិបសាកលវិទ្យាល័យទូទាំងប្រទេសកម្ពុជាបានចូលរួមនៅក្នុងសន្និសីទស្ដីអំពីអំពើប្រល័យពូជសាស្ត្រនៅកម្ពុជា

ចូលរួមពីសាស្ត្រាចារ្យ អ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ និងអប់រំរបស់ជាតិនិងអន្តរជាតិជាច្រើនរូបទៀតផងមុននឹងបោះពុម្ពជាភាសាអង់គ្លេសនៅពេលនេះៗ

បេក្ខបណ្ឌិត សូ ហ្វារីណា មានប្រសាសន៍ថា ៖ «សៀវភៅនេះផ្ដោតទៅលើការសិក្សាបែបប្រៀបធៀប ដោយមានការរួមបញ្ចូលប្រទេសយ៉ាងហោចណាស់ចំនួន៤ ទៀតដែលធ្លាប់បានឆ្លងកាត់ជម្លោះអំពើប្រល័យពូជសាសន៍ និងការស

នៅប្រទេសអាម៉េនី អំពើប្រល័យពូជសាសន៍ បានកើតឡើងនៅថ្ងៃទី២៤ខែមេសាឆ្នាំ១៩១៥,នៅប្រទេសកម្ពុជាកងទ័ពខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, នៅប្រទេសរ៉្វាន់ដា មានការសម្លាប់រង្គាលជនជាតិទុតស៊ីនៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៤ ហើយនៅខែមេសានេះ ក៏ត្រូវបានអង្គការសហប្រជាជាតិជ្រើសយកជាថ្ងៃរំឭកខួបអំពើប្រល័យពូជសាសន៍ និងការសម្លា

ប់រង្គាលសម្រាប់ប្រទេសវ៉ាន់ដាដែរ។ ប្រទេសទាំង៥នេះលើកលែងតែប្រទេសអាម៉េនីគឺបាន និងកំពុងធ្វើការជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ទាំងឡាយ ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលទៅលើប្រជាជន ព្រមទាំងប្រើប្រាស់វិធីមួយចំនួនទៀត ដើម្បីការចងចាំនិងផ្សះផ្សាជាតិ។ សៀវភៅនេះក៏ត្រូវបានរំពឹងថា នឹងផ្តល់ប្រយោជន៍ជាច្រើនដល់ការសិក្សាអប់រំ និងជនរងគ្រោះនៃការកាប់សម្លាប់ដែរ៖

-ពង្រីក និងពង្រឹងសមត្ថភាពសាស្ត្រាចារ្យដោយបញ្ច្រៀបខ្លឹមសារដែលមាននៅក្នុងសៀវភៅនេះ នៅក្នុងកម្មវិធីបង្រៀននៅឯសកលវិទ្យាល័យឲ្យមានប្រសិទ្ធភាព

- ស្វែងរកការដោះស្រាយសំណួរលំបាកៗមួយចំនួនដែលត្រូវបានសួរជាញឹកញាប់ទាក់ទងការកើតឡើងនៃការកាប់សម្លាប់

- ជំរុញឲ្យមានការទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះនិងកាត់បន្ថយអារម្មណ៍ឯកោ និងភាពជាជនរងគ្រោះតែម្នាក់ឯងរបស់ប្រជាជនកម្ពុជា ដោយសារមានមនុស្សជាច្រើនជាទៀតដែលជាជនរងគ្រោះ ដោយអំពីប្រល័យពូជសាសន៍និងការកាប់សម្លាប់ទ្រង់ទ្រាយធំ

-ជំរុញឲ្យមានការចងចាំ តាមរយៈការបង្រៀនការពិភាក្សាការចែករំលែកសាច់រឿង របស់អ្នករស់រានមានជីវិតដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួមទប់ស្កាត់ កុំឲ្យរបបខ្មែរក្រហមឬការកាប់សម្លាប់ កើតមាននៅលើទឹកដីកម្ពុជានិងនៅលើពិភពលោកៗ

លោកបណ្ឌិត លី សុខឃាង មានប្រសាសន៍ថា «សៀវភៅនេះពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះអ្នកសរសេរនេះគឺជាជនជាតិខ្មែរ និងបានសរសេរពីរឿងរ៉ាវ និងប្រវត្តិសាស្ត្រដ៏រន្ធត់របស់ខ្លួន ហើយបានចែករំលែកទៅកាន់ពិភពលោកៗលោកបន្តថា ដោយសារនៅក្នុងសៀវភៅនេះ មួយផ្នែកនិយាយអំពីដំណើរស្វែងរកយុត្តិធម៌ តាមរយៈការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ដូច្នេះ សៀវភៅនេះក៏នឹងជួយធ្វើឲ្យជនរងគ្រោះកម្ពុជាបានធូរស្បើយដែរ។ ការសរសេរសៀវភៅនេះឡើងគឺចង់បង្ហាញថា មិនមែនតែប្រជាជនកម្ពុជាទេដែលទទួលរងការឈឺចាប់ និងការកាប់សម្លាប់យ៉ាងរង្គាលគឺមានប្រជាជនផ្សេងៗ នៅជុំវិញពិភពលោកទទួលរងដូចគ្នានេះដែរ។ យើងមានបំណងដាក់បញ្ចូលសៀវភៅនេះទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជា និងសម្រាប់ការសិក្សាពីអំពើប្រល័យពូជសាសន៍ជាសកលដែរ។ លោក គ្រិស្តូហ្វ័រ ឌៀរីង អ្នកជំនាញកម្មវិធីអប់រំដែលបានចូលរួមផ្ទៀងផ្ទាត់ខ្លឹមសារនៅក្នុងសៀវភៅនេះមានប្រសាសន៍ថា« សៀវភៅនេះមិនមែនផ្តោតសំខាន់តែទៅលើទំហំនៃ ការឈឺចាប់របស់ប្រទេសនីមួយៗនោះទេ ប៉ុន្តែចង់បង្ហាញថាមូលហេតុអ្វី បានជាអំពើហិង្សាកើតឡើង និងមានការសម្លាប់សម្លាប់ជាទ្រង់ទាយធំ»។ លោកបន្តថា អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលមិនមែនកើតឡើងតែក្នុងប្រទេសទាំង៥នេះទេ គឺបានកើតឡើងនៅជុំវិញពិភពលោកដូចជានៅប្រទេសអ៊ីរ៉ាក់ សេរ៉ាឡេអូន ក្វាតេម៉ាឡា និងនៅតំបន់ដាហ្វ័រ ប្រទេសស៊ូដង់ៗ

ដូច្នេះ ការសិក្សាពីអំពើប្រល័យពូជសាសន៍នេះពិតជាមានសារសំខាន់ណាស់ ហើយគ្រូក៏អាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដើម្បីបង្រៀនសិស្សអំពើប្រល័យពូជសាសន៍ទាំងនេះដែរ។ សៀវភៅនេះ ក៏មានផ្នែកមួយដែលនិយាយអំពីដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងមានរឿងរ៉ាវរបស់ជនរងគ្រោះនិងប្រជាជនកម្ពុជាជាច្រើននៅក្នុងតុលាការនេះដែលលោកគ្រូ-អ្នកគ្រូ អាចយកមកប្រើប្រាស់ធ្វើជាសម្ភារៈឧបទេសក៏សម្រាប់បង្រៀនបានដែរ។

អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល់មិនមែនកើតឡើងទៅលើក្រុមមួយ ជាតិពន្ធុមួយ ឬប្រទេសមួយទេ គឺអាចឡើងនៅលើ គ្រប់ជាតិសាសន៍ គ្រប់ពេល និងគ្រប់ទឹកន្ទៃងប្រសិនបើយើងមិនយកចិត្តទុកដាក់ទប់ស្កាត់ និងសិក្សារៀនសូត្រពីវាឲ្យបានច្បាស់លាស់នោះទេ។

**សោម ប៊ុនថន**

# សេចក្តីប្រកាសរកសាច់ញាតិ

ខ្ញុំសូមប្រកាសរកសាច់ញាតិ ដែលបែកគ្នាក្នុង ឆ្នាំ១៩៧៥គឺត្រកូលតាំងដែលមានរាយនាមដូចខាងក្រោម៖

១) តាំង ហុក (ប្រុស)

២) តាំង អែម (ស្រី)

៣) តាំ ឈេ (ប្រុស)

៤) តាំង ឡេង (ប្រុស)

៥) តាំង ហេង (ប្រុស)

៦) តាំង ម៉េង (ប្រុស)

៧) តាំង ខេង (ប្រុស)

៨) តាំង ស៊ីវ (ស្រី)

ព្រមទាំងឪពុកម្តាយនិងប្អូនរបស់ពួកគាត់ខាងលើ។នៅមុនឆ្នាំ១៩៧៥ ក្រុមគ្រួសារខាងលើមានទីលំនៅនៅកោះកាពិខេត្តកោះកុង។

ខ្ញុំឈ្មោះអាម៉ាស ធ្វើការនៅរោងចក្រតម្បាញត្រាំអិចគីឡូម៉ែត្រលេខ៦ ជាមួយចែឡានបងស្រីអាហៀង។ មុនចូល



រូបថតរបស់ អាម៉ាស ក្នុងឆ្នាំ១៩៧៩

ឆ្នាំប្រពៃណីខ្មែរបីថ្ងៃ បងឈេ បានចូលមកទទួលខ្ញុំនៅរោងចក្រតម្បាញដែលខ្ញុំធ្វើការ ហើយបានប្រាប់ថាក្រុមគ្រួសាររបស់គាត់ឲ្យមកយកខ្ញុំទៅរស់នៅកោះកាពិជាមួយគ្នា។ ខ្ញុំពិតជាចង់ទៅជាមួយគាត់ណាស់។ប៉ុន្តែ ខ្ញុំ រវែកក្នុងចិត្តព្រោះខ្ញុំក៏មិនចង់ទុកម៉ាក់ខ្ញុំចោលដែរ។ គាត់នៅតែម្នាក់ឯង។ ខ្ញុំក៏និយាយប្រាប់បងឈេថា ខ្ញុំមិនអាចទៅឥឡូវបានទេ។ បងឈេក៏សុំរូបថតខ្ញុំមួយសន្លឹកយកទៅជាមួយ។ ក្រោយមកខ្ញុំទទួលដំណឹងថាក្រុមគ្រួសាររបស់គាត់បានចាកចេញទៅក្រៅប្រទេសអស់ហើយ។

បីថ្ងៃក្រោយមកគ្រួសារខ្ញុំ ចែឡាន ព្រមទាំងប៉ាម៉ាក់របស់អាហៀង ព្រមទាំងកូនថៅកែ រោងចក្រត្រូវបានជម្លៀសពីភ្នំពេញទៅព្រែកព្នៅ។ យើងទាំងអស់គ្នា សម្រាកនៅទីនោះបានបីថ្ងៃបន្ទាប់មកក៏បែកគ្នាអស់ ដោយមិនដឹងទៅទីណាពីព្រោះមនុស្សដែលជម្លៀសមកពីភ្នំពេញ និងកន្លែងផ្សេងៗមកផ្តុំគ្នានៅទីនោះ។ ក្រោយមក គ្រួសារខ្ញុំ ត្រូវបានជម្លៀសបន្តទៅខេត្តក្រចេះហើយស្នាក់នៅទីនោះ រហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបប៉ុលពតដួលរលំទៅភ្លាមៗ នៅឆ្នាំ១៩៧៩ក្រុមគ្រួសាររបស់ខ្ញុំ បានមករស់នៅគីឡូម៉ែត្រលេខ៨សង្កាត់ច្រាំងចំរេះ ក្រុងភ្នំពេញ។ នៅឆ្នាំ១៩៨៤ ខ្ញុំបានទៅខេត្តកោះកុងដើម្បីទៅសួររកក្រុមគ្រួសារខាងលើ។

ខ្ញុំបានជួបជាមួយអ៊ីណាក់ដែល អះអាងថាគាត់ស្គាល់ក្រុមគ្រួសាររបស់បង១។ គាត់ប្រាប់ខ្ញុំថាក្រុមគ្រួសារបង១បានចាកចេញទៅប្រទេសបារាំងអស់ហើយ។ ខ្ញុំ ពិតជាចង់ជួបជាមួយបង១ណាស់។ ប្រសិនបើបងទាំងអស់គ្នា និងក្រុមគ្រួសារបានទទួលដំណឹងនេះហើយ សូមទាក់ទងមកខ្ញុំតាមទូរស័ព្ទលេខ+៨៥៥ ១២ ៥៨៦ ២៩៣ ឬ +៨៥៥ ១៧ ២៨៣ ៨២៨ឬ email: sofarina12@gmail.com

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**(តពីលេខមុន)**

*ជាម ជិន មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយខេត្តកំពង់ធំ ជាកូនរបស់ ស្រី ជាម និង ហ៊ុន ដើង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកពល៤៥០ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ជាម ជិន នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៧ បន្ទាប់ពី ជាប់ឃុំឃាំងអស់រយៈពេល៥៥ថ្ងៃ។*

*ជាម មុនី មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃវែងខេត្តព្រៃវែង ជាកូនរបស់ ជាម កែម និង ទូន ឡោក មានប្រន្ធឈ្មោះ អ៊ុក សាវឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួនមន្ទីរកងពល១៧០ ខែមិថុនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ចំណែកឯប្រពន្ធ អ៊ុក សាវឿន ឬ អ៊ុក វឿន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែង នៅថ្ងៃទី១៧ ខែមិថុនាឆ្នាំ១៩៧៨និងសម្លាប់ចោលនៅថ្ងៃបន្ទាប់។*

*ជាម វ៉េង សៀន មានអាយុ៤១ឆ្នាំ ក្នុងឆ្នាំ១៩៧៧ អតីតសក្តិ៤កន្ទះ វិស្វករជួសជុល មានស្រុកកំណើតនៅកងមាសខេត្តកំពង់ចាម ជាកូនរបស់ ជាម ទូច និង ស្រីធៀមណន មានប្រពន្ធឈ្មោះទាគីមស៊្រុនមានកូនប្រុស៣នាក់ និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែកថ្ងៃទី១ ខែមករាឆ្នាំ១៩៧៧ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ០៥ បន្ទប់តូច ៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការសម្លាប់នៅឡើយ។ប្រពន្ធឈ្មោះទា គីមស៊្រុន ត្រូវបាន ខ្មែរក្រហមចាប់ខ្លួនមកជាមួយប្តីនៅថ្ងៃតែមួយ ហើយសម្លាប់ចោល នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពី ជាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។*

*ជាម សំអាត ហៅ វឿន មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅខ្សាច់កណ្តាលខេត្តកណ្តាលជាកូនរបស់ ជាម អ៊ុល និង ស្រីឈីន អៀ មានប្តីឈ្មោះ សឿ វ៉ាស៊ុ ហៅ ឌឿន មានកូនប្រុស ២នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្រសួងការបរទេស ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧។សឿវ៉ាស៊ុត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ១ថ្ងៃ មុនប្រពន្ធ។ នៅពុំទាន់មានឯកសារ បញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

*ជាម អេង មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅលើកដែកខេត្តកណ្តាលជាកូនរបស់ ជាម សេង និង យូ ណាន់ មានប្រពន្ធឈ្មោះ សាម ឡុង មានកូនប្រុស២នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ៧០៣ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅ ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៨ បន្ទប់ធំ២។ ខ្មែរក្រហមចាប់បញ្ជូន ជាម អេង មកដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែមិថុនាឆ្នាំ១៩៧៦ហើយសម្លាប់ចោលនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦៣ថ្ងៃ។*

*ជិន ធាង មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅមេសាងខេត្តព្រៃវែង ជាកូនរបស់ ផែង ជិន និងមីងសុកអ៊ុយត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០២។ ខ្មែរក្រហមសម្លាប់ ជិន ធាង នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧០ ថ្ងៃ។*

*ជិន ថុល មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពារាំងខេត្តព្រៃវែង ជាកូនរបស់ ជិន លីម និងមីងយ៉ែម មុន មានប្រពន្ធឈ្មោះ កង សុំ មានកូនស្រី២នាក់ត្រូវ*

បានខ្មែរក្រហមចាប់ខ្លួននៅកងពល២៩០ ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០៤ បន្ទប់តូច១៦។ ខ្មែរក្រហមសម្លាប់ ជិន ថុល នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៣៣២ ថ្ងៃ។

ជិន ប៉ោលាប ហៅ ឆេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មរដ្ឋក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នាមួយនៅថ្ងៃទី១២និងមួយទៀតនៅថ្ងៃទី១៣ ខែកញ្ញាឆ្នាំ១៩៧៦ ហើយកាលបរិច្ឆេទនៃការសម្លាប់គឺនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៦។

ជិន លន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល២៩០ ក្នុងឆ្នាំ១៩៧៦។

ជិន វី មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទឹងសែនខេត្តកំពង់ធំ ជាកូនរបស់ ជី ជិន និងមីង នួន យុត ត្រូវបានខ្មែរក្រហមចាប់ខ្លួននកងពល៣១០ ថ្ងៃទី១១ ខែធ្នូឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះគ បន្ទប់ធំ ៥ បន្ទប់តូច ៤។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជិន សុន មានប្រពន្ធឈ្មោះ ផេង គឹមហួយ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកន្លែងរទេះភ្លើង ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់។

ជិន សុវត្ថិ ហៅ វង់ មានអាយុ៥១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅថាញ់ វ៉ា ខេត្តកម្ពុជាក្រោមជាកូនរបស់លោកតាជិន និងលោកយាយ សៀន មានប្រពន្ធឈ្មោះ ខ្មៅកម្រងហោកងមានកូនប្រុស៥នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្រសួង ស-៨ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះជបន្ទប់ធំ៣ បន្ទប់តូច៨។ខ្មែរក្រហមសម្លាប់ជិនសុវត្ថិ ហៅ វង់ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

ជិនហឿនមានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបាត់ដំបងខេត្តបាត់ដំបង ជាកូនរបស់ជិន ហ៊ត និងស្រីទាហូមានប្រពន្ធឈ្មោះឡេងសំបូរ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅបាត់ដំបង ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ០៦បន្ទប់លេខ១៤។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន៣ខុសគ្នាមួយនៅថ្ងៃទី៦,ទី១៤ ខែមីនា និងមួយទៀតនៅថ្ងៃទី៩ខែឧសភាឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ជិនហឿននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦។

ជិន ផល មានអាយុ២៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ អតីតទាហានពលទោមានស្រុកកំណើតនៅដង្កោ ខេត្តកណ្តាលជាកូនរបស់ពូសូជិននិងមីង យឹម ដាន់ មានប្រពន្ធឈ្មោះ សាយសុក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិព្រែកហូរ ថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៧បន្ទប់ធំ២។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី២៣ និងមួយទៀតនៅថ្ងៃទី៣១ខែមីនាឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ជិនផលនៅថ្ងៃទី២៣ខែឧសភា ឆ្នាំ១៩៧៦។

ជីន វ៉ែន មានអាយុ៤៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញជាកូនរបស់លោកតា គិប ធីន និងលោកយាយយីវលនមានប្រពន្ធឈ្មោះចែម ស៊ីឆ៉ាត់ មានកូនប្រុស២នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅតំបន់២ ៥ ។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន៣ ខុសគ្នាមួយនៅថ្ងៃទី១១ ខែមករា, ថ្ងៃទី១៤ ខែមីនា និងមួយទៀតនៅថ្ងៃទី១៩ខែមេសាឆ្នាំ១៩៧៦ដូចគ្នា។ ខ្មែរក្រហមសម្លាប់ ជីន វ៉ែន នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៦។

ជីម ង៉ី ហេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គិសនីទី២ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជីម ង៉ី ហេងនៅថ្ងៃទី៦ខែធ្នូឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៤០ថ្ងៃ។

ជីម មី មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញជាកូនរបស់ចាន់លី និង អោមម៉ន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង១៣ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧

ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ៥ បន្ទប់តូច៩។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជីង កុកហួរ ជាភារៈធារីស្តីទីស្ថានទូតមកពីប្រទេសបារាំងត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៦និងសម្លាប់នៅថ្ងៃទី២៩ខែតុលា ឆ្នាំ១៩៧៦។

ជីង ឈុនលាង មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅមេមត់ខេត្តកំពង់ចាម ជាកូនរបស់ ជីង អ៊ីវ និងស្រីជីងយ៉េត មានប្រពន្ធឈ្មោះម៉ែនស៊ីមនមានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិតាឡី ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៥ បន្ទប់តូច ១៨។ ខ្មែរក្រហមចាប់បញ្ជូន ជីង ឈុនលាងមកដល់គុកទួលស្លែងនៅថ្ងៃទី២៨ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ខែមីនាឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៤២ថ្ងៃ។

ជីម ជឿន យុទ្ធជនកង១៣ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស-២១យក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហម ចាប់បញ្ជូន ជីម ជឿន មកដល់គុកទួលស្លែងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៧ថ្ងៃ។

ជីម ជៀក ជាកូនរបស់ ជីម ឌុី ហេង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅអគ្គិសនីទី៣ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ក្រោយឪពុកតែ២ថ្ងៃប៉ុណ្ណោះ។ ខ្មែរក្រហមសម្លាប់ជីម ជៀក នៅថ្ងៃបន្ទាប់។

ជីម ព្រូ ជាកូនរបស់ ជីម ឌុី ហេង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅអគ្គិសនីទី៣ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូនជីមព្រូមកដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ក្រោយឪពុកតែ២ថ្ងៃប៉ុណ្ណោះ និងសម្លាប់ចោល នៅថ្ងៃបន្ទាប់។

ជីម យ៉ាងគី ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលយលទៅផ្ញើបញ្ជីឡើងវិញដោយ ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាជីមយ៉ាងគី ជាជនជាតិវៀតណាម ចាប់មកពីកំពង់សោម ដូចគ្នាហើយសម្លាប់ចោល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦។

ជីម យ៉ាងគី ជនជាតិយួន (វៀតណាម) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។

ជី លៀន មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅឃ្លូកខេត្តក្រមួនសឪពុកម្តាយ ឌិន ជី និង ឡី ម៉ូយ មានប្តីឈ្មោះ សៀង ឌិន មានកូនប្រុស ៤នាក់និងស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអូគ្រេះ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៥ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះ៤ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជី លៀន នៅថ្ងៃទី១៤ខែកក្កដាឆ្នាំ១៩៧៦បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦៩ថ្ងៃ។ ចំណែកឯប្តីឈ្មោះ សៀង ឌិនឬសៀងទ្រឹងត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៦។

ជី ហៀង ហ៊ិន់ ហៅណែម មានអាយុ២៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧មានស្រុកកំណើតនៅចំការលើខេត្តកំពង់ចាមជាកូនរបស់ពូជីឆាយ និងមីង ទ្រីស៊ាន យុទ្ធជនកង១៣ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ(មន្ទីរ) ស-២១យ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ២ បន្ទប់តូច ១១។

ជី វុត មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកប្រសព្វ ខេត្តក្រចេះ ជាកូនរបស់ ជី គាយ និងស្រី ឃិន លន់ មានប្រពន្ធឈ្មោះស៊ុប ស៊ាមហ៊ុយមានកូនប្រុស២ នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរក-១៥ថ្ងៃទី២៣ខែតុលាឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំង

នៅគុកទួលស្លែងក្នុងផ្ទះងបន្ទប់ធំ៣ បន្ទប់តូច៨ ហើយសម្លាប់ចោលនៅថ្ងៃទី៦ ខែមីនាឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៣៥ ថ្ងៃ។

ជុក ចយ ហៅ ចេវ មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូអៀម ជុក និងមីង ឌីន ស៊ីន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះល បន្ទប់ធំ៤ បន្ទប់តូច២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជុច ស៊ឹម ហៅ សាន មានអាយុ៥២ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់លោកតាយូនិងលោកយាយវ៉ា មានប្រពន្ធឈ្មោះ ឡេង យ៉ាន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជុន ឈុំ ហៅ តាំង មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំឪ ជុន និងអ៊ំស្រី អុច យ៉ែម មានប្រពន្ធឈ្មោះ ហួត ហេន ហៅ តួរ មានកូនប្រុស ២នាក់និងស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភាគឧត្តរ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ជុន ឈុំ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៤១ ថ្ងៃ។

ជុន ហុង ហៅ ហេង មានអាយុ១៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាសខេត្តកំពង់ចាមត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ៩៨ថ្ងៃទី៦ខែមករាឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី១៧ខែមីនាឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧១ ថ្ងៃ។

ជុំ កន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពី ជាប់ឃុំឃាំងអស់រយៈពេល៤៤ថ្ងៃ។

ជុំ ខ្សាន ត្រូវបានខ្មែរក្រហមឃាត់ខ្លួន នៅកន្លែងរទេះភ្លើង ថ្ងៃទី២៩ ខែតុលាឆ្នាំ១៩៧៦។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជុំ ចំរើន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ជុំ ថៃ អ៊ី ហៅ ប៊ុក មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ជាកូនរបស់អ៊ំជុំសុកនិងអ៊ំស្រីជាយ៉ាវមានប្រពន្ធឈ្មោះសេរឿងគឹមលាង ហៅភីមានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ជុំ ថៃ អ៊ីនៅថ្ងៃទី១ ២ ខែឧសភាឆ្នាំ១ ៩ ៧ ៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៨៥ ថ្ងៃ។

ជុំ ធន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជុំ ធន នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦។

ជុំ ធឿន មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពញាក្រែកខេត្តកំពង់ចាមជាកូនរបស់ពូជុំយ៉ាន់និងមីងមូលយ៉ែម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ជុំ ធឿ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៣៩ថ្ងៃ។

ជុំ នាង ហៅ ជុំ កញ្ញា មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃវែង ខេត្តព្រៃវែង ជាកូនរបស់ពូ ជុំ ជា និងមីង ងិង តិម ត្រូវបានខ្មែរក្រហមចាប់ខ្លួនរោងចក្រម្បាញ ត-២ ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជុំ ប៊ុន ណាត់ កូនស្រីរបស់ ជុំ ខ្សាន ខាងលើ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកន្លែងរទេះភ្លើង ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ក្រោយឪពុកមួយថ្ងៃ។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ដុំ ប៊ុនរឿន មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសេរីសោភ័ណខេត្តបាត់ដំបង( ឥឡូវខេត្តបន្ទាយមានជ័យ)ជាកូនរបស់ពូឃឹមដោក និងមីងយុនដាន់មានប្រពន្ធឈ្មោះយីសួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបាត់ដំបងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ដុំប៊ុនរឿននៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល១៦៧ ថ្ងៃ។

ដុំបូណាដែត ហៅ មើម មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតសិស្ស មានស្រុកកំណើតនៅរលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាកូនរបស់ពូ ដុំ ផល និងមីង គី ណាត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញរដ្ឋ ត-៥ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់លេខ ១៦។ ខ្មែរក្រហមចាប់បញ្ជូន ដុំ បូណាដែត ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារ បញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ដុំ ផល មានអាយុ១៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកៀនស្វាយខេត្តកណ្ដាលជាកូនរបស់ពូដុំដានិងមីងមិចអានត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ១៥ ថ្ងៃទី១ខែកុម្ភៈឆ្នាំ១៩៧៧ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ១ បន្ទប់តូច១។ ខ្មែរក្រហមសម្លាប់ ដុំ ផល នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ ១៩៧៧ បន្ទាប់ពី ដាប់ឃុំឃាំងអស់រយៈពេល១០១ ថ្ងៃ។

ដុំ លី ហៅ យ៉ាង មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកូនរបស់អ៊ំសៅដុំនិងអ៊ំស្រីគុមខៀវ មានប្រពន្ធឈ្មោះ នៃ សាគីម ហៅ រីមានកូនស្រី នាក់ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ៥បន្ទប់តូច៣។ ខ្មែរក្រហមសម្លាប់ ដុំ លីនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។

ដុំ លឹម ហៅ ពល់ មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ដុំ គៀក និងអ៊ំស្រី ណើ សន មានប្រពន្ធឈ្មោះ ញ៉ឹប ណាត ហៅ ព្រឹក មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ដុំលឹមនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល៧៥ ថ្ងៃ។

ដុំ លឹម មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ ធ្លាប់បួសជាសង្ឃមានស្រុកកំណើតនៅកោះធំ ខេត្តកណ្ដាល ជាកូនរបស់ពូដុំស៊ុននិងមីងសេកប្រិច ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅបន្ទាយ ហែម អេង ថ្ងៃទី២៧ខែកុម្ភៈឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ០១ បន្ទប់តូច ១។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៧ ខែកុម្ភៈ និងមួយទៀតនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៦ ដូចគ្នា។ ខ្មែរក្រហមសម្លាប់ ដុំ លឹម នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦។

ដុំ សារ៉ែន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុង១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ដុំ សារុន ហៅ ផាន់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល២៩០ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដុំ សារុន នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៧។

ដុំសុខនត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកន្ទែងរទេះភ្លើង ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែងនិងការសម្លាប់នៅឡើយ។

ដុំ សេដ្ឋា មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្រាំកក់ខេត្តតាកែវ ជាកូនរបស់ពូ ដុំ ប៊ុន និងមីង ហ៊ូ ណម ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្ថានីយអយស្ម័យយានភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ផ បន្ទប់ធំ ៥ បន្ទប់តូច ១៧។

ជុំ សេដ្ឋា មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ជាកូនរបស់ពូ ជុំ ប៊ុន និងមីង ហ៊ូ ណម ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្ថានីយអយស្ម័យយានភ្នំពេញ ថ្ងៃទី២៨ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៥ បន្ទប់តូច ១៧។ សេដ្ឋាបានស្នើសុំអង្គការថាសូមស្នើអ/កប/វ (អង្គការបដិវត្តន៍វិលទៅធ្វើការវិញ)។ សូមស្នើអ/កមេត្តាអនុគ្រោះ ដោះស្រាយឲ្យរូបខ្ញុំធ្វើកម្មករតទៅទៀត។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែងនិងការសម្លាប់ឡើយ។

ជូ ឈុន មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៥៤(ស្រុកកណ្តាលស្ទឹង) ខេត្តកណ្តាលជាកូនរបស់ពូជូឈឺននិងមីងប៊ុនឡុង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក១៥៤ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ០១បន្ទប់ធំ៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែងនិងការសម្លាប់នៅឡើយ។

ជូ ព្រិន្ទ យុទ្ធជនកង១៣ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ(មន្ទីរ) ស-២១ យ ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជូ ព្រិន្ទ នៅថ្ងៃបន្ទាប់ដោយមិនទុកយូរទេ។

ជូ ម៉េង មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅជង្កោរខេត្តកណ្តាលជាកូនរបស់ពូគួរ រីងជិកនិងមីងអង់អ៊ីវមានប្រពន្ធឈ្មោះខេង ម៉េងមានកូនស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួនសុក្រ២១ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែងក្នុងបន្ទប់ធំ ០៦ បន្ទប់តូច៣។ កាលបរិច្ឆេទ នៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី២៦ ខែកុម្ភៈ និងមួយទៀតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦។ រីឯកាលបរិច្ឆេទនៃការសម្លាប់មាន២ដែរ មួយនៅថ្ងៃទី១៩ ខែមេសា និងមួយទៀតនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ ដូចគ្នា។

ជូ សុន្ធា ហៅ សាមី មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រះស្តេច ខេត្តព្រៃវែង ជាកូនរបស់ពូជូ មាស និងមីង យ៉យ សន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញ ត-៣ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជូ ឈិត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងគឺនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។

ជួង ដេង ហៅឡុង សេង មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្អាង ខេត្តកណ្តាល ជាកូនរបស់អ៊ំឡេង ជួង និងអ៊ំស្រី ម៉ុល អឿង មានប្រពន្ធឈ្មោះ បាន ស៊ីវឡាំង ហៅ ឡាំង មានកូនប្រុស ៤នាក់និងស្រី៣នាក់ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅមន្ទីរកសិដ្ឋាន របស់មន្ទីរ២៥ តំបន់២៥ ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ០៣ បន្ទប់តូច ៥។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ ខុសគ្នាមួយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៥ និងមួយទៀតនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ជួង សារ៉ុន ហៅ ហ៊ាន មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅចំការលើ ខេត្តកំពង់ចាម ជាកូនរបស់ពូជួង ហុក និងមីង សុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ៣-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជួង សារ៉ុននៅថ្ងៃទី១៧ខែមីនាឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៧១ ថ្ងៃ។

ជួន នួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ជួន នួន នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៤៥ថ្ងៃ។

ជួន ឆុក មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ ស្រុកកំណើត

នៅស្រុក២០(ស្រុកស្អាង) ខេត្តកណ្តាលជាកូនរបស់ពូជួនត្រី កនិង មីងស្ងួន គួយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ(មន្ទីរស)-២១ យ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី២៤ និងមួយទៀតនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជួនឆុកនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

ជួន ផល្លា មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក២០(ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ពូជួប ភឹម និងមីង លុយ មិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ(មន្ទីរ)ស-២១យ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជួនផល្លានៅថ្ងៃទី១៨ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល២៥ថ្ងៃ។

ជួន រ៉ុង ហៅ សឿន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះអណ្តែត ខេត្តតាកែវ ជាកូនរបស់ពូជួន កាក់ និងមីង គង់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ជួន រ៉ុង ហៅ សឿន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។

ជួន វ៉ាន់នី ហៅ នីន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ ជាកូនរបស់ពូ អឿន និងមីង សុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មក្រុង ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះចបន្ទប់ធំ៤បន្ទប់តូច១២។ខ្មែរក្រហមសម្លាប់ជួន វ៉ាន់នី នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល ៥៧ ថ្ងៃ។

ជួន វួច ហៅ ជាតិ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឋាមពល ក្នុងឆ្នាំ១៩៧៦។

ជួន អុល ហៅ មាស មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀមខេត្តកំពង់ចាមជាកូនរបស់អ៊ំសួរជួននិងអ៊ំស្រីភោគហាក់ ប្រធានស្រុកកងមាសមានប្រពន្ធឈ្មោះសអ៊ាត ហៅ ស៊ីម មានកូនស្រី៣នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់៤១ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ជួន អុល នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីដាប់ឃុំឃាំងអស់រយៈពេល១៣៣ថ្ងៃ។

ជួន ហេង មានអាយុ៣៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃកប្បាសខេត្តតាកែវជាកូនរបស់អ៊ំយូ ធិ និងអ៊ំស្រីឈិនប៊ុមានប្រពន្ធឈ្មោះហាក់ សាណុំ ហៅ កែវ ចរណៃ មានកូនប្រុស ២នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ(ឃុំ) ជប់ (ស្រុក) ព្រះនេត្រព្រះ ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៦ បន្ទប់ធំ ៦។ បើយោងតាម ឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយលទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ជួន ហេង ហៅ មិត្តដាកម្មករថ្មី ត្រូវបានខ្មែរក្រហមចាប់ខ្លួនមកពីរោងចក្រចានយកមកដាក់គុកទួលស្លែងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

ជួរ សូវ៉ាន់ហន មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាមជាកូនរបស់ពូជួរវិននិង មីងជួន សម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកតាឡី-ដង្កោ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ១ បន្ទប់តូច ២។ នៅពុំទាន់មានឯកសារ បញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ជៀច មាច ហៅ វិចិត្រ មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពារាំង ខេត្តព្រៃវែង ជាកូនរបស់ពូ ជៀជួន និងមីង ព្រឿង ណន មានប្រពន្ធឈ្មោះ យឹម គង់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រក្រឡឹង ដ-៣ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់ឡើយ។

**(នៅមានត)**

**វ៉ាន ថាន់ពោដាវ៉ា និង ឡុង ដានី**



*រូបថតក្រុបក្រោយ ៖ អេង សោវត្ថា ជាកូនស្រីរបស់ តឹក សេងអេង ដែលត្រូវបានអង្គការចាប់ខ្លួនបញ្ជូនទៅមន្ទីរសរ-២១*

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 239, November 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.